# ប្រវត្តិដើមពោធិព្រឹក្ស

## នៅពុទ្ធគយា វត្តជេតពន ប្រទេសស្រីលង្កា

## និងអានិសង្សនៃការបូជា


រៀបរៀងដោយ

ភិក្ខុរតនបុញ្ញោ បុត្ត សំណាន



ផ្សាយចេញពីវត្តវិសុទ្ធិមគ្គ

សៀមរាប ថ្ងៃ ១៤ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក

ពុទ្ធសករាជ ២៥៦៣

# ប្រវត្តិដើមពោធិព្រឹក្ស

## នៅពុទ្ធគយា វត្តជេតពន ប្រទេសស្រីលង្កា

## និងអានិសង្សនៃការបូជា

*រៀបរៀងដោយ*

**ភិក្ខុរតនបុញ្ញោ បុត្ត សំបាន**

សៀមរាប ថ្ងៃ ១៥ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក

ព.ស.២៥៦៣ គ.ស.២០២០

| | |
|---|---|
| ឈ្មោះសៀវភៅ | **ប្រវត្តិដើមពោធិព្រឹក្ស នៅពុទ្ធគយា វត្តជេតពន ប្រទេសស្រីលង្កា និងអានិសង្សនៃការបូជា** |
| អ្នករៀបរៀង | ភិក្ខុរតនបុត្តោ **បុត្ត សំបាន** |
| ទីកន្លែងធ្វើ | វត្តវិសុទ្ធិមគ្គ ភូមិបំពេញរាជ្យ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប |
| កាលបរិច្ឆេទ | ថ្ងៃអាទិត្យ ១៥ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០២០ |
| បោះពុម្ពលើកទី១ | ចំនួន ៥០០ ក្បាល នៅរោងពុម្ពគីមឡុង ភ្នំពេញ |
| ឧបត្ថម្ភបោះពុម្ពដោយ | -ឧបាសក **គីម សៀង**<br>-លោក **ចាន់ ម៉េត** អ្នកស្រី **គីម ស្នួង** និងកូនចៅ<br>-លោក **អ៊ុល រៃ** និងអ្នកស្រី **ឌី ផល** និងកូនចៅ<br>-លោក **ព្រហ្ម សុភ័ណ្ឌ** អ្នកស្រី **គីម ស៊ីម** និងកូន<br>-ឧបាសក **គីម លី** ឧបាសិកា **ភោគ ពៅ** និងកូន<br>-លោក **ស ប៉** អ្នកស្រី **គិត បញ្ញា** និងកូន<br>-លោក **គីម លៀង**, ទាយក **ផល្លី**<br>-លោក **សុខ ស៊ីឡង់** អ្នកស្រី **គីម ចាន់សី** និងកូន<br>-ឧបាសក **អលីនោ (ពិសិដ្ឋ)** អ្នកស្រី **ស៊ុន ហ្គិចឡាង** និងកូន<br>-លោក **អ៊ុច ចន្ធា** អ្នកស្រី **ឡុច ចន្ធូ** និងកូន និងពុទ្ធបរិស័ទមួយចំនួនទៀត ។ |
| សម្រាប់ចែកធម្មទាន | ក្នុងពិធីបុណ្យសម្ពោធឆ្លងខឿនដើមពោធិព្រឹក្ស វត្តព្រះច័ន្ទ ះពេញបូណ៌មី ហៅ វត្តជាងហ្លួង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង |
| ផ្សាយចេញពី | វត្តវិសុទ្ធិមគ្គ (ភិនវីទ្ធារាម) ស្រុកអង្គរធំ ខេត្តសៀមរាប |

# អារម្ភកថា

សៀវភៅ "ប្រវត្តិដើមពោធិព្រឹក្ស និងអានិសង្សនៃការបូជា" នេះ កើតឡើងដោយឧបាសក សៀង ពិសិដ្ឋ (អលីនោ) សុំឱ្យខ្ញុំរៀបរៀងឱ្យ ដើម្បីបោះពុម្ពចែកជាធម្មទាន ក្នុងពិធីបុណ្យសម្ពោធឆ្លងខឿនព្រះពោធិព្រឹក្ស ក្នុងវត្តព្រះច័ន្ទពេញ-បូណ៌មី ហៅ វត្តខាងឆ្នូង ភូមិអូរ ឃុំសាលាឃុំ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដែលបានដាំក្នុងពុទ្ធសករាជ ២៥៥៥ ដោយបានអារាធនាមកពីសាលារៀនសតិប្បដ្ឋាន ខេត្តបាត់ដំបង ដោយឧបាសក គឹម អូន ក្នុងពុទ្ធសករាជ ២៥៥៥ ។

សៀវភៅនេះ ក្នុងកាលបោះពុម្ពលើកដំបូងមានខុសអក្ខរខ្លះ ព្រោះខ្ញុំរៀបរៀងដោយប្រញាប់ដើម្បីឱ្យទាន់កម្មវិធីបុណ្យ ទើបពិនិត្យមិនបានសព្វគ្រប់ តែលើកនេះខ្ញុំបានកែតម្រូវវិញហើយ ព្រមទាំងបន្ថែមទំហំអក្សរនិងសរសេរមាតិកាផង តែក៏គង់នៅមានខុសខ្លះពុំខានឡើយ ដូច្នេះ សូមលោកអ្នកអាន និងអ្នកឈ្លាសទាំងឡាយ មេត្តាមួយកែតម្រូវដោយកុសលចេតនាផងចុះ ។

ដោយបុញ្ញានិសង្សនៃធម្មទាននេះ សូមឱ្យលោកអ្នកដែលជាម្ចាស់ធម្មទានទាំងឡាយផង លោកអ្នកអានទាំងឡាយផង ពពួកញាតិ និងសព្វសត្វទាំងឡាយក្នុងសង្សារវដ្តផង និងឧបាសក **គឹម អូន** ដែលទើបនឹងអនិច្ចកម្មថ្មីៗនេះផង បានជួបប្រទះនូវសេចក្តីសុខ ចម្រើន ក្នុងលោកនេះ និងក្នុងបរលោក និងសូមឱ្យបានជាបុគ្គលសម្មាទិដ្ឋិ សេពគប់សប្បុរស ស្តាប់ធម៌របស់សប្បុរ រហូតដល់ព្រះនិព្វានកុំបីក្លាយជាប្រការដទៃឡើយ។

សៀមរាប ថ្ងៃចន្ទ ៩ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
(១១,២,២០២០)

**ភិក្ខុរតនបុញ្ញោ ប៊ុត្ត សំបាន**

# មាតិកា

**មាតិកានុក្រម** **ទំព័រ**

អារម្ភកថា.....................................................................................៤
ពុទ្ធចេតិយវន្ទនា...........................................................................៨

## ប្រវត្តិដើមពោធិព្រឹក្ស

ដើមពោធិព្រឹក្ស ជាបរិភោគចេតិយ.................................................១០
ដើមពោធិព្រឹក្ស.............................................................................១១
**ប្រវត្តិដើមពោធិព្រឹក្សនៅប្រទេសឥណ្ឌា (ពុទ្ធគយា)**...........................១៧
**ដើមពោធិ៍ទី ១**............................................................................១៩
**ដើមពោធិ៍ទី ២**............................................................................២៨
**ដើមពោធិ៍ទី ៣**............................................................................៣៤
**ដើមពោធិ៍ទី ៤ (ពោធិព្រឹក្សដើមបច្ចុប្បន្ន)**......................................៣៥
**ប្រវត្តិដើមពោធិព្រឹក្សនៅវត្តជេតពន**..............................................៣៨
**ប្រវត្តិដើមពោធិព្រឹក្សនៅប្រទេសស្រីលង្កា**.......................................៥១
**១.កោះលង្កាជាប់ទាក់ទងនឹងព្រះពុទ្ធ**................................................៥៣
**២. សេចក្ដីសង្ខេបអំពីរឿងព្រះពុទ្ធសាសនា និងដើមពោធិព្រឹក្សមក កោះលង្កា**...........................................................................................៥៨
អ្នកទម្លាយព្រះចេតិយ មានទោសស្មើនឹងអនន្តរិយកម្ម..........................៩៨

## អានិសង្សនៃការបូជាដើមពោធិព្រឹក្ស

១.អានិសង្សបូជាដីខ្សាច់ត្រង់ខឿនដើមពោធិព្រឹក្ស...........................១០២

២.អានិសង្សស្រោចទឹកក្រអូបដើមពោធិព្រឹក្ស.................................១០៣
៣.អានិសង្សបូជាប្រទីបជុំវិញដើមពោធិព្រឹក្ស.................................១០៥
៤.អានិសង្សបូជាទង់ រើសស្លឹកពោធិ៍ និងថ្វាយបង្គំដើមពោធិព្រឹក្ស.......១០៦
៥.អានិសង្សដាំដើមពោធិព្រឹក្ស.......................................................១០៨
៦.អានិសង្សស្រោចទឹកដើមពោធិព្រឹក្ស..........................................១១១
៧.អានិសង្សបូជាផ្កា ៣ ទងចំពោះពោធិព្រឹក្ស.................................១១៣
៨.អានិសង្សរោយផ្កាឈើទៀបគល់ពោធិព្រឹក្ស.................................១១៤
៩.អានិសង្សថ្វាយសីហាសនៈ និងថ្វាយបង្គំដើមពោធិព្រឹក..................១១៦
១០.អានិសង្សបូជាប្រទីបដើមពោធិព្រឹក.........................................១១៧
១១.អានិសង្សបម្រើដើមពោធិព្រឹក...............................................១១៨
១២.អានិសង្សបោសសម្អាតទីលានដើមពោធិព្រឹក្ស..........................១២០
១៣.អានិសង្សរើសស្លឹកពោធិព្រឹក្សក្នុងលានព្រះចេតិយទៅចោល.......១២២
១៤.អានិសង្សធ្វើខឿនដើមពោធិព្រឹក្ស..........................................១២៨
១៥.អានិសង្សធ្វើខឿនពោធិព្រឹក្ស ថ្វាយដុំបាយអ និងបូកបាយអ.........១២៩
១៦.អានិសង្សលាបប្រេងត្រង់ខឿនដើមពោធិព្រឹក្ស........................១៣០
១៧.អានិសង្សថ្វាយក្បាច់អឌ្ឍចន្ទចំពោះពោធិព្រឹក្ស.........................១៣២
១៨.អានិសង្សកសាងកំពែងទៀបគល់ដើមពោធិព្រឹក្ស.....................១៣៣
១៩.អានិសង្សធ្វើខឿនដើមពោធិព្រឹក្ស..........................................១៣៥
២០.អានិសង្សពូនផែនដីជិតខឿនដើមពោធិព្រឹក្ស............................១៣៧
បំភ្លឺពាក្យមួយចំនួន..................................................................១៣៩

# ពុទ្ធចេតិយវន្ទនា

និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ
បដិមា ពោធិរុក្ខោ ច បាទា ច ជិនធាតុយោ
ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា
អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ ។

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមា (គឺឧទ្ទេសិកចេតិយ) ផង ដើមពោធិព្រឹក្ស (គឺបរិភោគចេតិយ) ផង ស្នាម-ព្រះបាទ (គឺបាទចេតិយ) ផង ព្រះជិនធាតុ (គឺធាតុ-ចេតិយ) ផង ព្រះធម៌ ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ (គឺធម្មចេតិយ) ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

ទូរតោហំ គារវេន វន្ទាមិ បញ្ចចេតិយំ
ធាតុធម្មុទ្ទេសក- បរិភោគបាទចេតិយំ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធចេតិយទាំងឡាយ ៥ យ៉ាង គឺៈព្រះធាតុចេតិយ (ព្រះសារីរិកធាតុទាំងឡាយ) ១ ព្រះធម្មចេតិយ(ព្រះធម៌ទាំង ៨៤,០០០ ព្រះធម្មក្ខន្ធ) ១ ព្រះឧទ្ទេសកចេតិយ (ព្រះពុទ្ធរូបទាំង-ឡាយ)១ ព្រះបរិភោគចេតិយ (ដើមពោធិព្រឹក្ស និងគ្រឿងបរិក្ខារផ្សេងៗ)១ ព្រះបាទចេតិយ (ស្នាមព្រះបាទទាំងឡាយ) ១, (ដែលស្ថិតនៅក្នុងជម្ពូទ្វីបក្តី លង្កាទ្វីបក្តី នាគទ្វីបក្តី ក្នុងទេវលោកក្តី ព្រហ្មលោកក្តី ដោយកាយវាចាចិត្ត សូម្បីក្នុងឥរិយាបថដេកក្តីអង្គុយក្តី ឈរក្តី ដើរក្តី) ដោយសេចក្តីគោរពអំពីចម្ងាយ ។





# ដើមពោធិព្រឹក្ស

## ជាបរិភោគចេតិយ





# ដើមពោធិព្រឹក្ស

ពោធិព្រឹក្ស គឺដើមឈើជាទីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ហើយក៏ជាចេតិយមួយ បណ្តាពុទ្ធចេតិយទាំង ៤ យ៉ាង មានឈ្មោះថា "បរិភោគចេតិយ" ពុទ្ធចេតិយទាំង ៤ យ៉ាងនោះ គឺ៖

១-ធាតុចេតិយ បានដល់ព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ, ទោះបីចេតិយដែលបញ្ចុះព្រះពុទ្ធរូបបាក់បែក ក៏ហៅថា ធាតុចេតិយដែរ។

២-ធម្មចេតិយ បានដល់ព្រះធម៌ទាំង៨៤,000ព្រះធម្មក្ខន្ធ ដែលចារឹកក្នុងគម្ពីរព្រះត្រៃបិដក និងគម្ពីរអដ្ឋកថា ដីកាជាដើម, ទោះបីធម្មមន្ទីរ មានបណ្ណាល័យ ហោត្រ័យ ឬទូដែលតម្កល់គម្ពីរព្រះធម៌ ក៏ហៅថា ធម្មចេតិយដែរ ។

៣-ឧទ្ទិស្សកចេតិយ ឬ ឧទ្ទេសិកចេតិយ បានដល់ព្រះពុទ្ធរូបដែលគេសាងឡើងតំណាងព្រះសម្មាសម្ពុទ្ធ ទោះគេធ្វើពីឈើ ឬលោហធាតុជាដើម សូម្បីគេគូនឹងសំពត់ដែលហៅថា ព្រះបដ ក៏ហៅថា ឧទ្ទិស្សកចេតិយដែរ។

៤- **បរិភោគចេតិយ** បានដល់ ដើមពោធិព្រឹក្ស និងចេតិយ ដែលបញ្ចុះគ្រឿងប្រើប្រាស់របស់ព្រះសម្មាសម្ពុទ្ធ មានបាត្រ ចីវរ ធម្មក្រក ជាដើម ។

៥- **បាទចេតិយ** គឺស្នាមព្រះបាទរបស់ព្រះពុទ្ធ ។

ក៏ពោធិព្រឹក្សនេះ មិនសំដៅចំពោះតែដើមឈើនោះមានឈ្មោះថាជាដើមពោធិ៍ពីកំណើតនោះទេ គឺទោះជាដើមឈើណាក៏ដោយ ឱ្យតែព្រះពោធិសត្វគង់អាស្រ័យក្រោមម្លប់ ហើយបានត្រាស់ជាព្រះពុទ្ធ លោកហៅថា "**ពោធិព្រឹក្ស**" ទាំងអស់។ ដូចជាពោធិព្រឹក្សរបស់ព្រះសម្មាសម្ពុទ្ធនៃយើងអ៊ីចឹង បើតាមឈ្មោះដើម ហៅថា "**អស្សត្ថព្រឹក្ស**" តែដោយហេតុដែលព្រះសក្យមុនីគោតម ទ្រង់បានត្រាស់ជាព្រះសម្ពុទ្ធក្រោមម្លប់នោះ ក៏ក្លាយឈ្មោះថា "**ពោធិព្រឹក្ស**" រៀងមក ។ និងនៅក្នុងគម្ពីរពុទ្ធវង្ស: បិដកលេខ ៧៧ និងអដ្ឋកថា ត្រង់វេមត្តកថា ក៏មានប្រាប់ឈ្មោះដើមឈើជាពោធិព្រឹក្សរបស់ព្រះពុទ្ធមុនៗ មានឈ្មោះផ្សេងៗ ពីគ្នា ដូច្នេះ គឺ:

**បិប្ផលិព្រឹក្ស** (ដើមលៀប), **សាលកល្យាណិព្រឹក្ស** (ដើម

សាលព្រឹក្ស), **នាគព្រឹក្ស** (ដើមខ្ទឹង), **អជ្ជុនព្រឹក្ស** (ដើមអង្គ្រង) **មហាសោណព្រឹក្ស** (ដើមម្រុម), **សលឡព្រឹក្ស** (ដើមស្រល់), **និម្ពព្រឹក្ស** (ដើមស្ដៅ), **មហាវេឡុព្រឹក្ស** (ដើមឫស្សីធំ, គឺឫស្សីមានដើមតែមួយ ដើមតាន់ មិនមានប្រហោង បែកមែកជា ៥ មានមែកត្រសុំត្រសាយ មានស្លឹកច្រើន ឥតបន្លា មានដើមត្រង់ជាឈើល្អដូចជាបាច់នៃកន្ទុយក្ងោកដែលគេចងល្អហើយ គួររមិលមើល ជាទីរីករាយនៃចិត្ត), **កកុធព្រឹក្ស** (ដើមថ្វាន់), **ចម្បកព្រឹក្ស** (ដើមចំប៉ា), **តិម្ពជាលព្រឹក្ស** (ដើមទម្លាប់), **កណ្ណិ-ការព្រឹក្ស** (ដើមកណ្ណិការ), **អសនព្រឹក្ស** (ដើមធ្នង់), **អាមលកព្រឹក្ស** (ដើមកន្ទួតព្រៃ), **បាដលិព្រឹក្ស** (ដើមច្រនៀង), **បុណ្ឌរីកព្រឹក្ស** (ដើមស្វាយស), **មហាសាលព្រឹក្ស** (ដើមមហា-សាលព្រឹក្ស), **សិរិសព្រឹក្ស** (ដើមច្រេស), **ឧទុម្ពរព្រឹក្ស** (ដើមល្វា), **និគ្រោធព្រឹក្ស** (ដើមជ្រៃ) ។

ក្នុងគម្ពីរផ្សេងៗ ក៏លោកបានពន្យល់អំពីពាក្យថា "**ពោធិ**" នេះដែរ ដូចមានសេចក្ដីខាងក្រោមនេះ ៖

ក្នុងគម្ពីរអភិធានវណ្ណនា ត្រង់គាថាទី ៥៥១ ថា:

សព្វញ្ញុតញ្ញាណំ ពុជ្ឈតិ ឯត្ថាតិ ពោធិ ។ ព្រះពុទ្ធទ្រង់ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណក្រោមដើមឈើនោះ ព្រោះហេតុនោះ ដើមឈើនោះ ឈ្មោះថា ពោធិ៍ ។

ក្នុងសុមង្គលវិលាសិនី អដ្ឋកថាមហាបទានសូត្រ ថា:

តេសុ យស្ស យស្ស រុក្ខស្ស មូលេ ចតុមគ្គញ្ញាណសង្ខាតំ ពោធឹ ពុទ្ធា បដិវិជ្ឈន្តិ សោ សោ ពោធីតិ វុច្ចតិ ។

ព្រះពុទ្ធទាំងឡាយ រមែងចាក់ធ្លុះនូវធម៌ជាគ្រឿងត្រាស់ដឹង ពោលគឺ មគ្គញ្ញាណ ៤ ក្រោមដើមឈើណាៗ ដើមឈើនោះៗ លោកហៅថា ពោធិ៍។

ក្នុងវិនយបិដក លេខ ៦ ទំព័រ ១ ត្រង់ពោធិកថាសម្ដែងថា:

តេន សមយេន ពុទ្ធោ ភគវា ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ... ។ សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់ត្រាស់ដឹងជាដំបូង ទ្រង់គង់នៅត្រង់គល់ពោធិព្រឹក្ស . . .។

ព្រះអដ្ឋកថាលោកពន្យល់ថា:

**ពោធិរុក្ខមូលេតិ ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ;**

តំ ពោធឹ ភគវា ឯត្ថ បត្តោតិ រុក្ខោបិ "ពោធិរុក្ខោ"ត្វេវ នាមំ លភិ, តស្ស ពោធិរុក្ខស្ស មូលេ ពោធិរុក្ខមូលេ ។

ពាក្យថា **ត្រង់គល់ពោធិព្រឹក្ស** (ពោធិរុក្ខមូលេ) សេចក្ដីថា ញាណនៅក្នុងមគ្គ ៤ លោកហៅថា ពោធិ, ព្រះមានព្រះភាគ ទ្រង់បានត្រាស់ដឹងនូវពោធិញាណនោះ ត្រង់គល់ដើមឈើនោះ ព្រោះហេតុនោះ ដើមឈើនោះ ទើបឈ្មោះថា ពោធិព្រឹក្សផង, ទៀបគល់នៃដើមពោធិព្រឹក្សនោះ ទើបឈ្មោះថា ពោធិរុក្ខមូល ផង ។

ក្នុងសារត្ថទីបនីដីកា ពន្យល់ថែមទៀតថា:

តទុភយម្បិ ពោធឹ ភគវា ឯត្ថ បត្តោតិ រុក្ខោបិ ពោធិរុក្ខោត្វេវ នាមំ លភិ ។ ព្រះមានព្រះភាគទ្រង់សម្រេចនូវ ពោធិញាណទាំង ២ នោះ ត្រង់ដើមឈើនោះ ព្រោះហេតុនោះ ទើបដើមឈើនោះមានឈ្មោះថា ពោធិព្រឹក្ស ។

តេន ពុទ្ធេន្តេន សន្និស្សិតត្តា សោ រុក្ខោ ពោធិ-រុក្ខោតិ នាមំ លភិ ។ រីដើមឈើនោះ រមែងបានឈ្មោះថា ពោធិព្រឹក្ស ព្រោះភាវនៃដើមឈើនោះ គឺព្រះមានព្រះភាគអង្គ

នោះ ទ្រង់គង់អាស្រ័យនៅហើយ ត្រាស់ដឹង ។

បណ្ដាសហជាតវត្ថុទាំង ៧ ដើមពោធិព្រឹក្សនេះ ក៏ជាសហជាតវត្ថុ គឺវត្ថុដែលកើតរួមក្នុងថ្ងៃជាមួយនឹងព្រះអង្គមួយផងដែរ។

*******

**មហយិត្វា សម្ពោធឹ នានាតុរិយេហិ វជ្ជមានេហិ**
**មាលាវិលេបនំ អភិហរិត្វា អថ រាជា មនុបាយាសិ ។**

ព្រះបាទកាលិង្គជ្រះថ្លានឹងពោធិមណ្ឌល ហើយនាំយកផ្កាកម្រង
និងគ្រឿងក្រអូប គ្រឿងលាប ព្រមទាំងតូរ្យតន្ត្រីទាំងឡាយ
ផ្សេងៗ ទ្រង់ឱ្យធ្វើកំពែងព័ទ្ធជុំវិញហើយទើបទ្រង់ចេញទៅ ។

**សដ្ឋិ វាហសហស្សានិ បុប្ផានំ សន្និបាតយិ**
**បូជេសិ រាជា កាលិង្គោ ពោធិមណ្ឌមនុត្តរំ ។**

ព្រះបាទកាលិង្គ បានឱ្យរាជបុរសបេះផ្កាឈើទាំងឡាយ
ចំនួនប្រាំមួយម៉ឺនរទេះ មកបូជាកន្លែងដាំដើមពោធិព្រឹក្ស
ដ៏ប្រសើរបំផុត (នោះ) ។

(អដ្ឋកថាកាលិង្គពោធិជាតក)

# ប្រវត្តិដើមពោធិព្រឹក្សនៅប្រទេសឥណ្ឌា








CEREMONY

# ប្រវត្តិដើមពោធិព្រឹក្សនៅពុទ្ធគយា

## (កន្លែងត្រាស់ដឹង)

តាមប្រវត្តិរឿងមហាពោធិព្រឹក្សនៅពុទ្ធគយា ដែលជាទីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធនោះ មានសេចក្ដីរៀបរាប់ថាៈ

ក្រោយពីព្រះពោធិសត្វធ្វើនូវទុក្ករកិរិយាអស់ ៦ វស្សានៅភ្នំដុង្គសិរិតំបន់ឧរុវេលានិគម កាលទ្រង់លះបង់ការធ្វើអត្តកិលមថានុយោគនោះហើយ ក៏ទ្រង់ប្រព្រឹត្តជាកណ្ដាលវិញ ដោយទ្រង់សោយចង្ហាន់ជាប្រក្រតី ។ ព្រះពោធិសត្វក្រោយពីបានទទួលមធុបាយាសពីនាងសុជាតា ទ្រង់សោយរួចហើយក៏ទ្រង់ធ្វើអធិដ្ឋានដោយបណ្ដែតភាជន៍ក្នុងស្ទឹងនេរញ្ជរា ហើយទ្រង់ឆ្លងស្ទឹងនេរញ្ជរានោះមកកាន់ពោធិមណ្ឌល ។ ក្នុងខណៈដែលព្រះអង្គយាងឆ្ពោះទៅកាន់ពោធិមណ្ឌល សោត្ថិយព្រាហ្មណ៍នៅជិតផ្លូវនោះកំពុងតែច្រូតស្មៅស្គា[១] ឃើញព្រះមហាសត្វហើយក៏

---

១-បាលីថា **កុស** ប្រែតាមទម្លាប់ថា "ស្បូវភ្លាំង" តែសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក **ជួន-ណាត** កាលនិមន្តទៅឥណ្ឌៀបានជ្រាបថា ស្មៅស្គា អ្នកឥណ្ឌៀហៅថា **កុសៗ** ដូច្នេះ **កុស** គួរប្រែថា "ស្មៅស្គា" វិញទើបត្រូវ ។ (ចាកប្រស្នាពុទ្ធប្រវត្តិ ទំព័រ ៧២ ដោយឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ)

ថ្វាយស្មៅស្គានោះ ៨ ក្តាប់ដល់ព្រះអង្គ។ ព្រះពោធិសត្វកាន់យកស្មៅនោះមកក្រាលគង់ក្រោមដើមពោធិ៍ ។ ក៏មហាពោធិ៍នេះជាសហជាតវត្ថុ ដែលកើតឡើងក្នុងថ្ងៃដែលព្រះពោធិសត្វទ្រង់ប្រសូត គឺមានអាយុដំណាលគ្នានឹងព្រះអង្គដែរ ។

សហជាតវត្ថុនោះ មាន ៧ គឺៈ

១-ព្រះនាងយសោធរាពិម្ពារ (រាហុលមាតា),

២-ព្រះអានន្ទពុទ្ធុបដ្ឋាក,

៣-កាឡុទាយីអាមាត្យ,

៤- ឆន្នអាមាត្យ,

៥-សេះកណ្ឋកៈ

៦-ដើមពោធិព្រឹក្ស,

៧-កំណប់ទ្រព្យទាំង ៤។

ព្រះពោធិសត្វ យកស្មៅស្គាទៅក្រាលជិតគល់ពោធិព្រឹក្សនាទិសខាងកើត ទ្រង់គង់ប្រថាប់ហើយតាំងសច្ចាធិដ្ឋានយ៉ាងអង់-អាចប្រកបដោយអង្គ ៤ ថាៈ

កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ

ឧបសុស្សតុ និស្សេសំ សរីរេ មំសលោហិតំ(១)។
សូមឱ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់
ឈាមក្នុងសរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីង
ស្ងួតទៅចុះ ។

បើអាត្មាអញមិនបានត្រាស់ដឹងទេ នឹងមិនក្រោកចេញពីរតនបល្ល័ង្កនេះឡើយ។ ក្នុងថ្ងៃពេញបូណ៌មី វិសាខមាសនក្ខត្តសម័យនៃរាត្រីនោះ ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ សម្រេចភាវជាព្រះសម្មាសម្ពុទ្ធ ជាកំពូលមុជក្នុងលោក។ ហើយក៏ព្រះអង្គទ្រង់គង់ប្រថាប់សោយវិមុត្តិសុខលើបល្ល័ង្ក ទៀបគល់ពោធិព្រឹក្សនេះអស់៧ ថ្ងៃ ទើបទ្រង់ក្រោកចាករតនបល្ល័ង្កយាងទៅឈរនៅទិសខាងកើត សម្លឹងមើលមហាពោធិព្រឹក្សដោយមិនប្រប្រិចព្រះនេត្រអស់ ៧ ថ្ងៃ ។ មហាពោធិព្រឹក្សនេះ គឺជាដើមពោធិ៍ទី ១ ជាទីជ្រះថ្លាគោរពបូជារបស់មហាជនពុទ្ធសាសនិក និងជាបូជនីយដ្ឋានទី ២ ដែលព្រះអង្គសម្តែងទុកក្នុង

---

១-អស្សាជានីយសូត្រ អង្គុត្តរនិកាយ អដ្ឋកនិបាត បិដកលេខ ៤៨ ទំព័រ ៧៤។

មហាបរិនិព្វានសូត្រ គម្ពីរទីឃនិកាយ ។ ហើយក៏ជាកន្លែងដែលមានមហាជនមកគោរពបូជាច្រើនជាងគេ បណ្ដាបូជនីយដ្ឋានទាំង ៤ គឺ **លុម្ពិនី** (កន្លែងប្រសូត), **ពុទ្ធគយា** (ពោធិបល្ល័ង្កកន្លែងត្រាស់ដឹង), **ព្រៃឥសិបតនមិគទាយវ័ន** (កន្លែងសម្ដែងព្រះធម្មចក្ក), និង**កុសិនារា** (កន្លែងបរិនិព្វាន)។ ចំណេរកាលតមក បឋមពោធិ៍នេះមានអាយុបាន ៣៥២ ឆ្នាំ មកដល់រជ្ជកាលព្រះបាទធម្មាសោក ។ មហាពោធិ៍ទី ១ នេះ ស្លាប់ដោយស្នាដៃនៃអគ្គមហេសីទី ៤ របស់ព្រះរាជាអង្គនេះឯង ដោយសេចក្ដីច្រណែនចំពោះមហាពោធិ៍។

ក្នុងសម័យពុទ្ធស័ករាជ ២១៨ ឆ្នាំ ព្រះបាទអសោកមហារាជ ឡើងគ្រងរាជសម្បត្តិ ដឹងនាំប្រទេសប្រកបដោយធម៌ ក្រោយអំពីព្រះថេរៈមោគ្គលីបុត្តតិស្សត្ថេរ ញុំាងព្រះរាជាឱ្យមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ឧបត្ថម្ភព្រះពុទ្ធសាសនាឱ្យរុងរឿង ព្រះអង្គបានឱ្យសេនាមាត្រ កសាងមហាវិហារនៅជុំវិញមហាពោធិព្រឹក្ស និងកំពែងការពារជុំវិញព្រះស្រីមហាពោធិព្រឹក្ស។

ក្នុងរជ្ជកាលរបស់ព្រះបាទអសោកមហារាជ ព្រះពុទ្ធសាសនារីកចម្រើនផ្សព្វផ្សាយទូលំទូលាយទូទាំងទ្វីបអាស៊ី ព្រះរាជាមានសទ្ធាមុះមុតក្នុងព្រះពុទ្ធសាសនា បានឱ្យព្រះរាជបុត្រពីរព្រះអង្គបួសក្នុងព្រះពុទ្ធសាសនា បានជាអរហន្តខីណាស្រព គឺ ព្រះមហិន្ទត្ថេរ និងព្រះសង្ឃមិត្តាថេរី ឯកសារជាវត្ថុសម្គាល់មាននៅសល់គ្រប់ទីកន្លែងក្នុងប្រទេសឥណ្ឌា ។ ព្រះអង្គបានកសាងសាសនវត្ថុជាច្រើន ហើយព្រះអង្គបានចាប់អារម្មណ៍ជាងគេ ពេញព្រះទ័យត្រង់ទីកន្លែងត្រាស់ដឹង ព្រះអង្គតែងមកគោរពបូជា អង្គុយសមាធិរៀងរាល់សប្តាហ៍ មិនដែលខានឱ្យគេសម្អាតរក្សាមហាពោធិព្រឹក្ស មានពេលខ្លះព្រះអង្គប្រគល់រាជកិច្ចឱ្យពួកមន្ត្រីសេនាធ្វើកិច្ចការជំនួសព្រះអង្គ ហើយព្រះអង្គយាងមកគង់ប្រថាប់នៅព្រះរាជដំណាក់ជិតមហាពោធិព្រឹក្ស ពុទ្ធគយាចំនួន ១ សប្តាហ៍ខ្លះ ២ សប្តាហ៍ខ្លះ ទ្រង់អង្គុយសមាធិនៅក្រោមមហាពោធិព្រឹក្សជារៀងរាល់ទិវារាត្រី ។ ដោយព្រះអង្គយកព្រះទ័យទុកដាក់គោរពបូជាចម្រើនកម្មដ្ឋាន នៅក្រោមម្លប់ពោធិព្រឹក្ស មិនសូវរវល់នឹងកិច្ចក្នុងព្រះរាជវាំងឡើយ ធ្វើឱ្យ

ព្រះអគ្គមហេសីឈ្មោះ "មហីសុន្ទរី ឬហៅថា តិស្សរក្ខិតា" ។ មហេសីអង្គទី ៤ ទ្រង់តូចព្រះទ័យ មិនសប្បាយចិត្តដោយព្រះរាជាមិនសូវរវីរវល់ ទ្រង់គិតតែពីធ្វើបុណ្យ ធ្វើសមាធិ។

គ្រាដំបូង ព្រះនាងប្រើនាងស្នំឈ្មោះ នគរា ទៅទូលព្រះរាជាឱ្យយាងត្រឡប់មកព្រះរាជវាំងវិញ តែព្រះរាជាពុំយកព្រះទ័យស្ដាប់ការទូលរបស់នាងស្នំ ព្រះអង្គគិតតែពីការអង្គុយចម្រើនកម្មដ្ឋាន ធ្វើឱ្យនាងស្នំ នគរាក្រោធខឹងជាខ្លាំង ហើយត្រឡប់មកទូលពិតព្រះនាងមហីសុន្ទរី ដោយសព្វគ្រប់ ធ្វើឱ្យនាងមហីសុន្ទរីក្រោធខ្ញាល់មិនសប្បាយព្រះទ័យ ចងកម្មពៀរនឹងដើមពោធិព្រឹក្ស។ តមកព្រះនាងបានបញ្ជាឱ្យនាងស្នំឈ្មោះនគរាធ្វើការជិតស្និទ្ធបម្រើព្រះរាជា លបលួចយកថ្នាំពុលខ្ចប់ដាក់ជាប់នឹងខ្លួន ចូលទៅបម្រើព្រះរាជាក្នុងបរិវេនពោធិមណ្ឌល ស្រីស្នំនោះ ធ្វើអាកប្បកិរិយាហាក់ដូចជាខ្លួនជ្រះថ្លានឹងមហាពោធិ-ព្រឹក្សណាស់ ដើរប្រទក្សិណមហាពោធិព្រឹក្ស ។ ខណៈដែលព្រះរាជាគង់ប្រថាប់ចម្រើនកម្មដ្ឋានបិទព្រះនេត្រហើយ បាននិ-កាសស្រីស្នំចិត្តអប្រីយ៍ យកថ្នាំពុលលាយនឹងទឹកក្ដៅចាក់ស្រោច

តាមគល់តាមឫសច្រើនដង នៅពេលដែលនាងមកបម្រើព្រះរាជាក្នុងពោធិមណ្ឌល ។ មិនជាប៉ុន្មានថ្ងៃ ដើមមហាពោធិព្រឹក្សដែលមានអាយុកាល ៣៩២ ឆ្នាំមកហើយនោះ ត្រូវជាតិពុលក៏ស្វិតស្រពោនជ្រុះស្លឹកស្លាប់ក្នុងពេលនោះទៅ ដោយស្នាដៃឥស្សារបស់នាងមហីសុន្ទរី។ ព្រះបាទអសោកមហារាជ ទតឃើញព្រះស្រីមហាពោធិព្រឹក្សមានភាពមិនប្រក្រតី ស្វិតស្រពោនជ្រុះស្លឹកដូច្នោះ ក៏មានព្រះទ័យទោមនស្សតូចព្រះទ័យ គិតថា "នេះជាបាបកម្មរបស់អាត្មាអញទេដឹង បានជាមហាពោធិព្រឹក្សស្លាប់ដូច្នេះ" ។ ព្រះរាជាទ្រង់ត្រឡប់មកកាន់ព្រះរាជវាំងវិញ ។ ព្រះនាងមហីសុន្ទរី ឃើញព្រះរាជាទ្រង់ត្រឡប់មកកាន់ព្រះរាជវាំងវិញ មានចិត្តត្រេកអរណាស់ ព្រោះជាផលសម្រេចសមតាមសេចក្ដីប្រាថ្នារបស់នាង ដែលបានឱ្យនាងនគរាយកថ្នាំពិសទៅដាក់រោយសម្លាប់ដើមពោធិព្រឹក្ស តែព្រះរាជាទ្រង់មានព្រះទ័យកើតទុក្ខកង្វល់ទោមនស្ស មិនរីករាយព្រះទ័យ ដោយនឹកដល់ព្រះមហាពោធិ៍ដែលស្លាប់ ដោយមិនដឹងមូលហេតុក្រៀមក្រំព្រះទ័យ ទ្រង់ផ្ទុំសញ្ជប់សញ្ជឹងដល់បាបកម្មរបស់ខ្លួន

ដែលព្រះអង្គបានធ្វើពីកាលមុន បានជាមហាពោធិព្រឹក្សស្លាប់ ដោយឆាប់រហ័សដូច្នេះ ព្រះរាជាមានកង្វល់យ៉ាងខ្លាំង ធ្វើឱ្យព្រះកាយពលស្រុតចុះ ទ្រង់ព្រះប្រឈួន កើតខ្យល់វិលមុខ ទ្រង់ដួលទាំងជំហរសន្លប់ព្រះស្មារតី ។ ខណៈនោះ ព្រះនាងមហីសុន្ទរី ឃើញហេតុការណ៍ដូច្នោះ ក៏ស្ទុះមកលើកត្រកងព្រះរាជស្វាមី ដោយអាការៈភ័យតក្កមា ព្រះនាងទ្រង់ត្រកងព្យាបាលដោយព្រះអង្គឯង រហូតដល់ព្រះរាជាមានស្មារតីឡើងវិញ ។ ទើបព្រះនាងគិតថា បើអាត្មាអញមិនប្រាប់រឿងពិតដល់ព្រះអង្គទេ ប្រាកដជាព្រះរាជស្វាមីទ្រង់ទីវង្គតយ៉ាងពិតប្រាកដ ព្រោះព្រះអង្គមិនសប្បាយព្រះទ័យសោះ។ ខណៈនោះ ព្រះនាងក្រាបបង្គំទូលតាមរឿងពិតអំពីរឿងមហាពោធិព្រឹក្សត្រូវស្លាប់ ដោយសារស្នាដៃនាងដោយសព្វគ្រប់ ។

ព្រះរាជាកាលបានដឹងរឿងពិតនោះហើយ ក៏ទ្រង់មានព្រះទ័យធូរស្បើយឡើងវិញ ដោយពុំបានយកទោសពៃរ៍ដល់ព្រះនាង និងនាងស្នំឡើយ ទើបព្រះរាជាវិលត្រឡប់ទៅកាន់ពោធិមណ្ឌលវិញ បញ្ជាឱ្យទាហានសេនាមាត្យសម្អាតត្រង់គល់

ពោធិព្រឹក្សដែលស្លាប់នោះ ធ្វើដីឱ្យស្អាតឡើងវិញ ហើយឱ្យយកទឹកដោះគោបរិសុទ្ធស្អាតចំនួន ១០០ មេ មកស្រោចត្រង់កន្លែងដើមពោធិ៍ដែលស្លាប់នោះ ហើយព្រះអង្គប្រថាប់ចម្រើនកម្ម-ដ្ឋានតាំងសច្ចាធិដ្ឋានថា "បើមិនមានដើមពោធិ៍ដុះ មានពន្លកកើតឡើងត្រង់កន្លែងនេះទេ ព្រះអង្គនឹងមិនក្រោកចេញពីទីនេះឡើយ ព្រះអង្គថ្វាយបូជាជីវិតក្នុងទីនេះ"។ គួរឱ្យអស្ចារ្យមែន ក្នុងរយៈពេលតែ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏មានត្រួយដុះចេញមកនៅទ្រង់កន្លែងដើមនោះឯង ព្រះរាជាបានទតឃើញហើយ មានព្រះទ័យសប្បាយសោមនស្សរីករាយជាខ្លាំង ត្រាស់បញ្ជាកងសេនាទាហានឱ្យធ្វើកំពែកការពារ មិនឱ្យអ្នកណាចេញចូលរហេតរហូតដោយគ្មានការអនុញ្ញាត និងត្រួតពិនិត្យយ៉ាងតឹងរឹង ។ មហាពោធិព្រឹក្សដើមទី ១ នេះ មានអាយុបាន ៣៥២ ឆ្នាំ គឺព្រះពុទ្ធបរិនិព្វានកន្លងទៅបាន ២៧២ វស្សា[១]។

---

១-យោងតាមន័យក្នុងគម្ពីរមហាវង្ស ត្រង់បរិច្ឆេទទី ២០ ឱ្យដឹងថា ដើមពោធិ៍ទី១ នេះស្លាប់ក្នុងឆ្នាំទី ៣៧ នៃការគ្រងរាជ្យរបស់ព្រះបាទធម្មាសោក ត្រូវនឹងព.ស. ២៥៥ ឆ្នាំ គឺព្រះអង្គទ្រង់គ្រងរាជ្យក្នុងព្រះជន្មាយុ ៥៤ ឆ្នាំ ត្រូវនឹងព.ស.២១៨ ទ្រង់សោយរាជ្យបាន ៣៧ គត់ ដូច្នេះដើមពោធិ៍ទី ១ នេះ មានអាយុ ៣៣៥ ឆ្នាំ (គិតពីពោធិ៍កើតដល់ស្លាប់ ២៥៥+៨០= ៣៣៥) ។

ដើមពោធិ៍ទី ១ នេះ មានតំណពូជ ២ កន្លែង គឺៈ

**១- ព្រះអានន្ទបានយកគ្រាប់ទៅដាំនៅមុខទ្វារវត្តជេតពន ក្រោយអំពីចេញវស្សាទី ១០ ហើយ ។**

**២- ព្រះនាងសង្ឃមិត្តាថេរី បានអារាធនាមែកទៅដាំង តម្ពបណ្ណិទ្វីប (ប្រទេសស្រីលង្កា) ក្នុងពុទ្ធសករាជ ២៣៦ ក្រោយអំពីព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ ។**

# ដើមពោធិ៍ទី ២

ពន្លកត្រួយខ្ចីនៃពោធិព្រឹក្ស ដែលព្រះរាជាអសោកមហារាជព្យាយាមថែរក្សាដោយយកព្រះទ័យទុកដាក់ មានទាហាននៅយាមការពារទាំងថ្ងៃទាំងយប់ ។ មហាពោធិព្រឹក្សដើមទី ២ នេះ មានការចម្រើនលូតលាស់ល្អជាទីគោរពបូជារបស់ព្រះបាទអសោកមហារាជ ហើយក៏ជាទីជ្រះថ្លានៃមហាជនដែរ គឺមានពុទ្ធបរិស័ទមកពីទីជិតឆ្ងាយគ្រប់រដ្ឋក្នុងប្រទេសឥណ្ឌាក្នុងសម័យនោះ ចូលមកគោរពបូជាយ៉ាងច្រើនទាំងថ្ងៃទាំងយប់ ។ ក្នុង

ខេត្តគយាសីសៈប្រទេស តំបន់ពុទ្ធគយានេះ សាសនាដទៃសាបសូន្យអន់ថយ មិនមានលាភសក្ការៈ មិនមានបរិស័ទគោរពជឿតាម គឺម្នាក់ៗ មានមុខឆ្ពោះមកកាន់បរិវេណពោធិមណ្ឌលធ្វើការបដិបត្តិបូជានិងអាមិសបូជា។

សម័យនោះ ព្រះពុទ្ធសាសនាផ្សព្វផ្សាយទូលំទូលាយគ្រប់ទិសទីក្រោមការរាជូបត្ថម្ភរបស់ព្រះរាជាក្នុងដែនមគធៈ មហា-ពោធិព្រឹក្សនេះចម្រើនរុងរឿងមកដល់ពុទ្ធសតវត្សទី ១១ គឺក្នុងពុទ្ធសករាជ ១,១៦៣ មានភាពរីកវរឥស្សានឹងមហាពោធិព្រឹក្ស ។ មានព្រះរាជាមួយព្រះអង្គ ព្រះនាមសាសង្កា ផ្នែកសាសនាហិណ្ឌូ (សាសនាព្រាហ្មណ៍) នៅរដ្ឋបេង្គាល ភាគខាងកើតនៃប្រទេសឥណ្ឌាបច្ចុប្បន្ន ប្រកាសខ្លួនជារដ្ឋឯករាជ្យ មិនចំណុះជាមួយព្រះបាទ បុរណៈវរមា មគធរដ្ឋតទៅទៀត ។ បានប្រមូលកងទ័ពរាប់ពាន់នាក់ ចូលមកកាន់បរិវេណពោធិមណ្ឌលដោយក្រោធខឹងនឹងមហាពោធិព្រឹក្ស ដែលធ្វើឱ្យសាសនារបស់ខ្លួនសាបសូន្យនៅក្នុងតំបន់ពុទ្ធគយានេះ បានបញ្ជាឱ្យសេនាទាហានកម្ទេចបំផ្លាញដើមមហាពោធិព្រឹក្ស ដែលមានអាយុ

បាន ៨៩១ ឆ្នាំ កាប់ចិញ្ច្រាំមែកស្លឹក ជីកកកាយយកឫសមកដុត ឱ្យទៅជាផេះធ្យូង ដុតបំពក់នៅត្រង់រណ្ដៅដែលជីកកកាយយក ឫសដោយចិត្តឫស្សា ក្រោធខឹងនឹងមហាពោធិព្រឹក្សដោយ បំណងថាឱ្យផុតពូជពោធិព្រឹក្ស មិនឱ្យកើតឡើងបានតទៅទៀត នៅក្នុងទីនេះ បានបញ្ជាឱ្យកងទាហានបំផ្លាញមហាវិហារនៅជុំ វិញដើមពោធិព្រឹក្ស និងនៅក្នុងតំបន់ពុទ្ធគយាទាំងមូល បញ្ជាឱ្យ បំផ្លាញវត្ត បំផ្លាញវិហារ បំផ្លាញព្រះពុទ្ធបដិមាទាំងឡាយក្នុងទី នោះ មានព្រះពុទ្ធរូប ១ អង្គទ្រង់មារវិជ័យ ព្រះពុទ្ធរូបអង្គធំ នេះគ្រាន់តែនៅក្នុងមហាវិហារជិតមហាពោធិព្រឹក្ស ព្រះបាទ សាសង្កា បញ្ជាឱ្យសេនាបតី (មេទ័ព) មួយរូប មាននាមមិន ប្រាកដ យកព្រះពុទ្ធរូបនេះចេញពីមហាវិហារជិតដើមពោធិ-ព្រឹក្ស ។ សេនាបតីនោះ បានទទួលព្រះរាជបញ្ជាហើយ ក៏ទៅ ពិនិត្យមើលព្រះពុទ្ធរូបក្នុងមហាវិហារ ព្រះពុទ្ធរូបនោះឆ្លាក់ពីថ្ម ស្អាត ដោយសេនាបតីនោះជាអ្នកជ្រះថ្លា គោរពព្រះពុទ្ធសាសនា ដោយមានចិត្តស្លុតសង្វេគ គិតពិចារណាថា "បើអាត្មាអញមិន ធ្វើតាមបញ្ជាស្ដេចរូបនេះទេ ករបស់អញនឹងត្រូវដាច់ តែបើ

អញធ្វើតាម ដោយបាបកម្មដ៏ធ្ងន់នេះអាត្មាអញនឹងមិនជួប មិនបានឃើញព្រះពុទ្ធអរិយមេត្តិយ ដែលនឹងបានត្រាស់ដឹងក្នុងកាលអនាគតដោយពិត"។ សេនាបតីនោះ គិតពិចារណាមួយសន្ទុះរកវិធីលាក់ទុកក្នុងទីនោះកុំឱ្យព្រះរាជារូបនេះដឹង ហើយក៏ប្រញាប់ប្រញាល់ចូលទៅគាល់ព្រះរាជាវិញ ហើយក្រាបបង្គំទូលថា "ទេវ! បពិត្រព្រះសម្មតិទេពជាអម្ចាស់ ព្រះអង្គមានព្រះរាជបញ្ជាឱ្យខ្ញុំព្រះអង្គយកព្រះពុទ្ធរូបក្នុងវិហារនោះ ចេញក្នុងខណៈនេះភ្លាមមិនទាន់ទេ ព្រោះព្រះពុទ្ធរូបអង្គនេះធំ សូមព្រះរាជទានឱកាសបាន ៧ ថ្ងៃសិន ដើម្បីខ្ញុំព្រះអង្គរកកម្លាំងនាំចេញលុះត្រាតែបាន" ។ ព្រះរាជាក៏ទ្រង់អនុញ្ញាតតាមការស្នើសុំរបស់សេនាបតី។

សេនាបតីនោះ បានចាត់ចែងឱ្យអ្នកក្រោមបញ្ជាដែលជិតស្និទ្ធឱ្យធ្វើជាកំពែងបូកដីឥដ្ឋបិទឱ្យជិត មិនឱ្យអ្នកណាដឹង ហើយអុជប្រទីបបំភ្លឺទុកក្នុងរូងគុហានោះ ។ រួចស្រេចហើយទើបចូលទៅក្រាបទូលព្រះរាជាវិញថា ខ្លួនបានចាត់ចែងយកព្រះពុទ្ធរូបនោះចេញហើយ ។ ព្រះរាជាបានស្តាប់ឮហើយ គួរតែ

ត្រេកអររីករាយ ព្រោះសេចក្ដីប្រាថ្នារបស់ព្រះអង្គបានសម្រេចហើយ តែមួយរំពេចនោះ ព្រះរាជាអង្គនោះបែរជាក្អួតឈាមដាច់ខ្យល់ទីវង្គតក្នុងពេលនោះ ព្រោះតែអំពើបាបកម្មរបស់ខ្លួនដោយបន្សល់ទុកនូវកងសេនាទាហាននៅប្រចាំ ក្នុងទីតាំងដែលខ្លួនវាយយកបាន ។ តែមិនយូរប៉ុន្មានការរឹកវរនេះ បានជ្រាបដំណឹងដល់ព្រះបាទបុរណៈវរមា មគធរដ្ឋ ទ្រង់បញ្ជាសេនាបតីឱ្យនាំពលយោធាមកឡោមព័ទ្ធ វាយកម្ទេចទាហានរបស់ព្រះបាទសាសង្កា ដែលមកបៀតបៀនព្រះមហាពោធិព្រឹក្ស ទ្រង់វាយកម្ចាត់រត់បាក់ទ័ព បោសសម្អាតអ្នកដែលមកប្រទូសរាយនឹងព្រះពុទ្ធសាសនា ។

កងទ័ពរបស់ព្រះបាទបុរណៈវរមា មគធរដ្ឋ បានកាន់កាប់ទាំងស្រុងក្នុងតំបន់គយាសីសៈ និងពុទ្ធគយា ព្រះអង្គយាងទៅពិនិត្យមើលនៅពោធិមណ្ឌល និងបរិវេណជុំវិញពុទ្ធស្ថានមហាពោធិព្រឹក្ស តើមានបាត់បង់ខូចខាតអ្វីខ្លះ ។ ព្រះអង្គទតឃើញមហាពោធិព្រឹក្សត្រូវបំផ្លាញអស់មិនមានសល់ សូម្បីតែឫសមួយកំណាត់ក៏មិនមានសេសសល់ គាស់កកាយជារណ្ដៅផុត

បំផ្លាញទៅជាផេះធ្យូងអស់។ ព្រះរាជាទ្រង់សង្វេគសោកស្ដាយជាខ្លាំងទ្រង់ព្រះរាជបញ្ជាទៅសេនាបតីយោធា និងប្រជាករនៅជុំវិញពុទ្ធគយា ឱ្យនាំគ្នារឹតយកទឹកដោះគោចំនួន ១,០០០ ក្បាលមកចាក់ស្រោចក្នុងរណ្ដៅកន្លែងគល់ពោធិព្រឹក្សចាស់ និងជុំវិញទ្រង់បញ្ជាឱ្យរៀបចំទីកន្លែងឱ្យស្អាតឡើងវិញ ហើយព្រះអង្គទ្រង់គង់ប្រថាប់នៅចំពោះមុខ កន្លែងមហាពោធិព្រឹក្សចាស់នោះហើយតាំងសច្ចាធិដ្ឋានថា "បើមិនមានមហាពោធិព្រឹក្ស មានពន្លកដុះឡើងក្នុងទីនេះទេ ខ្ញុំព្រះអង្គនឹងមិនគេចចេញពីទីនេះជាដាច់ខាត ស៊ូថ្វាយបូជាជីវិតក្នុងទីនេះ"។ ព្រះរាជាទ្រង់គង់ចម្រើនមេត្តាភាវនានៅពោធិមណ្ឌលនេះ មិនយូរប៉ុន្មាន ដោយអំណាចសច្ចាធិដ្ឋាននិងបារមីនៃពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ ពោធិព្រឹក្សក៏មានចេញពន្លកមួយដើមត្រង់កន្លែងចាស់ ។ គួរឱ្យអស្ចារ្យណាស់ ព្រះរាជាទ្រង់ទតឃើញហើយ មានព្រះទ័យសោមនស្សរីករាយជាអតិបរមា ទ្រង់បញ្ជាឱ្យកងទាហានធ្វើមហាកំពែងព័ទ្ធជុំវិញដើមពោធិ៍ យាមការពារត្រួតត្រាមើលមនុស្សចេញចូលដោយល្អ មិនឱ្យមានមនុស្សចូលទៅព្យាបាទ

បាន ។ មហាពោធិព្រឹក្សដើមទី ២ នេះ មានអាយុកាលបាន ៨៩១ ឆ្នាំ ពុទ្ធសករាជ ១,១៦៣ វស្សា ។

## ដើមពោធិ៍ទី ៣

ដើមពោធិព្រឹក្សទី ៣ ដែលបានដុះឡើងដោយអំណាចនៃសច្ចាធិដ្ឋានរបស់ព្រះរាជាបុរណៈវរមា ក្នុងពុទ្ធសករាជ ១,១៦៣ នេះ ព្រះអង្គបានថែរក្សានិងចម្រើនលូតលាស់ជាលំដាប់ច្រើនតំណវង្ស ដែលពុទ្ធបរិស័ទជួយថែទាំ មិនមានអ្នកបៀតបៀន មានអាយុវែង បានមកដល់ពុទ្ធសករាជ ២,៤២១ មានអាយុប្រមាណ ១,២៥៨ ឆ្នាំ ទើបស្លាប់ដោយចាស់ទ្រុឌទ្រោម និងត្រូវខ្យល់ព្យុះបក់បោកត្រូវ ។ តាមឯកសារនៅពុទ្ធគយាប្រាប់ថា មានជនជាតិអង់គ្លេសម្នាក់ ជាអ្នកជំនាញការខាងផ្នែកបុរាណវត្ថុ ឈ្មោះឧត្តមសេនីយ៍ ហ្សឺរ៍នឹងខាន់ហែម មកកាន់ប្រទេសឥណ្ឌា ៣ លើក បានមកពិនិត្យមើលនៅពោធិមណ្ឌលពុទ្ធគយា លើកទី១ក្នុងឆ្នាំ ព.ស.២,៤១៥, លើកទី ២ ក្នុងឆ្នាំព.ស.២,៤១៨ បានឃើញមហាពោធិព្រឹក្សនេះចាស់ទ្រុឌទ្រោមណាស់ មាន

មែកបាក់ មែកងាប់ ស្លឹកជ្រុះច្រើកន្លែង ហើយលោកឧត្តមសេនីយ៍រូបនេះ មកពុទ្ធគយាជាលើកទី៣ ក្នុងឆ្នាំ ព.ស.២,៤២១ បានឃើញមហាពោធិព្រឹក្សនេះ ត្រូវស្លាប់ដោយខ្យល់ព្យុះបោកបក់ត្រូវ ក៏មានគំនិតចង់ដាំឡើងវិញ ក៏ធ្វើសំណុំរឿងទៅរដ្ឋាភិបាលឥណ្ឌាក្នុងខេត្តគយានេះរុះរើគាស់កកាយដាំឡើងវិញ។

ដើមមហាពោធិព្រឹក្សទី ៣ នេះ មានអាយុបាន១,២៥៨ ឆ្នាំ។

# ដើមពោធិ៍ទី ៤

(ពោធិព្រឹក្សដើមបច្ចុប្បន្ន)

ពោធិព្រឹក្សដើមទី ៤ នៅពុទ្ធគយាបច្ចុប្បន្ននេះ ក្រោយពីលោកឧត្តមសេនីយ៍ ហ្សីរ៍នឹងខាន់ហែម ពិនិត្យឃើញដើមពោធិ៍ទី ៣ អស់អាយុហើយលោកឧត្តមសេនីយ៍ ខំដើររកគ្រាប់ពោធិព្រឹក្សនៅជុំវិញដើមពោធិព្រឹក្ស ដើម្បីយកមកបណ្តុះ ជាភ័ព្វសំណាងល្អ បានរកឃើញកូនពោធិ៍ដុះពន្លកដល់ទៅ ២ ដើម មួយដើមមានកម្ពស់ ៦ ធ្នាប់ មួយដើមទៀតកម្ពស់ ៤ ធ្នាប់, ហើយក៏សុំការអនុញ្ញាតពីរដ្ឋាភិបាលខេត្តគយាសីសៈ គាស់

កកាយដើមពោធិ៍ចាស់ដែលអស់អាយុហើយនោះ ធ្វើទីដីឱ្យស្អាតឡើងវិញ ហើយយកកូនពោធិ៍ដែលមានកម្ពស់ ៦ ផ្អាប់មកដាំត្រង់កន្លែងចាស់ដូចដើម មួយដើមទៀត គាត់យកទៅដាំនៅទិសឦសាននៃពោធិព្រឹក្សរតនបល្ល័ង្កចម្ងាយប្រមាណ ៥០ ម៉ែត្រ ដោយគាត់យល់ថាទីនោះជាអនិមិសក្រចេតិយដ្ឋាន កន្លែងដែលព្រះពុទ្ធទ្រង់សម្លឹងមើលដើមពោធិ៍អស់ ៧ ថ្ងៃ ។ តែតាមការពិតអនិមិសក្រចេតិយដ្ឋាននៅទិសខាងកើតមហាពោធិព្រឹក្សទេ។

មហាពោធិព្រឹក្សដើមបច្ចុប្បន្ននេ តាំងពីឆ្នាំ ព.ស.២,៤២១ មកដល់ឆ្នាំ ព.ស. ២,៥៦៣ (គ.ស. ២០២០)នេះ មានអាយុបាន ១៤២ ឆ្នាំហើយ ។ មហាពោធិព្រឹក្សនេះបានចម្រើនលូតលាស់ល្អ ដោយភ្នាក់ងារថៅនាទីថែរក្សាយកចិត្តទុកដាក់ សព្វថ្ងៃមហាពោធិព្រឹក្សទី ៤ នេះ មានទំហំដើម ៣ ឱប កម្ពស់ ៨០ ហ្វុន (២៥ ម៉ែត្រ) ។ ក្រោមកិច្ចការការពាររបស់រដ្ឋាភិបាលរដ្ឋពិហារនិងមន្ត្រីខេត្តគយាសីសៈ បានធ្វើកំពែងព័ទ្ធជុំវិញ អ្នកចូលទៅនមស្ការត្រូវសុំអនុញ្ញាតទើបចូលទៅបាន ជាពិសេសប្រជាជនឥណ្ឌាចេញចូល ថៅនាទីត្រួតពិនិត្យតឹងរឹងជាងគេព្រោះខ្លាច

យកវត្ថុមានជាតិពិសទៅដាក់ដោយចិត្តឥស្សានឹងដើមពោធិ៍ តែបើចំពោះជនបរទេសវិញ ចេញចូលទៅនមស្ការបានដោយស្រួល ។ រដ្ឋាភិបាលក្នុងខេត្ត តែងឱ្យមានគណៈកម្មការជាអ្នកជំនាញការផ្នែករុក្ខជាតិ និងជីវសាស្ត្រមកត្រួតពិនិត្យមើលនៅជុំវិញគល់ពោធិព្រឹក្សជារៀងរាល់សប្តាហ៍ ការពារមិនឱ្យមានជាតិពុលនៅជុំវិញពោធិព្រឹក្សឡើយ ដោយប្រាថ្នាចង់ឱ្យមហាពោធិ-ព្រឹក្សនេះមានអាយុវែងបំផុត ព្រោះមានផលល្អដល់ប្រទេសឥណ្ឌា ផ្នែកសេដ្ឋកិច្ច គឺពុទ្ធសំវេជនីយដ្ឋានធំទាំង ៣ នៅប្រទេសឥណ្ឌា គឺកន្លែងត្រាស់ដឹង១, កន្លែងសម្តែងធម្មចក្រ១ និងកន្លែងបរិនិព្វាន១ ហើយកន្លែងត្រាស់ដឹងនៅពុទ្ធគយានេះមានអ្នកទេសចរណ៍បរទេសចេញចូលច្រើនជាងគេ។

(ដកស្រង់និងសម្រួលសេចក្តីចាកសៀវភៅ ប្រវត្តិស្រីមហាពោធិព្រឹក្សនៅពុទ្ធគយា របស់ភិក្ខុ **ស្រី សុវណ្ណ ចារុវណ្ណោ** )

# ប្រវត្តិដើមពោធិព្រឹក្សនៅវត្តជេតពន



(អានន្ទពោធិ៍ នៅវត្តជេតពន)



# ប្រវត្តិអានន្ទពោធិ៍

(ដើមពោធិ៍ដែលព្រះអានន្ទដាំនៅមុខវត្តជេតពន

ក្រោយចេញវស្សាទី ១០ ហើយ)

នៅក្នុងអដ្ឋកថាកាលិង្គពោធិជាតក សម្តែងថាៈ

កាលព្រះសាស្តាទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ព្រះអង្គទ្រង់ប្រារព្ធការបូជាដើមមហាពោធិ៍ដែលព្រះអានន្ទត្ថេរធ្វើហើយ ទើបត្រាស់នូវព្រះធម្មទេសនានេះថា **ស្តេចចក្រពត្តិព្រះនាមថា កាលិង្គៈ** (រាជា កាលិង្គោ ចក្កវត្តិ) ជាដើម ។

ហិ សេចក្តីពិស្តារថា កាលព្រះតថាគតទ្រង់ស្តេចចារិកទៅក្នុងជនបទ ដើម្បីប្រយោជន៍ការសង្រ្គោះវេនេយ្យសត្វ ។ សាវត្ថិវាសិនោ ពុទ្ធបរិស័ទអ្នកនៅក្នុងក្រុងសាវត្ថី កាន់យកគ្រឿងក្រអូបនិងផ្កាឈើជាដើមទៅកាន់វត្តជេតពន មិនបានទីគួរបូជាយ៉ាងដទៃក៏យកទៅតម្កល់ទុកទៀបទ្វារព្រះគន្ធកុដិ ទាំងមិនសប្បាយចិត្ត ហើយក៏នាំគ្នាត្រឡប់ទៅវិញ។ អនាថបិណ្ឌិកោ លោកអនាថបិណ្ឌិកមហាសេដ្ឋីបានដឹងហេតុនោះហើយ ទើប

ទៅកាន់សម្នាក់ព្រះអានន្ទត្ថេរៈ ក្នុងកាលដែលព្រះតថាគតព្រះអង្គត្រឡប់មកកាន់វត្តជេតពនវិញ ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន កាលព្រះតថាគតស្ដេចចារិកទៅ ព្រះវិហារនេះមិនមានទីពឹង, មនុស្សទាំងឡាយ មិនមានស្ថានទីគួរបូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម សូមឱកាសចុះលោកម្ចាស់ សូមលោកម្ចាស់ក្រាបទូលនូវរឿងនេះចំពោះព្រះសាស្ដា ហើយចូរដឹងនូវទីដែលគួរបូជាមួយកន្លែង"។

ព្រះអានន្ទត្ថេរទទួលថា "សាធុ ប្រពៃហើយ" ហើយទូលសួរព្រះសាស្ដាថា "កតិ នុ ខោ ភន្តេ ចេតិយានិ បពិត្រព្រះអង្គដ៏ចម្រើន ចេតិយមានប៉ុន្មានយ៉ាង ? " ។

ព្រះអង្គត្រាស់តបថា "តីណិ អានន្ទ មាន ៣ យ៉ាងអានន្ទ" ។

ព្រះអានន្ទទូលសួរថា "កតមានិ ភន្តេ តីណិ ៣ យ៉ាងអ្វីខ្លះព្រះអង្គ ? "។

ព្រះសាស្ដាត្រាស់ថា "សារីរិកំ បរិភោគិកំ ឧទ្ទិស្សកំ គឺធាតុចេតិយ (ចេតិយ គឺព្រះសារីរិកធាតុ) ១ បរិភោគចេតិយ

(ចេតិយ គឺដើមពោធិព្រឹក្ស និងគ្រឿងបរិក្ខារ) ១ ឧទ្ទិស្សក-ចេតិយ (ចេតិយ គឺព្រះពុទ្ធរូប) ១"។

ព្រះអានន្ទទូលសួរថា "សក្កា បន ភន្តេ, តុម្ហេសុ ធរន្តេសុយេវ ចេតិយំ កាតុំ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលដែលព្រះអង្គទ្រង់ព្រះជន្មធរមាននៅ តើខ្ញុំព្រះអង្គអាចធ្វើចេតិយបានដែរឬទេ ?" ។

ព្រះសាស្តាត្រាស់ថា "អានន្ទ សារីរិកំ ន សក្កា កាតុំ ។ តញ្ហិ ពុទ្ធានំ បរិនិព្វានកាលេ ហោតិ, ឧទ្ទិស្សកំ អវត្ថុកំ មមាយនមត្តមេវ ហោតិ, ពុទ្ធេហិ បរិភុត្តោ មហាពោធិរុក្ខោ ពុទ្ធេសុ ធរន្តេសុបិ ចេតិយមេវ។ ម្នាលអានន្ទ អ្នកមិនអាចធ្វើធាតុចេតិយបានទេ ព្រោះធាតុចេតិយនោះ នឹងមានបានក្នុងកាលដែលព្រះពុទ្ធបរិនិព្វានហើយ, ចំណែកឧទ្ទិស្សកចេតិយ ក៏មិនមានវត្ថុប្រាកដ (ព្រោះ) ជាប់ដោយតថាគតប៉ុណ្ណោះ, ឯដើមមហាពោធិ៍ដែលព្រះពុទ្ធទ្រង់អាស្រ័យជាទីត្រាស់ដឹង សូម្បីកាលព្រះពុទ្ធទ្រង់មានព្រះជន្មនៅឡើយ ក៏ជាចេតិយបានដូចគ្នា"។

ព្រះអានន្ទទូលទៀតថា "ភន្តេ តុម្ហេសុ បក្កន្តេសុ ជេត-

ខនទិហារេ អប្បដិសរណោ ហោតិ, មហាជនោ បូជនីយ-
ដ្ឋានំ ន លភតិ, មហាពោធិតោ ពីជំ អាហរិត្វា ជេតវនទ្វារេ
រោបេស្សាមិ, ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គស្តេច
ជៀសចេញទៅ ជេតពនមហាវិហារមិនមានទីពឹង មហាជន
មិនបាននូវស្ថានទីជាទីបូជា ខ្ញុំព្រះអង្គនឹងនាំយកនូវពូជអំពីដើម
មហាពោធិ៍មកដាំជិតទ្វារវត្តជេតពន ព្រះអង្គ" ។

ព្រះសាស្តាត្រាស់ថា "សាធុ អានន្ទ, រោបេហិ, ឯវំ សន្តេ
ជេតវនេ មម និពទ្ធវាសោ វិយ ភវិស្សតិ ល្អហើយអានន្ទ
អ្នកចូរដាំចុះ កាលបើដូច្នោះ ដើមមហាពោធិ៍ក៏ហាក់ដូចជាទី
នៅប្រចាំរបស់តថាគត ក្នុងវត្តជេតពនដែរ"។

ព្រះអានន្ទឱ្យទូលដល់ព្រះបាទកោសល ឱ្យប្រាប់ដល់
អនាថបិណ្ឌិកមហាសេដ្ឋី និងពួកបរិស័ទមាននាងវិសាខាជាដើម
ឱ្យជីករណ្ដៅក្នុងទីសម្រាប់ដាំដើមពោធិព្រឹក្ស ជិតទ្វារវត្តជេតពន
ហើយពោលនឹងព្រះមហាមោគ្គល្លានត្ថេរថា "ភន្តេ អហំ ជេត-
វនទ្វារេ ពោធឹ រោបេស្សាមិ, មហាពោធិតោ មេ ពោធិបក្កំ
អាហរថ បពិត្រលោកម្ចាស់ ខ្ញុំនឹងដាំដើមពោធិ៍ទៀបទ្វារវត្ត

ជេតពន សូមលោកចូរនាំយកផ្លែពោធិ៍ទុំអំពីដើមមហាពោធិ៍ឱ្យខ្ញុំផងចុះ" ។

ព្រះមហាមោគ្គល្លានត្ថេរទទួលថា "សាធុ ល្អហើយ" ទើបទៅកាន់ពោធិមណ្ឌលតាមផ្លូវអាកាស យកចីវរទទួលផ្លែពោធិ៍ដែលជ្រុះចាកទងតែនៅមិនទាន់ដល់ផែនដីនៅឡើយ បានហើយក៏នាំមកប្រគេនព្រះអានន្ទ ។

ព្រះអានន្ទ ឱ្យក្រាបទូលដល់ព្រះបាទកោសលជាដើមថា "អជ្ជ ពោធិំ រោបេស្សាមិ មហាបពិត្រ អាត្មាភាពនឹងដាំដើមពោធិ៍ក្នុងថ្ងៃនេះ" ។ ក្នុងវេលាល្ងាច ព្រះបាទកោសលទ្រង់ឱ្យបរិវារដ៏ច្រើន កាន់យកគ្រឿងឧបករណ៍គ្រប់យ៉ាង ស្តេចយាងមក ។ អនាថបិណ្ឌិកសេដ្ឋី ឧបាសិកាវិសាខា និងជនអ្នកមានសទ្ធាដទៃៗ ទៀតក៏បានមកដែរ។

ព្រះអានន្ទបានតាំងផើងមាសធំ ទុកក្នុងទីសម្រាប់ដាំដើមមហាពោធិ៍ ឱ្យចោះទម្លុះបាតផើង ហើយដាក់ភក់ដែលផ្សំដោយរបស់ក្រអូបឱ្យពេញ បានថ្វាយដល់ព្រះរាជាដោយទូលថា "ឥមំ ពោធិបង្កំ រោបេហិ មហារាជា បពិត្រមហារាជ សូម

ព្រះអង្គចូរទ្រង់ដាំដើមពោធិ៍នេះចុះ”,

ព្រះបាទកោសលទ្រង់គិតថា “រជ្ជំ នាម ន សព្វកាលំ អម្ហាកំ ហត្ថេ តិដ្ឋតិ, ឥទំ មយា អនាថបិណ្ឌិកេន រោបាបេតុំ វដ្ដតិ ឈ្មោះថារាជសម្បត្តិ មិនតាំងនៅក្នុងដៃរបស់យើងសព្វកាលទេ យើងគួរឱ្យដល់អនាថបិណ្ឌិក សេដ្ឋីដាំដើមពោធិ៍នេះ” ទ្រង់គិតដូច្នេះហើយ បានដាក់ផ្លែពោធិ៍ទុំនោះទៅក្នុងដៃមហាសេដ្ឋី ។ អនាថបិណ្ឌិកមហាសេដ្ឋី ប្រមូលភក់ដែលមានក្លិនក្រអូបហើយកប់ផ្លែពោធិ៍ទំទុកក្នុងភក់នោះ ។

តស្មិំ តស្ស ហត្ថតោ មុត្តមត្តេយេវ សព្វេសំ បស្សន្តានញ្ញេវ នង្គលសីសប្បមាណោ ពោធិខន្ធោ បណ្ណាសហត្ថុព្វេធោ ឧដ្ឋហិ, ចតូសុ ទិសាសុ ឧទ្ធញ្ចាតិ បញ្ច មហាសាខា បណ្ណាសហត្ថាវ និក្ខមឹសុ គ្រាន់តែផ្លែពោធិ៍ផុតពីដៃមហាសេដ្ឋីប៉ុណ្ណោះ ដែលមហាជនកំពុងតែរមិលមើលនោះឯង ដើមពោធិ៍មានទំហំប្រមាណប៉ុនភ្នៀងនង្គ័ល កម្ពស់ ៥០ ហត្ថ ក៏ដុះឡើង បែកមែកធំ ៥ គឺក្នុងទិសទាំង ៤ និងខាងលើ, មែកនីមួយៗ ប្រមាណ ៥០ ហត្ថ ចេញទៅហើយរំពេជនោះឯង ។

ឥតិ សោ គន្ធណរញ្ញោ ទនប្បតិជេដ្ឋកោ ហុត្វា អដ្ឋាសិ ដើមពោធិ៍នោះតាំងឡើងជាដើមឈើជាម្ចាស់នៃព្រៃ (គឺដើមឈើជាធំក្នុងព្រៃ) ដោយប្រការដូច្នេះ ។ ព្រះរាជាទ្រង់បញ្ចុះក្អមមាសនិងក្អមប្រាក់ប្រមាណ ១៨ ក្អម ឱ្យពេញដោយទឹកក្រអូប តាំងក្អមដែលពេញហើយ ប្រដាប់ដោយបាច់ផ្កាឧប្បលខៀវជាដើម ជុំវិញដើមមហាពោធិ៍ទុកតាមលំដាប់ ហើយត្រាស់ឱ្យសាងវេទិកា[១] ដែលសម្រេចដោយរតនៈ ៧ ប្រការ ទ្រង់រោយខ្សាច់ដែលលាយដោយមាស ឱ្យសាងកំពែងព័ទ្ធជុំវិញ ឱ្យសាងខ្លោងទ្វារសម្រេចដោយរតនៈ ៧ ប្រការ បានមានសក្ការៈដ៏ធំហើយ ។

ព្រះអានន្ទត្ថេរចូលទៅគាល់ព្រះតថាគត ក្រាបទូលថាៈ "ភន្តេ តុម្ហេហិ មហាពោធិមូលេ សមាបន្នសមាបត្តឹ មយា រោបិតពោធិមូលេ និសីទិត្វា មហាជនស្ស ហិតត្ថាយ សមា-

១-**វេទិកា** សព្ទនេះជួបនៅក្នុងព្រះសុត្តន្តបិដក គម្ពីរអបទានជាច្រើនកន្លែង ក្រុមជុំនុំលោកប្រែថា "**ខឿន**" ដូចជាខឿនដើមពោធិព្រឹក្សជាដើម, ក្នុងវចនានុក្រមខ្មែរប្រែថា "**ភ្នាក់ដៃ, បង្កាន់ដៃ, ក្តារហឹង, ជើងម៉ាសម្រាប់អង្គុយ...**", ចំណែកក្នុងក្នុងវចនានុក្រមបាលីប្រែថា "ទីបូជា, តុគ្រឿងបូជា..."។

បដ្ឋិថ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់គង់ប្រថាប់ត្រង់គល់ដើមពោធិ៍ ដែលខ្ញុំព្រះអង្គដាំហើយ ទ្រង់ចូលសមាបត្តិ ដែលព្រះអង្គធ្លាប់ចូលហើយត្រង់គល់ដើមមហាពោធិ៍ ដើម្បីប្រយោជន៍អនុគ្រោះដល់មហាជនផងចុះព្រះអង្គ" ។

ព្រះសាស្តាត្រាស់ថា "អានន្ទ កឹ កថេសិ មយិ មហាពោធិមូលេ សមាបន្នសមាបត្តឹ សមាបជ្ជិត្វា និសិន្នេ អញ្ញោ បទេសោ ធារេតុំ ន សក្កោតិ ម្នាលអានន្ទ អ្នកនិយាយស្អីកាលតថាគតគង់ចូលសមាបត្តិ ដែលធ្លាប់ចូលហើយត្រង់គល់ដើមមហាពោធិ ទីកន្លែងដទៃរមែងមិនអាចនឹងទ្រទ្រង់បានឡើយ" ។

ព្រះអានន្ទក៏ក្រាបទូលថា "ភន្តេ មហាជនស្ស ហិតត្ថាយ ឥមស្ស ភូមិប្បទេសស្ស ធុវនិយាមេន សមាបត្តិសុខេន តំ ពោធិមូលំ បរិភុញ្ជថ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីប្រយោជន៍សុខដល់មហាជន សូមព្រះអង្គទ្រង់អាស្រ័យនូវគល់ដើមពោធិ៍នោះ ដោយសេចក្តីសុខដែលកើតអំពីសមាបត្តិ ដោយកំណត់ថាជាទីកន្លែងដ៏ពិតប្រាកដចុះ ព្រះអង្គ" ។

សត្តា ឯករត្តឹ សមាបត្តិសុខេន បរិភុញ្ជិ ព្រះសាស្តាទ្រង់អាស្រ័យគល់ដើមពោធិ៍នោះ ដោយសេចក្តីសុខដែលកើតអំពីសមាបត្តិ អស់មួយរាត្រី។

ព្រះអានន្ទត្ថេរ ថ្វាយព្រះពរដល់ព្រះបាទកោសលជាដើមឱ្យធ្វើការឆ្លងដើមមហាពោធិ៍ហើយ ។ សោបិ ខោ ពោធិរុក្ខោ អានន្ទត្ថេរេន រោបិតត្តា អានន្ទពោធិយេវាតិ បញ្ញាយិត្ថ ឯដើមពោធិ៍នោះ ក៏ប្រាកដនាមថា **អានន្ទពោធិ៍** ព្រោះជាដើមពោធិ៍ដែលព្រះអានន្ទត្ថេរបានដាំ ។

គ្រានោះភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងសាលាធម្មសភាថា "អាវុសោទាំងឡាយ ព្រះអានន្ទ កាលព្រះតថាគតកំពុងគង់ព្រះជន្មនៅឡើយ ឱ្យដាំដើមពោធិ៍ហើយ ឱ្យធ្វើការបូជាយ៉ាងធំអស្ចារ្យណាស់ ព្រះថេរៈមានគុណដ៏ច្រើន"។ ព្រះសាស្តាស្តេចយាងមកហើយក៏ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលឱ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន

អានន្ទក៏បាននាំមនុស្សក្នុងទ្វីបធំទាំង ៤ ព្រមទាំងបរិវារ នាំយករបស់ក្រអូប និងផ្កាឈើជាដើមដ៏ច្រើនមកហើយ ឱ្យធ្វើការឆ្លងដើមមហាពោធិ៍ក្នុងមហាពោធិមណ្ឌលដូចគ្នា”។ ទើបទ្រង់នាំរឿងក្នុងអតីតមកសម្តែង ។

។ល ។

អានន្ទពោធិ៍នេះ រាប់តាំងពីវស្សាទី ១០ ដល់ព.ស.២៥៦៣ (ឆ្នាំ ២០២០) នេះ មានអាយុ ២៥៩៨ ឆ្នាំ ។

ប្រវត្តិអានន្ទពោធិ៍ ក្នុងអដ្ឋកថាកាលិង្គពោធិជាតក តេរសកនិបាត

ចប់ដោយសង្ខេប





**បរម្បរាគតានំ ហិ ជយម្ហា ពោធិរុក្ខតោ**

**សព្វេសំ ពោធិរុក្ខានំ នត្វាន បូជយាមហំ៕**

ខ្ញុំព្រះករុណា សូមនមស្ការបូជានូវដើមពោធិព្រឹក្សគ្រប់ដើម ដែលមានដំណមកអំពីពោធិព្រឹក្ស ដែលជាទីឈ្នះមារ ។

**យំ យំ បរិភុញ្ជិ ភគវា បត្តចីវរមាទិកំ**

**សព្វំ បរិភោគធាតុំតំ នត្វាន បូជយាមហំ ៕**

ខ្ញុំព្រះករុណា សូមនមស្ការបូជាបរិភោគចេតិយទាំងពួង មានបាត្រនិងចីវរជាដើមនោះ ដែលព្រះដ៏មានព្រះភាគ ទ្រង់ប្រើប្រាស់ហើយ។

# ប្រវត្តិដើមពោធិព្រឹក្សនៅប្រទេសស្រីលង្កា









# ប្រវត្តិដើមពោធិព្រឹក្សនៅប្រទេសស្រីលង្កា

## សេចក្ដីខាងដើម

### ១. កោះលង្កាជាប់ទាក់ទងនឹងព្រះពុទ្ធ

ប្រទេសស្រីលង្កា (សីហឡទ្វីប, តម្ពបណ្ណិទ្វីប ឬលង្កាទ្វីប), នៅក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកកុសន្ធោ ទ្វីបនេះមានឈ្មោះថា "**ឱជទ្វីប**", ក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកោនាគមនោ មានឈ្មោះថា "***វរទ្វីប***", ក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបោ មានឈ្មោះថា "**មណ្ឌទ្វីប**" លុះមកដល់សម័យព្រះសមណគោតមបរមគ្រូនៃយើង ទ្វីបនេះ មានឈ្មោះថា "**សីហឡទ្វីប**"(កោះដែលវិជ័យរាជកុមារជាបុត្ររបស់សីហពាហុគ្រប់គ្រង) ផង ឈ្មោះថា "**តម្ពបណ្ណិទ្វីប**" (កោះរបស់មនុស្សដែលមានបាទដៃក្រហម)ផងឈ្មោះថា "**លង្កាទ្វីប**"ផង។

ក្នុងសមន្តប្បាសាទិ, សារត្ថទីបនីដីកា, គម្ពីរទីបវង្ស, គម្ពីរមហាវង្ស និងគម្ពីរសាសនវង្សប្រាប់ថា ព្រះសម្មាសម្ពុទ្ធបរមគ្រូ

នៃយើង ទ្រង់ធ្លាប់យាងទៅកោះនេះចំនួន ៣ លើក គឺៈ

លើកទី ១ ព្រះអង្គយាងទៅដល់ មហា**នាគវ័នឧទ្យាន** (មហិយង្គណចេតិយ) ដែលជាចំណុចកណ្ដាលនៃប្រទេសស្រី-លង្កា (លង្កាមជ្ឈេ) តែមួយព្រះអង្គឯងបុណ្ណោះ ដើម្បីទូន្មានយក្ស ក្នុងថ្ងៃ ១៥ កើត ខែបុស្ស ក្រោយត្រាស់ដឹង ៩ ខែ ។

លើកទី ២ ព្រះអង្គយាងទៅដល់ **នាគទីបៈ** តែមួយព្រះអង្គឯងដូចគ្នា ដើម្បីទូន្មានស្ដេចនាគដែលជាឪពុកមានិងក្មួយឈ្មោះគ្នាដណ្ដើមបល្លង្កកែវមណី ក្នុងថ្ងៃ ១៥ រោច ខែចេត្រ ក្រោយត្រាស់ដឹង ៥ វស្សា ។

លើកទី ៣ ព្រះអង្គយាងទៅដល់ **នគរកល្យាណី** ជាមួយនឹងភិក្ខុ ៥០០ អង្គ ដើម្បីប្រោសមណិអក្ខិកនាគរាជ ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ក្រោយត្រាស់ដឹង ៨ វស្សា ហើយទ្រង់ប្រដិស្ឋានស្នាមព្រះបាទទុកលើកំពូលភ្នំសុមនកូដ និងទ្រង់គង់ចូលនិរោធសមាបត្តិ ក្នុងទីនៃមហាចេតិយ (សុវណ្ណមាលិកចេតិយ), ត្រង់ថូបារាមចេតិយ, **ត្រង់ទីប្រតិស្ឋានដើមមហាពោធិ៍** (គឺកន្លែងដាំដើមពោធិព្រឹក្សសព្វថ្ងៃ ក្នុងឧទ្យានមេឃវ័ន ឋិតនៅទិសខាង

ត្បូងក្រុងអនុរាធបុរី), ត្រង់មហិយង្គណចេតិយ, ត្រង់ទីមុទិង្គចេតិយ, ក្នុងទីឃវាបិចេតិយ និងត្រង់កល្យាណីចេតិយ (ចេតិយក្នុងវត្តកល្យាណីសព្វថ្ងៃ) ។

ហើយក្នុងទីប្រតិស្ឋានដើមពោធិព្រឹក្សសព្វថ្ងៃនេះ ក៏ធ្លាប់ជាទីគង់ចូលនិរោធសមាបត្តិ និងធ្លាប់ជាកន្លែងដាំដើមពោធិព្រឹក្សរបស់ព្រះពុទ្ធ ៣ ព្រះអង្គមកហើយដែរ ដូចដែលលោកពោលទុកថាៈ "ឱជទ្វីប, វរទ្វីប, មណ្ឌទ្វីប និងលង្កាទ្វីបដ៏ឧត្តម លោកប្រាប់ឱ្យដឹងថា ឈ្មោះតម្ពបណ្ណិ ។

អភយបុរៈ, វឌ្ឍមានៈ, វិសាលៈនិងអនុរាធបុរៈ ឈ្មោះទាំង ៤ របស់ក្រុងនេះ នៅក្នុងសាសនានៃព្រះពុទ្ធទាំង ៤ ព្រះអង្គ ។

ឧទ្យានឈ្មោះ មហាតិត្ថៈ, មហានាមៈ, សាគរៈ, មហាមេឃវនៈ ស្ថិតនៅក្នុងផ្លូវដ៏ប្រសើរ ជាកន្លែងគង់នៅជាលើកដំបូងនៃព្រះលោកនាថទាំង ៤ ព្រះអង្គ ។

ដើមពោធិ៍របស់ព្រះសម្មាសម្ពុទ្ធកកុសន្ធៈ គឺ**មហាសិរីសព្រឹក្ស** (ដើមច្រែសធំ) ដ៏ប្រសើរ ដែលព្រះនាងរុចនន្ទាភិក្ខុនី

មានឫទ្ធិច្រើន (ព្រមទាំងភិក្ខុនី ៥០០ អង្គ) បាននាំយកមែកខាងត្បូង ហើយដាំក្នុងឧទ្យានមហាតិត្ថវ៉ន ក្នុងឱជទ្វីប ។

ដើមពោធិ៍របស់ព្រះសម្មាសម្ពុទ្ធកោនាគមនៈ គឺ **ឧទុម្ពរព្រឹក្ស** (ដើមល្វា) ដ៏ប្រសើរ ដែលព្រះនាងកណកទត្តាភិក្ខុនី មានឫទ្ធិច្រើន (ព្រមទាំងភិក្ខុនី ៥០០ អង្គ) បាននាំយកមែកខាងត្បូង ហើយដាំក្នុងឧទ្យានមហានាមវ៉ន ក្នុងវរទ្វីប ។

ដើមពោធិ៍របស់ព្រះសម្មាសម្ពុទ្ធកស្សបៈ គឺ**និគ្រោធព្រឹក្ស** (ដើមជ្រៃ) ដ៏ប្រសើរ ដែលព្រះនាងសុធម្មាភិក្ខុនី មានឫទ្ធិច្រើន (ព្រមទាំងភិក្ខុនី ៥០០ អង្គ) បាននាំយកមែកខាងត្បូង ហើយដាំក្នុងឧទ្យានមហាសាលវ៉ន (ក្នុងមណ្ឌទ្វីប) ។

ដើមពោធិ៍របស់ព្រះសម្មាសម្ពុទ្ធគោតម គឺ**អស្សត្ថព្រឹក្ស** ដែលព្រះព្រះនាងសង្ឃមិត្តាភិក្ខុនី មានឫទ្ធិច្រើន (ព្រមទាំងភិក្ខុនី ១១ អង្គ)[១] បាននាំយកមែកខាងត្បូង ហើយដាំក្នុង

---

១-គម្ពីរទីបវង្ស ក្នុងបរិច្ឆេទទី ១៨ គាថាទី ១១ និង១២ មានប្រាប់ឈ្មោះភិក្ខុនីទាំង ១១ អង្គនេះថា ១.ឧត្តរាភិក្ខុនី, ២.វិចក្ខណាភិក្ខុនី, ៣.ហេមាភិក្ខុនី, ៤.ប-សាទបាលាភិក្ខុនី, ៥.អគ្គិមិត្តាភិក្ខុនី, ៦.ទាសិកាភិក្ខុនី, ៧.ភេគ្គុភិក្ខុនី, ៨.បព្វតាភិក្ខុនី, ៩.មត្តាភិក្ខុនី, ១០.មល្លាភិក្ខុនី, ១១.ធម្មទាសិយាភិក្ខុនី ។

ឧទ្យានមហាមេឃវ័នដ៏រុងរឿង នៅលើកោះលង្កា ។

ព្រះនាងរុចនន្ទា, ព្រះនាងកណកទត្តា និងព្រះនាងសុធម្មា ជាអ្នកមានឫទ្ធិច្រើន និងព្រះនាងសង្ឃមិត្តា ជាពហុស្សូត្រ ជាអ្នកមានប្រាជ្ញាឃើញច្បាស់ បានអភិញ្ញា ៦, ព្រះភិក្ខុនីទាំង ៤ អង្គនេះ បាននាំយកនូវដើមមហាពោធិ៍ ។

ដើមសិរីសព្រឹក្ស ក្នុងមហាតិត្ថៈ, ដើមឧទុម្ពរព្រឹក្ស ក្នុងមហានាមៈ, ដើមនិគ្រោធព្រឹក្ស ក្នុងមហាសាគរៈ, ដើមអស្សត្ថព្រឹក្ស ក្នុងមេឃវ័ន ។

ដើមពោធិព្រឹក្សទាំង ៤ បានដាំក្នុងឧទ្យានទាំង ៤ ដែលជាអចលដ្ឋាន និងកន្លែងជាទីគង់ក្នុងឧទ្យានជាអចលដ្ឋាន ក្នុងសាសនានៃព្រះពុទ្ធទាំង ៤ ព្រះអង្គ” ។



(ទ្រង់យាងទៅលើកទី១ ដើម្បីទូន្មានពួកយក្ខ)



(ទ្រង់យាងទៅលើកទី ២ ទូន្មាននាគ)

## ២. សេចក្ដីសង្ខេបអំពីរឿងព្រះពុទ្ធសាសនា និងដើមពោធិព្រឹក្សមកកោះលង្កា




(ព្រះមហិន្ទត្ថេរ និងគណៈនិមន្តទៅកាន់តម្ពបណ្ណិទ្វីប)

តាមសេចក្ដីក្នុងគម្ពីរសមន្តប្បាសាទិកា, សារត្ថទីបនីដីកា គម្ពីរទីបវង្ស គម្ពីរមហាវង្ស និងគម្ពីរសាសនវង្ស បានឱ្យដឹងថា

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់បរិនិព្វានទៅហើយ បាន ២១៨ ឆ្នាំ មានស្ដេចមួយព្រះអង្គព្រះនាមថា ធម្មាសោក បាន អភិសេកជាស្ដេចឯករាជ្យក្នុងជម្ពូទ្វីប គឺទ្រង់ឡើងគ្រងរាជ្យក្នុង ព្រះជន្ម ៥៤ ឆ្នាំ ។ ក្រោយពីទ្រង់អភិសេករួចមក ក្នុងឆ្នាំទី ៤ ទើបទ្រង់បានជ្រះថ្លានិងទំនុកបម្រុងព្រះពុទ្ធពុទ្ធសាសនា ដោយ

បច្ច័យ ៤ និងឱ្យគេកសាងព្រះវិហារ ៨៤,០០០ ដែលប្រដាប់ដោយព្រះចេតិយ ៨៤,០០០ ចេតិយ ទូទាំងជម្ពូទ្វីប ដើម្បីបូជាព្រះធម៌ទាំង ៨៤,០០០ ធម្មខន្ធ និងទ្រង់បានកសាងអសោការាម ។ ព្រោះទ្រង់ប្រាថ្នាភាពជាទាយាទនៃព្រះសាសនា ទ្រង់ក៏បានឱ្យរាជបុត្រទាំង ២ អង្គ គឺព្រះមហិន្ទរាជឱរស និងព្រះនាងសង្ឃមិត្តារាជធីតា ដែលក្នុងកាលនោះ ព្រះមហិន្ទទើបតែមានព្រះជន្មបាន ២០ ឆ្នាំ ឯព្រះនាងសង្ឃមិត្តាមានព្រះជន្មបាន ១៨ ឆ្នាំ ។ វេលាដែលព្រះឱរសនិងព្រះធីតាទាំង ២ អង្គព្រះផ្នួស ព្រះរាជាទ្រង់អភិសេកគ្រងរាជ្យបាន ៦ ឆ្នាំ ។ លុះខាងក្រោយមកទៀត គឺក្នុងឆ្នាំទី១៨នៃការគ្រងរាជ្យ ត្រូវនឹងពុទ្ធសករាជ ២៣៥ ទ្រង់បានរំងាប់អធិករណ៍ក្នុងព្រះសាសនា ដោយការចាប់ផ្សឹកនូវពួកតិរ្ថិយ៍ដែលចូលមកបន្លំបួសចំនួន ៦ ម៉ឺននាក់ ហើយទ្រង់បានទំនុកបម្រុងក្នុងការធ្វើសង្គាយនាលើកទី ៣ ហៅថា "តតិយសង្គាយនា" ឬ "សហស្សិកសង្គាយនា" គឺសង្គាយនាដែលមានភិក្ខុ ១,០០០ អង្គ ចូលរួម ក្រោមការដឹកនាំរបស់ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ នៅក្នុងអសោការាមនោះ ។

កាលធ្វើតតិយសង្គាយនាហើយ គឺក្នុងពុទ្ធសករាជ ២៣៥ នោះឯង ត្រូវនឹងថ្ងៃ ២ កើត ខែកត្តិក (ខែ ១២) ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ ក៏បានបញ្ជូនសមណទូតទៅកាន់នគរ និងជនបទផ្សេងៗ ដើម្បីផ្សព្វផ្សាយព្រះសាសនា គឺៈ

១. ព្រះមជ្ឈន្តិកត្ថេរ ទៅកាន់រដ្ឋកស្មីរគន្ធារៈ,

២. ព្រះមហាទេវត្ថេរ ទៅកាន់មហិង្សកមណ្ឌល,

៣. ព្រះរក្ខិតត្ថេរ ទៅកាន់វនវាសិជនបទ,

៤. ព្រះយោនកធម្មរក្ខិតត្ថេរ ទៅកាន់អបរន្តកជនបទ,

៥. ព្រះមហាធម្មរក្ខិតត្ថេរ ទៅកាន់មហារដ្ឋជនបទ,

៦. ព្រះមហារក្ខិតត្ថេរ ទៅកាន់យោនកលោកជនបទ,

៧. ព្រះមជ្ឈិមត្ថេរ ទៅកាន់ចំណែកមួយក្នុងហិមវន្តទេស,

៨. ព្រះសោណត្ថេរ និងឧត្តរត្ថេរ ទៅកាន់សុវណ្ណភូមិ,

៩-ព្រះមហិន្ទត្ថេរ និងព្រះឥដ្ឋិយត្ថេរ១ ឧត្តិយត្ថេរ១ សម្ពលត្ថេរ១ ភទ្ទសាលត្ថេរ ១ ទៅកាន់តម្ពបណ្ណិទ្វីប ។

តែព្រះមហិន្ទត្ថេរ និងគណៈមិនបានទៅក្នុងថ្ងៃនោះភ្លាមទេ ព្រោះស្តេចមុដ្ឋសីវៈ នៃកោះលង្កាក្នុងពេលនោះ កំពុងតែ

ជរាខ្លាំងមិនអាចនឹងលើកស្ទួយព្រះសាសនាបាន លោកក៏ទៅកាន់វេទិសនគរ ដែលនៅមិនឆ្ងាយពីក្រុងរាជគ្រឹះ ជាស្រុកកំណើតមាតាលោក ស្នាក់នៅទីនោះអស់ ៦ ខែ។

ក្នុងថ្ងៃពេញបូណ៌មី ១៥ កើត ខែជេស្ឋ (ខែ ៧) ត្រូវនឹងពុទ្ធសករាជ ២៣៦ និង ១ ខែ នៅឯកោះតម្ពបណ្ណិទ្វីប មានពិធីបុណ្យនក្ខត្តឫក្ស ក្នុងជេស្ឋមាសៈ (បុណ្យប្រចាំឆ្នាំក្នុងខែជេស្ឋ) ព្រះបាទទេវានម្បិយតិស្សៈ ដែលទើបតែអភិសេកគ្រងរាជ្យបាន ១ ខែគត់ (គឺទ្រង់អភិសេកក្នុងថ្ងៃ ១៥ កើតពេញបូណ៌មីខែពិសាខ ខែ ៦) ព្រះអង្គទ្រង់ប្រកាសឱ្យប្រជាពលរដ្ឋលេងមហោស្រព ចំណែព្រះអង្គឯង ព្រមទាំងរាជបុរស ៤០,០០០ នាក់ ទៅកាន់មិស្សកបព៌តនាទិសខាងកើតក្រុងអនុរាធៈ ដើម្បីបាញ់ម្រឹគ។

ឯព្រះមហិន្ទត្ថេរៈ ដែលមានវស្សាផ្នួសទើបតែ ១២ វស្សា បានហោះពីវេទិសគិរី ទៅចុះលើកំពូលភ្នំមិស្សកបព៌ត[១]នោះ

---

១-**មិស្សកបពិត** គឺភ្នំដែលមានថ្មលើធូលី (បំសុបាសាណមិស្សកត្តា) ។ សារត្ថទីបនីដីកា។ បច្ចុប្បន្នគឺ មិហិន្តលេ ឬមហិន្តលេ (Mihintale) នៅទិសខាងកើតក្រុងអនុរាធបុរី ប្រហែល ១៥ គីឡូម៉ែត្រ ។

ឯង ។ កាលព្រះថេរៈ និងព្រះរាជាបានជួបគ្នាសន្ទនាដឹងរឿងសព្វគ្រប់ហើយ ទើបសម្តែងនូវ**ចូឡហត្ថិបទោបមសូត្រ**[១] ញុំាងព្រះរាជា និងបរិវារប្រមាណ ៤០,០០០ នាក់ឱ្យតាំងនៅក្នុងត្រៃសរណគមន៍ និងសីល ៥ ។ ហើយលោកក៏ស្នាក់នៅក្នុងទីនោះ ១ រាត្រី, ក៏ក្នុងរាត្រីនោះឯង ព្រះថេរៈបញ្ជាឱ្យសុមនសាមណេរប្រកាសវេលាស្តាប់ធម៌ សាមណេរក៏ចូលចតុត្ថជ្ឈានមានអភិញ្ញាជាបាទ ចេញចាកឈានហើយ អធិដ្ឋានចិត្តតាំងមាំប្រកាសវេលាស្តាប់ធម៌ឮទូទាំងតម្ពបណ្ណិទ្វីប អស់វារ ៣ ដងព្រះថេរក៏សម្តែងនូវ**សមចិត្តសូត្រ**[២] ទេវតាមួយអសង្ខេយ្យបានសម្រេចធម៌ នាគនិងគ្រុឌជាច្រើនបានតាំងនៅក្នុងសរណគមន៍។ លុះព្រឹកស្អែកឡើង ព្រះរាជាបញ្ជូនបម្រើឱ្យទៅនិមន្តព្រះថេរទាំងនោះ លោកក៏ហោះទៅចុះត្រង់ទ្វារទិសខាងកើតក្រុង ទីនោះក៏កើតជាបឋមចេតិយ។ កាលសម្រេចភត្តកិច្ចហើយ ព្រះថេរក៏សម្តែង**បេតវត្ថុ**[៣], **វិមានវត្ថុ**[៤] និង**សច្ចសំយុត្ត**[៥] ស្ត្រី

---

១-ម. មូ.បិ. ២១/១៦៩ ។ ២-**សមចិត្តសូត្រ** ឬសមចិត្តវគ្គ (អង្គុ.ទុក. បិ.៤០/១៣៦។ ៣-ខុ.បិ.៥៦ ។ ៤-ខុ.វិ.បិ.៥៥។ ៥-សំ.ម.បិ.៣៩/២២៦។

៥០០ នាក់ មានព្រះនាងអនុឡាទេវីជាប្រធាន ក៏បានសម្រេចនូវសោតាបត្តិផល បន្ទាប់មកសម្ដែង**ទេវទូតសូត្រ**[១] កាលចប់ទេសនាមហាជនចំនួន ១,០០០ នាក់បានសម្រេចសោតាបត្តិផលទៀត និងសម្ដែងនូវ**អាសីវិសូបមសូត្រ**[២] មហាជនប្រមាណ ១.០០០ នាក់ទៀតមានសម្រេចសោតាបត្តិផល។

ក្នុងថ្ងៃទី ២ នៃការមករបស់ព្រះថេរៈ ការត្រាស់ដឹងធម៌បានមានដល់មនុស្សប្រមាណ ២,៥០០ នាក់ ។

ក្នុងរាត្រីទី ២ ព្រះថេរទាំងឡាយស្នាក់នៅក្នុងឧទ្យានមេឃវ័ន ដែលនៅទិសខាងត្បូងនៃព្រះនគរ មិនឆ្ងាយពេក និងមិនជិតពេក, លុះរាត្រីកន្លងទៅ ព្រះរាជាបានយាងទៅសួរដល់ការសិងជាសុខរបស់ព្រះថេរៈទាំងឡាយ កាលដឹងថា ឧទ្យាននេះជាទីសប្បាយ សមគួរដល់សមណៈហើយ ទ្រង់បានច្រូចទឹកទៅលើព្រះហស្តព្រះថេរ ហើយថ្វាយឧទ្យានមហាមេឃវ័ននោះជាអារាមដំបូងគេ[៣] ។ ថ្ងៃទី ៣ សម្ដែង**អនមតគ្គិយសូត្រ** ក្នុង

---

១-ម.ឧ.បិ.២៧/២០៥ ។ ២-សំ.ស.បិ.៣៥/៣៩៤ ។ ៣-ព្រះរាជឧទ្យានមហាមេឃវ័នតមកគឺមហាវិហា ។

ឧទ្យាននន្ទវ័ន ជិតទ្វារខាងត្បូងក្រុង។ ថ្ងៃទី ៤ សម្តែង**អគ្គិខន្ធោ-បមសូត្រ**[១] លោកសម្តែងដោយឧបាយនេះឯង រហូតដល់ ៧ ថ្ងៃ ។ ការត្រាស់ដឹងធម៌បានមានដល់សត្វប្រមាណ៨,៥០០នាក់ ហើយឧទ្យាននោះក៏បានឈ្មោះថា ជោតិវ័ន។ ក្នុងថ្ងៃទី ៧ ព្រះថេរសម្តែង**អប្បមាទសូត្រ**[២] ប្រោសព្រះរាជាក្នុងព្រះរាជវាំង ហើយក៏និមន្តទៅកាន់ចេតិយគិរីវិញ ដើម្បីចូលចាំវស្សាក្នុងទីនោះ ។ ព្រះរាជាក៏យាងឡើងរាជារថទៅតាមសួរដំណើរវិលត្រឡប់របស់ព្រះថេរទាំងឡាយ ក៏ក្នុងពេលនោះ អាមាត្យឈ្មោះ អរិដ្ឋៈ និងបងប្អូនប្រមាណ ៥៥ នាក់សូមបួស ព្រះថេរក៏ឱ្យបួសក្នុងថ្ងៃនោះឯង អ្នកទាំងនោះបានសម្រេចព្រះអរហត្តក្នុងវេលាកោរសក់រួចដូចគ្នា ។ ព្រះថេរទាំងនោះនៅចាំវស្សាក្នុងចេតិយគិរី, ក្នុងវស្សាទី ១ នោះមានព្រះអរហន្ត ៦២ អង្គ ។ កាលព្រះថេរៈចាំវស្សាបវារណារួចហើយ ក្នុងថ្ងៃឧបោសថ ពេញបូណ៌មីខែកត្តិក បានណែនាំព្រះរាជាឱ្យរកវត្ថុដែលគួរបូជា សុមន-សាមណេរក៏ទទួលភារៈនោះ ដោយបាននិមន្តទៅសូមព្រះធាតុ

---

១-អង្គុ.សត្តក. បិ.៤៧/២៣០ ។ ២-អង្គុ.ចតុក្ក. បិ.៤២/៣០១។

អំពីព្រះបាទធម្មាសោកដែលជាជីតា ហើយក៏ទៅកាន់តាវត្តិង្ស ទេវលោក សូមអារាធនាព្រះធាតុឆ្អឹងដងកាំបិតខាងស្តាំ (ទក្ខិណ អក្ខកធាតុ) អំពីព្រះឥន្ទ្រ កាលសាមណេរទទួលព្រះធាតុបាន ហើយយកមកប្រតិស្ឋានក្នុងចេតិយគិរី ។ ហើយក៏បានអារាធនា ព្រះបរមធាតុទៅកាន់មហានាគវ័នឧទ្យាន ក្នុងវេលារសៀល ។ ព្រះរាជានិងបរិវារមួយអន្លើដោយមហាជន នាំគ្នាទៅកាន់មហា វ័នឧទ្យាន ខណៈនោះ ព្រះបរមធាតុក៏បានមកប្រតិដ្ឋាននៅលើ ព្រះសិរសារបស់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា "លោកម្ចាស់ ដ៏ចម្រើន តើខ្ញុំព្រះករុណាត្រូវបដិបត្តិព្រះធាតុដូចម្តេច ? " ព្រះ ថេរៈថ្វាយព្រះពរ ឱ្យព្រះអង្គលើកព្រះធាតុទៅតម្កល់លើពោងដំរី ខណៈនោះមហាមេឃក៏បង្អុរភ្លៀងបោក្ខរព័សចុះមក ទាំងផែន ដីក៏ញាប់ញ័រ ឯដំរីក៏ដើរឆ្ពោះមុខទៅកាន់ថូបារាមដែលធ្លាប់ជាទី តាំងបរិភោគចេតិយនៃព្រះសម្មាសម្ពុទ្ធមុនៗ ៣ ព្រះអង្គ គឺ ១ ជាកន្លែងបញ្ចុះ**ធម្មក្រក**របស់ព្រះមានព្រះភាគកកុសន្ធោ, ២ ជា កន្លែងបញ្ចុះវត្ថពន្ធចង្កេះ របស់ព្រះមានព្រះភាគកោនាគមនោ, ៣ ជាកន្លែងបញ្ចុះ**ឧទកសាដក**របស់ព្រះមានព្រះភាគកស្សបោ។

កាលដល់ហើយ ដំរីក៏បានទៅឈរត្រង់កន្លែងជាទីតាំងដាំដើមពោធិ៍នាទិសបស្ចិម ។ ព្រះរាជាក៏បានកសាងព្រះស្តូបដែលមានរាងដូចនឹងគំនរស្រូវដើម្បីតម្កល់ព្រះធាតុ ខណៈនោះព្រះធាតុក៏ហោះឡើងកាន់អាកាសកម្ពស់ ៧ ដើមត្នោត សម្តែងយមកបាដិហារ្យ ធារទឹកនិងអណ្តាតភ្លើងមានរស្មី ៦ ពណ៌បានជះសាយចេញអំពីព្រះធាតុនោះ ដូចគ្នានឹងបាដិហារ្យដែលព្រះអង្គទ្រង់សម្តែងទៀបគល់ស្វាយ ជិតក្នុងសាវត្ថីដូច្នោះ ។ ក៏ឯបាដិ-ហារ្យនោះកើតឡើងដោយពុទ្ធានុភាព កាលដែលទ្រង់មានព្រះជន្មនៅឡើយបានអធិដ្ឋានថា "**កាលតថាគតបរិនិព្វានហើយយមកបាដិហារ្យចូរមានក្នុងថ្ងៃប្រតិស្ឋានព្រះធាតុដងកាំបិតខាងស្តាំរបស់យើង ក្នុងទីដែលជាទីតាំងនៃបរិភោគចេតិយរបស់ព្រះពុទ្ធអង្គមុនៗ ៣ ព្រះអង្គ ក្នុងទិសទក្សិណនៃអនុរាធបុរីក្នុងកោះតម្ពបណ្ណិ**"។ ហើយការមកដោយព្រះសរីរធាតុក្នុងកោះលង្កាលើកនេះ គឺជាការមកលើកទី ៤ នៃព្រះមានព្រះភាគនៃយើង ។ ក៏បាដិហារ្យនៃព្រះធាតុនោះ បានញុំាងកម្តៅក្នុងកោះទាំងមូលឱ្យរំងាប់ទៅដោយគ្រាប់ភ្លៀង ហើយចុះមកប្រតិស្ឋាន

លើព្រះសិរសាព្រះរាជា កាលស្ដេចប្រតិស្ឋានព្រះធាតុក្នុងទីនោះ ប្រថពីក៏ញាប់ញ័រ ។ ព្រោះការជ្រះថ្លានឹងបាដិហារ្យនោះ អភ័យរាជកុមារ ជាកនិដ្ឋភាតារបស់ព្រះរាជា ទ្រង់ចេញព្រះផ្នួស ព្រមទាំងបុរស១,០០០ នាក់ និងក្មេងប្រុស ៥០០ នាក់ទៀតមកអំពីស្រុកវេតាលិគ្រាម, សូម្បីស្រុកទ្វារមណ្ឌលជាដើម ស្រុកនីមួយៗ មានមនុស្ស ៥០០ នាក់ៗ ចេញបួស នៅមានក្មេងច្រើនរយនាក់ទៀតទាំងខាងក្នុងក្រុង និងខាងក្រៅក្រុងចេញបួសដែរ រួមជាភិក្ខុទាំងអស់ ៣០,០០០ អង្គ ដែលបួសក្នុងកាលនោះ ។

សូម្បីព្រះនាងអនុឡាទេវី ដែលបានសម្រេចសោតាបត្តិផល ព្រោះបានស្ដាប់នូវ**បេតវត្ថុ**, **វិមានវត្ថុ** និង**សច្ចសំយុត្ត** និងស្ត្រី ៥០០ នាក់ទៀត តាំងពីក្នុងថ្ងៃទី ២ នោះ ក៏សូមបួសក្នុងកាលនោះដែរ ។ **ព្រោះតែរឿងការបំបួសព្រះនាងនេះឯង ទើបត្រូវទៅនិមន្តព្រះនាងសង្ឃមិត្តាថេរីមក**។ ដូច្នេះ តទៅនេះ ជាសេចក្ដីពិស្ដារ ដែលត្រូវរៀបរាប់អំពីរឿងការនាំដើមពោធិព្រឹក្សមកកាន់កោះលង្កាហើយ ។

## ព្រះនាងអនុឡាទេវីទ្រង់មានព្រះបំណងនឹងបួស

ក៏សម័យនោះឯង ព្រះនាងអនុឡាទេវីប្រាថ្នានឹងបួស ទើបបានក្រាបទូលព្រះរាជាឱ្យទ្រង់ជ្រាប ។

ព្រះរាជា ទ្រង់ស្ដាប់ពាក្យក្រាបទូលរបស់ព្រះនាងហើយ ទើបបានត្រាស់នឹងព្រះថេរៈថា "បពិត្រលោកម្ចាស់ ព្រះនាងអនុឡាទេវីមានបំណងនឹងបួស សូមលោកម្ចាស់បំបួសឱ្យព្រះនាងផង" ។

ព្រះថេរៈថ្វាយព្រះពរថា "មហារាជ អាត្មាភាពនឹងបំបួសឱ្យមាតុគ្រាមមិនបានទេ ។ តែក្នុងនគរបាដលីបុត្ត មានប្អូនស្រីអាត្មាភាព ឈ្មោះសង្ឃមិត្តាថេរី សូមព្រះអង្គទ្រង់ឱ្យនិមន្តព្រះថេរីនោះមក,មហាបពិត្រ **ដើមពោធិព្រឹក្សរបស់ព្រះសម្មាសម្ពុទ្ធមុនៗ ទាំង ៣ ព្រះអង្គ ក៏បានប្រតិស្ឋាននៅក្នុងកោះនេះ សូម្បីដើមពោធិព្រឹក្សបញ្ចេញបណ្ដាញ គឺរស្មីដែលគួរត្រេកអររបស់ព្រះមានព្រះភាគនៃយើង ក៏គួរប្រតិស្ឋាននៅលើកោះនេះ ព្រោះហេតុនោះ ព្រះអង្គគួរបញ្ជូនរាជសាសន៍ទៅដល់ព្រះថេរីសង្ឃមិត្តាឱ្យអារាធនានូវដើមពោធិព្រឹក្សមកផង**"។

# ព្រះរាជាបញ្ជូនទូតទៅកាន់ជម្ពូទ្វីប

ព្រះរាជាទ្រង់ទទួលពាក្យរបស់ព្រះថេរៈថា "សាធុ ប្រពៃហើយលោកម្ចាស់" ទ្រង់ប្រឹក្សាជាមួយនឹងពួកអាមាត្យ ហើយត្រាស់នឹងអាមាត្យ ដែលជាក្មួយរបស់ព្រះអង្គ ឈ្មោះអរិដ្ឋថា "ម្នាលបា តើអ្នកនឹងអាចទៅកាន់នគរបាដលិបុត្ត និមន្តព្រះនាងសង្ឃមិត្តាថេរីមក ព្រមទាំងដើមពោធិព្រឹក្សបានទេ?"។

អរិដ្ឋអាមាត្យក្រាបទូលថា "អាចមហារាជ បើព្រះអង្គនឹងទ្រង់អនុ-ញ្ញាតឱ្យទូលបង្គំបួស" ។

ព្រះរាជាត្រាស់ថា "ទៅចុះអ្នកនិមន្តព្រះថេរីមកហើយ ចូរបួសចុះ"។

អាមាត្យនោះកាន់យកព្រះរាជសាសន៍ និងថេរសាសន៍ ហើយទៅកាន់កំពង់ចម្លងឈ្មោះ ជម្ពុកោឡបដ្តនៈ[១] ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ដោយកម្លាំងការអធិដ្ឋានរបស់ព្រះថេរៈ ចុះ

---

១ -ជម្ពុកោឡៈ តាំងនៅក្នុងនាគទ្វីប ទិសខាងជើងលង្កាទ្វីប ទូកចេញពីកំពង់ជម្ពុកោឡៈទៅដល់កំពង់តាមពលិត្តក្នុងរយៈពេល ៧ ថ្ងៃ ទៅដល់ក្រុងអនុរាធបុរីវិញក្នុងរយៈពេល ៥ ថ្ងៃ ។ ចូរមើល G.P. Malalasekara, **Dictionary of pali proper Names.** vol l. pp. 934-940

ទូកឆ្លងសមុទ្រសំដៅទៅនគរបាដលីបុត្ត ។ ចំណែកព្រះនាងអនុឡាទេវីព្រមទាំងស្ត្រី ៥០០ នាក់ និងស្ត្រីក្នុងបុរី ៥០០ នាក់ទៀតនាំគ្នាសមាទានសីល ១០ គ្រងសំពត់កាសាវៈ ឱ្យសាងទីស្នាក់នៅក្នុងចំណែកមួយនៃព្រះនគរហើយអាស្រ័យនៅ ។

## អរិដ្ឋអាមាត្យថ្វាយព្រះរាជសាសន៍ និងថេរសាសន៍

អរិដ្ឋអាមាត្យបានទៅដល់ក្នុងថ្ងៃនោះឯង ទូលថ្វាយព្រះរាជសាសន៍ ដល់ព្រះរាជាហើយក្រាបទូលយ៉ាងនេះថា "បពិត្រព្រះសម្មតិទេព ក្រោមល្អងធូលីព្រះបាទ ព្រះមហិន្ទត្ថេរជាព្រះរាជឱរសរបស់ព្រះអង្គទូលយ៉ាងនេះថា 'បានឮថា ព្រះទេវីព្រះនាមអនុឡា ជាព្រះជាយារបស់ព្រះកនិដ្ឋភាតា (ប្អូនប្រុស) នៃព្រះបាទទេវានម្បិយតិស្ស ជាសំឡាញ់របស់ព្រះអង្គ មានប្រាថ្នានឹងបួស ដើម្បីឱ្យព្រះនាងបានបួស សូមព្រះអង្គទ្រង់ព្រះករុណាប្រោសបញ្ជូនព្រះនាងសង្ឃមិត្តាថេរី និងដើមមហាពោធិ៍ទៅជាមួយនឹងព្រះនាងផងចុះ" ។ អរិដ្ឋអាមាត្យ លុះទូលថ្វាយថេរៈសាសន៍ហើយ ក៏ចូលទៅរកព្រះនាងសង្ឃមិត្តាថេរី

ក្រាបទូលយ៉ាងនេះថា "ព្រះនាងម្ចាស់ព្រះមហិន្ទត្ថេរជាព្រះភាតា (បងប្រុស) របស់ព្រះនាង បញ្ជូនខ្ញុំព្រះករុណាមកកាន់សម្នាក់របស់ព្រះនាងដោយពាក្យថា 'ព្រះនាងអនុឡាទេវី ជាព្រះជាយារបស់ព្រះកនិដ្ឋភាតា នៃព្រះបាទទេវានម្បិយតិស្ស ព្រមទាំងស្ត្រី ៥០០ នាក់ និងស្ត្រីក្នុងបុរី ៥០០ នាក់ទៀត មានបំណងនឹងបួស សូម ព្រះនាងម្ចាស់ ចូរនិមន្តមកបំបួសឱ្យព្រះនាងផងចុះ" ។

ខណៈនោះ ព្រះថេរីក៏ប្រញាប់ប្រញាល់ទៅកាន់រាជដំណាក់ ហើយថ្វាយព្រះពរយ៉ាងនេះថា "មហាបពិត្រ ព្រះមហិន្ទត្ថេរៈព្រះជេដ្ឋភាតា របស់អាត្មាបញ្ជូនដំណឹងមកយ៉ាងនេះថា 'បានឮថា ព្រះនាងអនុឡាទេវីជាព្រះជាយារបស់ព្រះកនិដ្ឋភាតានៃព្រះរាជា ព្រមទាំងស្ត្រី ៥០០ នាក់ និងស្ត្រីក្នុងវាំង ៥០០ នាក់ទៀត មានបំណងនឹងបួស រង់ចាំអាត្មា' អាត្មាប្រាថ្នានឹងទៅកាន់កោះតម្ពបណ្ណិ"។

ព្រះរាជាត្រាស់ថា "ព្រះនាងម្ចាស់ ព្រះមហិន្ទត្ថេរៈជាឱរសរបស់ញោម និងសុមនសាមណេរជាចៅរបស់ញោមទៅកាន់

កោះតម្ពបណ្ណិ ធ្វើឱ្យញោមដូចជាមនុស្សដាច់ដៃ ។ កាលញោម មិនឃើញឱរសនិងចៅទាំង២ ក៏កើតសេចក្ដីសោក តែកាល ឃើញមុខព្រះនាងម្ចាស់ សេចក្ដីសោកក៏ស្ងប់ទៅ កុំឡើយ ព្រះ នាងម្ចាស់កុំទៅឡើយ"។

ព្រះថេរីថ្វាយព្រះពរថា "មហាបពិត្រ ពាក្យរបស់ម្ចាស់ បងនៃអាត្មាធ្ងន់ណាស់ សូម្បីព្រះនាងអនុឡាខត្តិយានី ដែល ហែហមដោយស្ត្រី ១,000 នាក់ មានមុខឆ្ពោះទៅរកការបព្វជ្ជា រង់ចាំអាត្មា អាត្មាចាំបាច់ត្រូវតែទៅ"។

ព្រះរាជាត្រាស់ថា "ព្រះនាងម្ចាស់ បើដូច្នេះ សូមព្រះនាង អារាធនាដើមមហាពោធិ៍ទៅផងចុះ"។

សួរថា "ព្រះរាជាទ្រង់បានដើមមហាពោធិ៍មកអំពីណា?"។

ឆ្លើយថា "បានឮថា មុនអំពីព្រះសង្ឃមិត្តាថេរីនឹងទៅ កាលសុមនសាមណេរនៅមិនទាន់មក ដើម្បីទទួលព្រះបរមធាតុ ព្រះរាជាទ្រង់មានព្រះបំណងនឹងបញ្ជូនដើមមហាពោធិ៍ ទៅកាន់ កោះតម្ពបណ្ណិទ្វីបមុនហើយ ដោយទ្រង់ព្រះតម្រិះថា "យើង នឹងបញ្ជូនដើមមហាពោធិ៍ ដែលមិនគួរកាត់ដោយសស្ត្រាទៅបាន

ដូចម្ដេចហ្ន៎” កាលមិនទ្រង់ឃើញឧបាយ ទើបត្រាស់សួរអាមាត្យឈ្មោះមហាទេព” ។

អាមាត្យនោះក្រាបទូលថា “បពិត្រមហារាជ ភិក្ខុដែលជាបណ្ឌិតមានច្រើន (គួរសាកសួរលោក)” ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ ត្រាស់បង្គាប់ឱ្យចាត់-ចែងភត្តទុកដើម្បីភិក្ខុសង្ឃ ក្នុងទីបំផុតនៃភត្តកិច្ច ទើបត្រាស់សួរព្រះសង្ឃថា “លោកម្ចាស់ ដើមមហាពោធិ៍របស់ព្រះដ៏មានព្រះភាគគួរទៅកាន់កោះលង្កា ឬមិនគួរទេ”។ ព្រះសង្ឃប្រគល់ឱ្យជាភារៈរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរៈ។

## មហាអធិដ្ឋាន ៥ ប្រការរបស់ព្រះមានព្រះភាគ

ព្រះថេរៈថ្វាយព្រះពរថា “មហាបពិត្រ ដើមមហាពោធិ៍គួរទៅកាន់កោះលង្កា” ដូច្នេះ ទើបបានថ្វាយព្រះពរ**មហាអធិដ្ឋាន ៥ ប្រការ**របស់ព្រះមានព្រះភាគ ។

មហាអធិដ្ឋាន ៥ ប្រការ តើដូចម្ដេច ?

ភគវា កិរ មហាបរិនិព្ពានមញ្ចេ និបន្នោ លង្កាទីបេ មហាពោធិបតិដ្ឋាបនត្ថាយ “អសោកមហារាជា មហាពោធិគ្គហ-

ឈាត្លំ គមិស្សតិ, តទា មហាពោធិស្ស ទក្ខិណសាខា សយមេវ ឆិជ្ជិត្វា សុវណ្ណកដាហេ បតិដ្ឋាតុ"

បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់ផ្ទំលើគ្រែបរិនិព្វាន ដើម្បីត្រូវការឱ្យដើមមហាពោធិ៍ប្រតិស្ឋានក្នុងលង្កាទ្វីប បានទ្រង់អធិដ្ឋានថា "ព្រះបាទអសោកមហារាជ នឹងស្តេចយាងទៅទទួលដើមមហាពោធិ៍ ក្នុងគ្រានោះ មែកមហាពោធិ៍ផ្នែកទិសខាងត្បូង ចូរដាច់ចុះមកប្រតិស្ឋាននៅក្នុងផើងមាសដោយខ្លួនឯង" ។ នេះជាអធិដ្ឋានទី ១ ។

ទ្រង់អធិដ្ឋានថា តត្ថ បតិដ្ឋានកាលេ ច "មហាពោធិ ហិមវលាហកគព្ភំ បវិសិត្វា បតិដ្ឋាតុ ។ មែងមហាពោធិ៍ ចូរអណ្តែតទៅកាន់ស្រទាប់ពពកអាប់តាំងនៅ ក្នុងវេលាប្រតិស្ឋាននៅក្នុងផើងមាសនោះ" ។ នេះជាអធិដ្ឋានទី ២ ។

ទ្រង់អធិដ្ឋានថា "សត្តមេ ទិវសេ ហិមវលាហកគព្ភតោ ឱរុយ្ហ សុវណ្ណកដាហេ បតិដ្ឋហន្តោ បត្តេហិ ច ផលេហិ ច ឆព្វណ្ណរំសិយោ មុញ្ចតុ ។ ក្នុងថ្ងៃទី ៧ ដើមមហាពោធិ៍ចូរអណ្តែតចុះមកអំពីស្រទាប់ពពកអាប់ ប្រតិស្ឋាននៅក្នុងផើង

មាស បញ្ចេញរស្មីមានពណ៌ ៦ អំពីស្លឹក និងផ្លែទាំងឡាយ" ។ នេះជាអធិដ្ឋានទី ៣ ។

ទ្រង់អធិដ្ឋានថា "ថូបារាមេ ទក្ខិណក្ខកធាតុ ចេតិយម្ហិ បតិដ្ឋានទិវសេ យមកបាដិហារិយំ ករោតុ។ ព្រះធាតុដងកាំបិតខាងស្តាំ ចូរធ្វើយមកប្បាដិហារិយ៍ ក្នុងថ្ងៃប្រតិស្ឋានក្នុងព្រះចេតិយក្នុងថូបារាម" ។ នេះជាអធិដ្ឋានទី ៤ ។

ទ្រង់អធិដ្ឋានថា "លង្កាទីបម្ហិ ទោណមត្តា ធាតុយោ មហាចេតិយម្ហិ បតិដ្ឋានកាលេ ពុទ្ធវេសំ គហេត្វា វេហាសំ អព្ភុគ្គន្ត្វា យមកបាដិហារិយំ ករោន្តុ" ។ "ព្រះធាតុរបស់តថាគតប្រមាណ ១ ទោណៈ[១] ក្នុងកោះលង្កា ចូររួមគ្នាជាព្រះពុទ្ធជាម្ចាស់ ហោះឡើងទៅកាន់វេហាហើយធ្វើយមកប្បាដិហារិយ៍ ក្នុងវេលាប្រដិស្ឋានក្នុងមហាចេតិយ"។ នេះជាអធិដ្ឋានទី ៥ ។

---

១-ទោណៈ គឺមាត្រាវាល់ ១ ទោណៈ ស្មើនឹង ១២ នាឡិមគធៈ (វជិរ.ដីកាបាលី ៣៥) ឬ ១ ទោណៈ ស្មើនឹង ១៦ នាឡិមគធៈ (សារត្ថ.ដីកា បាលី ១/២២៣)។

## វិស្សុកម្មទេវបុត្របន្លំខ្លួនធ្វើជាជាងនិម្មិតផើងមាស

ព្រះរាជាទ្រង់ស្តាប់មហាអធិដ្ឋាន ៥ ប្រការនេះហើយ មានព្រះទ័យជ្រះថ្លា ត្រាស់ឱ្យចាត់ចែងជម្រះផ្លូវឱ្យស្អាតតាំងពីក្រុងបាដលីបុត្តទៅរហូតដល់ដើមមហាពោធិ៍ ឱ្យនាំមាសជាច្រើនចេញមកដើម្បីត្រូវការឱ្យសាងផើងមាស ។ ក្នុងខណៈនោះឯងវិស្សុកម្មទេវបុត្រជ្រាបព្រះតម្រិះ ទើបនិម្មិតខ្លួនជាជាងមាសឈរនៅខាងមុខព្រះភ័ក្រ (របស់ព្រះរាជា) ។ ព្រះរាជាទតឃើញជាងមាសហើយទើបត្រាស់ថា "តាត ឥមំ សុវណ្ណំ គហេត្វា កដាហំ ករោហិ នែអ្នក ចូរអ្នកយកមាសនេះទៅធ្វើផើងចុះ" ។

ទេពនិម្មិតទូលថា "បមាណំ ទេវ ជានាថ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ប្រាប់ទំហំឱ្យដឹង"។

ព្រះរាជាត្រាស់ថា "ត្វមេវ តាត ញត្វា ករោហិ នែអ្នក អ្នកហ្នឹងឯងដឹង ចូរធ្វើឱ្យមានខ្នាតល្មម" ។

ទេពនិម្មិតទទួលថា "សាធុ ទេវ ករិស្សាមិ ល្អហើយព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងធ្វើ" ទើបកាន់យកមាសហើយ ប្រើ

ដៃស្ទាបអង្អែល ដោយអានុភាពរបស់ខ្លួន និម្មិតជើងមាសវាស់ដោយជុំវិញបានប្រមាណ ៩ ហត្ថ កំពស់ ៥ ហត្ថ ទទឹង ៣ ហត្ថ កម្រាស់ ៨ ធ្នាប់ កណ្ដាប់មាត់មានទំហំប្រមាណប៉ុនគល់ប្រមោយដំរី។

## ព្រះបាទអសោកយាងទៅកាន់ដើមមហាពោធិព្រឹក្ស

ព្រះរាជាស្ដេចចេញអំពីនគរបាដលីបុត្ត ព្រមទាំងពួកសេនាដ៏ធំ (រៀបចំក្បួន) បណ្ដោយប្រមាណ ៧ យោជន៍ ទទឹងប្រមាណ ៣ យោជន៍ នាំព្រះអរិយសង្ឃ ស្ដេចយាងទៅកាន់ដើមមហាពោធិ៍ ពួកសេនាដើរហ៊ុមព័ទ្ធដើមមហាពោធិ៍ដែលមានទង់ផ្ទាំងសំពត់ វិចិត្រដោយរតនៈផ្សេងៗ ប្រដាប់ដោយគ្រឿងអលង្ការយ៉ាងច្រើន ដេរដាសទៅដោយផ្កាឈើ មានប្រភេទផ្សេងៗ ប្រគុំគ្រឿងតូរ្យតន្ត្រីច្រើនយ៉ាង ។ ព្រះរាជានិមន្តព្រះថេរៈ ជាប្រធានគណៈប្រមាណ ១,០០០ រូប ហើយបង្គាប់ឱ្យយាងព្រះរាជាអ្នកបានទទួលការអភិសេកទូទាំងជម្ពូទ្វីប ចំនួន ១,០០០ ព្រះអង្គ ហែហមព្រះអង្គ និងដើមមហាពោធិ៍ ហើយ

ប្រថាប់ឈរជិតគល់មហាពោធិ៍ ទ្រង់ងើយទតមើលដើមមហាពោធិ៍ ។ រឿរដើម និងចំណែកនៃមែកធំផ្នែកទិសខាងត្បូង ប្រមាណ ៤ ហត្ថ នៃមហាពោធិ៍ ចំណែកដ៏សេសមិនអាចទតព្រះនេត្រឃើញបាន ។

ព្រះរាជាទ្រង់ឃើញបាដិហារិយ៍នោះហើយ ទ្រង់កើតបីតិបាមោជ្ជៈ ត្រាស់ចំពោះភិក្ខុសង្ឃថា "អហំ ភន្តេ ឥមំ បាដិហារិយំ ទិស្វា តុដ្ឋោ មហាពោធឹ សកលជម្ពុទីបរជ្ជេន បូជេមិ លោកម្ចាស់ដ៏ចម្រើន ញោមឃើញបាដិហារិយ៍នេះហើយមានសេចក្តីត្រេកអរ នឹងបូជាដើមមហាពោធិ៍ ដោយរាជសម្បត្តិទូទាំងជម្ពូទ្វីប" ហើយទើបបានថ្វាយគ្រឿងអភិសេក។

## ព្រះរាជាទ្រង់ធ្វើសច្ចាធិដ្ឋាន

គ្រានោះ ព្រះរាជាទ្រង់បូជា (ដើមមហាពោធិព្រឹក្ស) ដោយគ្រឿងសក្ការៈមានផ្កាឈើនិងរបស់ក្រអូបជាដើម ទ្រង់ធ្វើប្រទក្សិណ ៣ ជុំ ទ្រង់ថ្វាយបង្គំក្នុងទីទាំង ៨ ស្តេចក្រោកឡើងហើយប្រថាប់ឈរផ្គងអញ្ជលី មានព្រះបំណងនឹងអារាធនា

ដើមមហាពោធិ៍ដោយការធ្វើសច្ចវាចា ត្រាស់បង្គាប់ឱ្យតម្កល់ផើងមាសទុកខាងលើតាំង ដែលសម្រេចដោយរតនៈគ្រប់យ៉ាងដែលតម្កល់ឱ្យខ្ពស់ឡើង តាំងអំពីផែនដីទៅរហូតដល់មែកផ្នែកទិសខាងត្បូងនៃដើមមហាពោធិ៍ ហើយស្ដេចឡើងប្រថាប់ឈរលើតាំងមាស ទ្រង់ចាប់កាន់ផើងមាស ហើយទ្រង់ធ្វើស្នាមគំនូសដោយមនោសិលា ហើយទ្រង់តាំងសច្ចកិរិយាថា "យទិ មហាពោធិនា លង្កាទីបេ បតិដ្ឋាតព្វំ, យទិ ចាហំ ពុទ្ធសាសនេ និព្វេមតិកោ ភវេយ្យំ, មហាពោធិ សយមេវ ឥមស្មឹ សុវណ្ណកដាហេ ឱរុយ្ហ បតិដ្ឋាតុ បើដើមមហាពោធិ៍គួរនឹងប្រតិស្ឋានក្នុងកោះលង្កា និងប្រសិនបើខ្ញុំព្រះអង្គនឹងគប្បីជាអ្នកមិនមានសេចក្ដីសង្ស័យក្នុងព្រះពុទ្ធសាសនា សូមឱ្យដើមមហាពោធិ៍ចូរប្រតិស្ឋាននៅក្នុងផើងមាសនេះដោយខ្លួនឯង"។ ព្រមជាមួយនឹងការតាំងសច្ចវាចា មែកពោធិ៍ក៏បានដាច់ត្រង់ទីដែលកំណត់ទុកដោយមនោសិលាមកប្រតិស្ឋាននៅលើផើងមាស ដែលពេញដោយភក់លាយដោយរបស់ក្រអូប ។ ដើមមហាពោធិ៍នោះ មានកំពស់ ១០ ហត្ថ មានមែកធំ ៥ មែក ប្រមាណ ៤ ហត្ថ ប្រដាប់

ដោយផ្លែ ៥ ផ្លែ ចំណែកមែកតូច មានចំនួន ១,០០០ មែក។ គ្រានោះ ព្រះរាជាទ្រង់បានកំណត់ស្នាមគំនូសទីដទៃទៀត ប្រមាណ ៣ ធ្នាប់ត្រង់ស្នាមគំនូសដើម ។ ខណៈនោះឯងឫស កែវ ១០ ក៏ដុះជាពន្លកចេញមកអំពីស្នាមគំនូសនោះ ។ ព្រះរាជា ទ្រង់កំណត់ស្នាមគំនូសដទៃៗ ៩ កន្លែងទៀត គំនូសនីមួយៗ ប្រមាណ ៣ ធ្នាប់ ខាងលើឡើងទៅៗរហូត ឫសល្អិតៗ ប្រមាណ ៩០ ដុះជាពន្លកចេញមកអំពីស្នាមគំនូសទាំងនោះ១០ៗ។ ឫស កែវ ១០ ដំបូង ដុះចេញមកប្រមាណ ៤ ធ្នាប់។ ឯឫស៩០ ក្រៅ អំពីនេះ ក៏ដុះចាក់ស្រែះចូលគ្នាដូចជាសំណាញ់មុខបង្អួច ព្រះ រាជាប្រថាប់ឈរនៅលើតាំងមាសនោះ ទតព្រះនេត្រឃើញបាដិ-ហារិយ៍មានប្រមាណប៉ុណ្ណោះ ទ្រង់ប្រណម្យអញ្ជលីបន្លឺសំឡេង ខ្លាំង ។ ភិក្ខុច្រើនពាន់រូបក៏បានឱ្យសាធុការ ។ រាជសេនាទាំង អស់ក៏បានបន្លឺដូចគ្នា ។ ទង់សំពត់ច្រើនសែនបក់រវិចៗ។ ពួក ទេវតាតាំងអំពីភូមិទេវតាជាដើមរហូតដល់ពួកព្រហ្មផ្សេងៗ នាំ គ្នាស្រែកឱ្យសាធុការ ។

កាលព្រះរាជាទតឃើញបាដិហារិយ៍ ទ្រង់មានព្រះវរកាយ

ដែលបីតិពាល់ត្រូវហើយមិនមានចន្លោះ ប្រថាប់ឈរផ្គងអញ្ចលីតែម្យ៉ាង ដើមមហាពោធិ៍មានឫស ១០០ ក៏បានប្រតិស្ឋានទៅក្នុងផើងមាស។ ឯឫសកែវ ១០បានចាក់ចុះដល់បាតផើងមាស។ ឫសល្អិតៗ ៩០ ដ៏សេសទៀត ក៏ចម្រើនឡើងតាមលំដាប់ ចាក់ចុះតាំងនៅក្នុងភក់ដែលលាយដោយគ្រឿងក្រអូប ។

កាលដើមមហាពោធិ៍ ប្រតិស្ឋានក្នុងផើងមាសយ៉ាងនេះហើយ មហាប្រថពីក៏កម្រើកញាប់ញ័រ ។ ស្គររបស់ពួកទេវតាក៏បន្លឺឡើងឮដ៏អាកាស ។ មានសំឡេងគឹងកងកោលាហលព្រមគ្នាតាំងអំពីផែនដី រហូតដល់ព្រហ្មលោក ដោយការរេរាំនៃភ្នំទាំងឡាយ សំឡេងសាធុការនៃពួកទេវតា សំឡេងគ្រហឹមរបស់ពួកយក្ខ សំឡេងពោលសរសើរនៃពួកអាសុរ សំឡេងទះដៃនៃពួកព្រហ្ម សំឡេងគំរាមនៃមេឃ សំឡេងសម្រែកនៃពួកសត្វជើង ៤ សំឡេងរងាវនៃពួកបក្សី និងដោយការប៉ុនប្រសប់នៃពួកក្រុមអ្នករបាំ ។ ឆព្វណ្ណរង្សីបានផ្សាយចេញអំពីផ្លែនីមួយៗត្រង់មែកទាំង ៥ ផ្សាយឡើងទៅរហូតដល់ព្រហ្មលោក ដូចជាធ្វើចក្កវាឡទាំងមូលឱ្យជាប់គ្នាទុកតែមួយដោយរនុក (ឬបង្កង់

ផ្ទះ) រតនៈ។

## មែកដើមមហាពោធិព្រឹក្ស
## អណ្តែតឡើងទៅនៅលើផ្ទៃមេឃ ៧ ថ្ងៃ

តាំងអំពីនោះមក ដើមមហាពោធិ៍ចូលទៅកាន់ស្រទាប់ពពកដែលពេញទៅដោយទឹកសន្សើម ហើយតាំងនៅអស់ ៧ ថ្ងៃ ។ មិនមានអ្នកណាឃើញដើមមហាពោធិ៍ឡើយ ។ ព្រះរាជាស្តេចចុះអំពីតាំងរតនៈ ហើយត្រាស់បង្គាប់ឱ្យធ្វើការបូជាដើមមហាពោធិ៍រហូត ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ទឹកសន្សើម និងឆព្វណ្ណរង្សី បានវិលជុំវិញមកអំពីគ្រប់ទិសត្រឡប់ចូលទៅកាន់ដើមមហាពោធិ៍នោះវិញ ។ កាលបន្ទប់នៃចក្កវាឡប្រោសចាកទឹកសន្សើម និងអាប់ស្រឡះល្អ ដើមមហាពោធិ៍ដែលមានមែកធំនិងមែកតូច គ្រប់បរិបូណ៌ប្រដាប់ដោយផ្លែទាំង៥បានប្រតិស្ឋាននៅក្នុងផើងមាស។

ព្រះរាជាទ្រង់ទតឃើញដើមមហាពោធិ៍ ហើយទ្រង់កើតបីតិនិងបាមោជ្ជៈ ព្រោះបាដិហារិយ៍ទាំងនោះ ទ្រង់ព្រះតម្រិះថា

"សកលជម្ពូទីបរជ្ជេន គរុណាមហាពោធឹ បូជេស្សាមិ យើងនឹងបូជាដើមមហាពោធិ៍ជំទង់ ដោយរាជសម្បត្តិក្នុងសកលជម្ពូទ្វីប" ដូច្នេះ ហើយបានព្រះរាជទានគ្រឿងរាជាភិសេកដល់ដើមមហាពោធិ៍ ហើយស្ដេចប្រថាប់ឈរត្រង់កន្លែងដើមមហាពោធិ៍នោះឯងអស់ ៧ ថ្ងៃ ។

ក្នុងវេលាល្ងាច ក្នុងថ្ងៃបវារណាខែកត្តិកដំបូង (បុព្វកត្តិកបវារណាទិវសេ) ដើមមហាពោធិ៍បានប្រតិស្ឋាននៅក្នុងផើងមាស តាំងអំពីនោះមក ព្រះរាជាទ្រង់ឱ្យកាលកន្លងទៅអស់ ៧ ថ្ងៃ នៃដើមមហាពោធិ៍ចូលទៅកាន់ស្រទាប់ពពក និង ៧ ថ្ងៃនៃការអភិសេកកន្លងផុតទៅ ។ ក្នុងថ្ងៃឧបោសថនៃកាឡបក្ខស្ដេចយាងចូលទៅកាន់នគរបាដលីបុត្ត ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃបដិបទ (១ រោច) នៃជុណ្ហបក្ខ ខែកត្តិក (ខែ ១២) ទ្រង់តម្កល់ដើមមហាពោធិ៍ទុកទៀបដើមសាលព្រឹក្សធំ នាទិសខាងកើត ។

# ដើមមហាពោធិព្រឹក្សបែកពន្លកចេញថ្មី

ក្នុងថ្ងៃទី ១៧ តាំងអំពីថ្ងៃដែលដើមមហាពោធិ៍ប្រតិស្ឋាននៅក្នុងផើងមាស ដើមមហាពោធិ៍ក៏មានពន្លកថ្មីៗ ប្រាកដឡើង ។ ព្រះរាជាសូម្បីបានទតឃើញពន្លកទាំងនោះមកអំពីមុនហើយ ក៏នៅទ្រង់ជ្រះថ្លា កាលនឹងទ្រង់បូជាដើមមហាពោធិ៍ដោយរាជសម្បត្តិបន្ថែមទៀត បានព្រះរាជទានគ្រឿងរាជាភិសេកទូទាំងជម្ពូទ្វីប ។ លុះដល់ថ្ងៃពេញបូណ៌មីខែកត្តិក សុមនសាមណេរបានទៅដើម្បីទទួលព្រះបរមធាតុ ក៏បានឃើញការបូជាដល់ដើមមហាពោធិ៍ដែលជាមហោស្រពប្រចាំខែកត្តិក។

ព្រះបាទអសោកមហារាជ ទ្រង់សំដៅដល់ដើមមហាពោធិ៍ដែលបាននាំមកអំពីមហាពោធិមណ្ឌល ហើយតម្កល់ទុកក្នុងនគរបាដលីបុត្ត ដោយន័យដូចពោលមកហើយ ទើបត្រាស់នឹងព្រះនាងសង្ឃមិត្តាថេរីថា "បើដូច្នោះ សូមព្រះនាងម្ចាស់ទទួលយកដើមមហាពោធិ៍ទៅផងចុះ"។

ព្រះនាងសង្ឃមិត្តាថេរីទទួលថា "ថ្វាយព្រះពរ" ។

# ព្រះបាទអសោកតាំងត្រកូលផ្សេងៗ ដើម្បីរក្សាមហាពោធិព្រឹក្ស

ព្រះរាជា បានព្រះរាជទានត្រកូលទេវតា ១៨ ត្រកូល, អាមាត្យ ៨ ត្រកូល, ព្រាហ្មណ៍ ៨ ត្រកូល, កុដុម្ពីក៍ ៨ ត្រកូល, អ្នកចិញ្ចឹមគោ ៨ ត្រកូល, ខ្លារខិន[១] ៨ ត្រកូល, និងអ្នកកាលិង្គៈ ៨ ត្រកូល ដើម្បីរក្សាដើមមហាពោធិ៍ និងព្រះរាជទានក្អមមាស ៨ ក្អមប្រាក់ ៨ ដើម្បីស្រោចទឹកដើមមហាពោធិ៍ ។ ទ្រង់លើកដើមមហាពោធិ៍ ព្រមទាំងគ្រឿងបរិវារនេះឡើងកាន់ទូកក្នុងទន្លេគង្គា ព្រមទាំងបរិវារ ។ សូម្បីព្រះអង្គក៏បានស្តេចយាងចេញអំពីនគរឆ្លងព្រៃឈ្មោះវិជ្ឈដវី ទៅដល់កំពង់ឈ្មោះតាម្ពលិត្តិ[២]រយៈពេល ៧ ថ្ងៃដោយលំដាប់ ។ ក្នុងចន្លោះផ្លូវ ពួកទេវតា នាគ និងមនុស្ស បាននាំគ្នាបូជាដើមមហាពោធិ៍យ៉ាងឱឡារិក ។ សូម្បីព្រះរាជាកាលទ្រង់ប្រដិស្ឋានដើមមហាពោធិ៍ទុក

---

១-តាមន័យក្នុងសារត្ថទីបនីដីកា ថាជាត្រកូលរបស់អ្នកបម្រើរាជាការ មិនមែនជាសត្វទេ ។

២-**តាម្ពលិត្តិ** គឺកំពង់ចម្លង បច្ចុប្បន្នហៅថា Tamluk តាំងនៅត្រើយខាងលិចស្រុករូបនារាយណៈ (Rupnayna) ជាទីហូរមកបញ្ចប់នៃទន្លេ ២ ខ្សែ គឺ ទន្លេសិលៃ (silai) ឬសិលាវតី និងទន្លេទ័លកិសរ៍ (Dalkisor) ឬទ្វារិកេសវារី នៅក្នុងខេត្តតាំបលមែដ៏នាបូរ៍ (Midnapur) ។

ត្រង់ច្រាំងមហាសមុទ្រអស់ ៧ ថ្ងៃហើយ ក៏បានព្រះរាជទានមហារាជសម្បត្តិទូទាំងជម្ពូទ្វីប ។ នេះជាការព្រះរាជទានរាជសម្បត្តិទូទាំងជម្ពូទ្វីបលើកទី ៣ របស់ព្រះអង្គ ។

## ព្រះបាទអសោកទ្រង់លុយទឹក
## បញ្ជូនមហាពោធិព្រឹក្សទៅកោះលង្កា






កាលព្រះបាទអសោកធម្មរាជ ទ្រង់បូជា (ដើមមហាពោធិ៍) ដោយរាជសម្បត្តិដ៏ធំយ៉ាងនេះហើយ ក្នុងថ្ងៃ ១ កើតខែមិគសិរ ទ្រង់លើកដើមមហាពោធិ៍ ស្តេចចុះទឹកជម្រៅប្រមាណ

ត្រឹម-ក ទៅប្រតិស្ឋានលើទូក ហើយ និមន្តព្រះនាងសង្ឃមិត្តាថេរី ព្រមទាំងបរិវារឱ្យឡើងទូក ហើយ ត្រាស់នឹងអរិដ្ឋអាមាត្យថា "អហំ តាត មហាពោធឹ តិក្ខត្តុំ សកលជម្ពុទីបរជ្ជេន បូជេត្វា គលប្បមាណំ ឧទកំ ឱរុយ្ហ មម សហាយកស្ស បេសេសឹ, សោបិ ឯវមេវ មហាពោធឹ បូជេតុំ ។ នែប្រស្នែង យើងបូជាដើមមហាពោធិ៍ដោយរាជសម្បត្តិទូទាំងជម្ពូទ្វីប អស់ ៣ ដង ចុះលុយទឹកប្រមាណត្រឹម-ក បញ្ជូនទៅឱ្យសំឡាញ់របស់យើង សូម្បីសំឡាញ់របស់យើងនោះ ក៏ចូរបូជាដើមមហាពោធិ៍ដូចយ៉ាងនេះដូចគ្នា" ។

កាលព្រះរាជទានព្រះរាជសាសន៍ ដល់សំឡាញ់យ៉ាងនេះហើយ ទ្រង់រំពឹងថា "គច្ឆតិ វតរេ, ទសពលស្ស សរសរំសិជាលំ វិមុញ្ចន្តោ មហាពោធិរុក្ខោ ដើមមហាពោធិ៍របស់ព្រះទសពល ដែលបញ្ចេញបណ្តាញ គឺរស្មីដែលគួរត្រេកអរ កំពុងទៅហើយ"ប្រថាប់ឈរផ្គងអញ្ជលីថ្វាយបង្គំបង្ហូរអស្សុ (ទឹកភ្នែក)។ ទូកដែលប្រតិស្ឋានដើមមហាពោធិ៍នោះ កាលមហាជនកំពុងសំឡឹងមើល បានលយទៅកាន់មហាសមុទ្រ ។ រលកទាំងឡាយ

ក្នុងមហាសមុទ្រ ស្ងប់ស្ងៀមប្រមាណមួយយោជន៍ដោយជុំវិញ។ ផ្កាឈូកមានពណ៌ ៥ ក៏រីកស្គុះស្គាយ ។ តូរ្យតន្ត្រីជាទិព្វទាំងឡាយក៏បន្លឺឡើងឰដ៏អាកាស ។ មានការបូជាដ៏ឧឡារិកក្រៃលែងនៃពួកទេវតាដែលអាស្រ័យនៅឰដ៏អាកាស លើទឹក លើគោក និងលើដើមឈើជាដើម ឱ្យប្រព្រឹត្តទៅក្នុងអាកាស ។ ព្រះនាងសង្ឃមិត្តាថេរីនិមិត្តរូបជាគ្រុឌ ធ្វើឱ្យត្រកូលនាគទាំងឡាយក្នុងមហាសមុទ្រភ័យខ្លាច ។ នាគដែលភ័យខ្លាចទាំងនោះ នាំគ្នាសរសើរសម្បត្តិនោះ[១] ហើយទូលសុំព្រះថេរីនាំដើមមហាពោធិ៍ទៅកាន់ពិភពរបស់នាគ ហើយបូជាដោយរាជសម្បត្តិរបស់នាគរហូត ៧ ថ្ងៃ ទើប (នាំត្រឡប់មក) ប្រតិស្ឋាននៅលើទូកវិញ ។ នាវាបានលយទៅដល់កំពង់ជម្ពុកោលបដ្ដនៈ ក្នុងថ្ងៃនោះឯង ។ ចំណែកព្រះបាទអសោកមហារាជ ទ្រង់កើតទុក្ខព្រោះព្រាត់ប្រាសចាកដើមមហាពោធិ៍ ទ្រង់ព្រះកន្សែងសំឡឹងមើលរហូតផុតទស្សនវិស័យហើយទើបស្ដេចត្រឡប់មកវិញ ។

---

១-ពាក្យថា "សម្បត្តិនោះ បានដល់សម្បត្តិ ពេលគឺឥទ្ធិប្បាដិហារ្យនោះ មានអត្ថាធិប្បាយថា សេចក្ដីអស្ចារ្យនោះ" ។ (សារត្ថទីបនីដីកា)

# ព្រះបាទទេវានម្បិយតិស្ស ត្រៀមទទួលមហាពោធិព្រឹក្ស




ចំណែកព្រះបាទទេវានម្បិយតិស្សមហារាជ ទ្រង់ត្រាស់ឱ្យជម្រះតាក់តែងផ្លូវតាំងអំពីទ្វារទិសខាងជើង (នៃអនុរាធបុរី) រហូតទៅដល់កំពង់ឈ្មោះជម្ពុកោលបដ្ដនៈ ចាប់ផ្ដើមអំពីថ្ងៃ ១ កើត ខែមិគសិរ តាមពាក្យរបស់សុមនសាមណេរ ឱ្យរៀបចំ ។ ក្នុងថ្ងៃដែលស្ដេចចេញអំពីនគរ ទ្រង់បានឈរនៅក្នុងទីតាំងនៃសាលាដែលមាននៅត្រង់ច្រាំងសមុទ្រ ជិតទ្វារទិសខាងជើងនោះ ទ្រង់បានឃើញដើមមហាពោធិ៍ ដែលកំពុងមកក្នុងមហាសមុទ្រ ព្រមដោយសម្បត្តិនោះ ព្រោះអានុភាពរបស់ព្រះថេរៈ ទ្រង់រីករាយព្រះហឫទ័យ ស្ដេចចេញទៅត្រាស់ឱ្យរោយផ្កាឈើ ៥

ពណ៌ ទូទាំងផ្លូវ ឱ្យតាំងទុកនូវគ្រឿងបូជាផ្កាឈើ ដែលមានតម្លៃច្រើនទូទាំងផ្លូវ ក្នុងចន្លោះៗ ស្តេចយាងទៅដល់កំពង់ឈ្មោះជម្ពុកលបដ្ដនៈតែមួយថ្ងៃប៉ុណ្ណោ ទ្រង់ហែហមទៅដោយអ្នករបាំទាំងពួង ទ្រង់បូជា(ដើមមហាពោធិ៍) ដោយគ្រឿងសក្ការៈទាំងឡាយមានផ្កាឈើ ធូប និងគ្រឿងក្រអូបជាដើម ស្តេចចុះទឹកទៅប្រមាណត្រឹម-ក ទ្រង់ត្រេកអរថា "អាគតោ ទសពលស្ស សរសរំសិជាលវិស្សជ្ជនកោ មហាពោធិរុក្ខោ ដើមមហាពោធិ៍ដែលបញ្ចេញរស្មីដែលគួរត្រេកអរ របស់ព្រះទសពល មកហើយ" ទើបទ្រង់លើកដើមមហាពោធិ៍ឡើងទៅប្រតិស្ឋានលើព្រះសិរសា ដែលជាអវយវៈដ៏ឧត្តម ស្តេចយាងឡើងអំពីសមុទ្រ ព្រមទាំងត្រកូលដែលមានជាតិបរិបូណ៌ ១៦ ត្រកូលដែលមកហែហមការពារដើមមហាពោធិ៍ ហើយទ្រង់ប្រតិស្ឋានដើមមហាពោធិ៍ទុកទៀបច្រាំងសមុទ្រ ទ្រង់បូជាដោយរាជសម្ប-ត្តិទូទាំងកោះ តម្ពបណ្ណិរហូត ៧ ថ្ងៃ ។ ហើយទ្រង់បែងចែករាជសម្បត្តិដល់ត្រកូល ដែលបរិបូណ៌ដោយជាតិ ១៦ ត្រកូលជួយគ្នាមើលថែ ។

# ព្រះរាជាតម្កល់មហាពោធិព្រឹក្សក្នុងបូជនីយស្ថាន៤ កន្លែង




កាលដល់ថ្ងៃទី ៤ ព្រះរាជាបានអារាធនាដើមមហាពោធិ៍មកធ្វើការបូជាយ៉ាងឱឡារិក ស្តេចទៅដល់ក្រុងអនុរាធបុរីតាមលំដាប់ ។ សូម្បីក្នុងក្រុងអនុរាធបុរី ព្រះអង្គទ្រង់បានធ្វើសក្ការៈដ៏ធំ វេលារសៀលក្នុងថ្ងៃ ១៤ កើតនោះឯង បានត្រាស់ឱ្យអារាធនាដើមមហាពោធិ៍ចូលទៅតាមទ្វារទិសខាងជើង ហែចូលទៅកណ្តាលក្រុង ចេញទៅតាមទ្វារទិសខាងត្បូង ទ្រង់ឱ្យប្រតិស្ឋានដើមមហាពោធិ៍ទុកទៀបខ្លោងទ្វារនៃរាជឧទ្យាន ដែលបានត្រៀមរៀបចំផ្ទៃដីរួចរាល់ស្រេចជាមុនហើយ ជាចំណុចកណ្តាលនៃព្រះរាជឧទ្យានមេឃវ័ន ដែលធ្លាប់ជាទីគង់ប្រថាប់ចូល

និរោធសមាបត្តិ របស់ព្រះសម្មាសម្ពុទ្ធរបស់យើង និងធ្លាប់ជាទីគង់ចូលសមាបត្តិរបស់ព្រះសម្មាសម្ពុទ្ធអង្គមុនៗ ៣ ព្រះអង្គ និងជាទីប្រដិស្ឋានដើម**មហាសិរីសព្រឹក្ស** (ដើមច្រែសធំ) ដែលជាដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគទ្រង់ព្រះនាម កកុសន្ធៈ **ឧទុម្ពរព្រឹក្ស** (ដើមល្វា) ដែលជាដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគទ្រង់ព្រះនាម កោនាគមនៈ និង**និគ្រោធព្រឹក្ស** (ដើមជ្រៃ) ដែលជាដើមឈើត្រាស់ដឹង របស់ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ មានចម្ងាយអំពីខ្លោងទ្វារទិសខាងត្បូងទៅប្រមាណ ៥០០ ជួរធ្នូ (១ គីឡូ)។

សួរថា ព្រះរាជាទ្រង់ប្រដិស្ឋានដើមមហាពោធិ៍នេះ ដូចម្ដេច ? ។

ឆ្លើយថា បានឮថា ត្រកូលដែលបរិបូណ៌ដោយជាតិទាំង ១៦ ត្រកូលនោះ ដែលហែហមដើមមហាពោធិ៍មកនោះ ខ្លះតែងខ្លួនជាព្រះរាជា ឯព្រះរាជាក៏តែងខ្លួនជាអ្នកយាមទ្វារ ។ ត្រកូលទាំង ១៦ បានអារាធនាដើមមហាពោធិ៍ដាំ (ត្រង់បូជនីយដ្ឋាន ៤ កន្លែង ដូចពោលមកហើយនោះ)។

# ដើមមហាពោធិព្រឹក្សសម្តែងឥទ្ធិបាដិហារ្យ

ក្នុងខណៈដែលផុតអំពីដៃនៃត្រកូលទាំងនុ៎ះ ដើមមហា-ពោធិ៍ក៏អណ្តែតឡើងទៅកាន់អាកាស មានកម្ពស់ប្រមាណ ៨០ ហត្ថ ហើយបញ្ចេញឆព្វណ្ណរង្សី រស្មីផ្សាយចេញទៅគ្របដណ្តប់ទូទៅទាំងកោះ ឡើងទៅរហូតដល់ព្រហ្មលោកខាងលើ ។ បុរសប្រមាណ ១០,០០០ នាក់ ឃើញបាដិហារិយ៍នៃដើមមហាពោធិ៍ ហើយកើតសេចក្តីជ្រះថ្លា ផ្តើមចម្រើនអនុបុព្វវិបស្សនា[១] បានសម្រេចជាព្រះអរហន្តហើយសូមបួស។

ដើមមហាពោធិ៍អណ្តែតនៅឰដ៏អាកាស រហូតព្រះអាទិត្យលិច ។ កាលព្រះអាទិត្យលិចហើយ ត្រឡប់ចុះមកប្រតិស្ឋាននៅលើផែនដី ដោយរោហិណីនក្ខត្តឫក្ស[២] ។ ព្រមគ្នានឹងការប្រតិស្ឋានដើមមហាពោធិ៍នោះឯង ផែនដីដ៏ធំបានកម្រើករហូតដល់ទឹកទ្រផែនដីជាទីបំផុត ។ កាលប្រតិស្ឋាន ហើយ ដើម

---

១-**អនុបុព្វវិបស្សនា** គឺ ការឃើញច្បាស់ ឬសេចក្តីដឹងដែលធ្វើឱ្យកើតការឃើញច្បាស់តាមលំដាប់ មានការតាមឃើញការកើត និងការរលត់នៃបញ្ចខន្ធជាដើម ។ (សារត្ថទីបនីដីកា និងវិមតិវិនោទនីដីកា)

២-ឈ្មោះនក្សត្រឫក្សពួកទី ៤ មានផ្កាយ ៥ ដួង មានរូបសណ្ឋាន ឬទ្រង់ទ្រាយដូចជារថ : ផ្កាយរោហិណី (ពាក្យហោ) ។ វចនានុក្រមខ្មែរ ទំព័រ ១០៧២

មហាពោធិ៍ក៏បានអាស្រ័យនៅក្នុងស្រទាប់ពពកអស់ ៧ ថ្ងៃ ។ សត្វលោកសំឡឹងរកមើលមិនឃើញ។ ក្នុងថ្ងៃទី ៧ អាកាសបានប្រាសចាកពពកហើយ ។ ឆព្វណ្ណរង្សីបានផ្សាយពន្លឺចេញទៅមនុស្សទាំងឡាយ ទើបបានសំឡឹងឃើញមែក ស្លឹក និងផ្លែទាំង ៥ នៃដើមមហាពោធិ៍ ។ ព្រះមហិន្ទត្ថេរៈ ព្រះនាងសង្ឃមិត្តាថេរី និងព្រះរាជាព្រមទាំងរាជបរិវារ បាននាំគ្នាទៅកាន់មហាពោធិស្ថាននោះ ។

ឯជនអ្នកនៅក្នុងទ្វីបទាំងអស់ បានប្រជុំគ្នាជាច្រើន។ កាលជនទាំងនោះកំពុងសំឡឹងមើលនោះឯង ផ្លែមួយអំពីមែកទិសខាងជើងទុំ ហើយក៏ជ្រុះអំពីមែក ។ ព្រះថេរៈបានបង្អោនព្រះហស្តទទួល។ ផ្លែតាំងនៅលើព្រះហស្តរបស់ព្រះថេរៈ។ ព្រះថេរៈបានថ្វាយផ្លែនោះដល់ព្រះរាជាដោយថ្វាយព្រះពរថា "រោបយ មហារាជ មហារាជ សូមព្រះអង្គទ្រង់ដាំចុះ" ។

## ពូជមហាពោធិព្រឹក្សបែកសាខា ៨ - ៣២ ដើម

ព្រះរាជាទ្រង់ទទួលហើយ ក៏រោយនូវមធុរបំសុ (ដីមានជាតិ) ចុះក្នុងផើងមាស ដាក់ដីភក់លាយដោយរបស់ក្រអូបឱ្យពេញ ហើយបណ្តុះទុកក្នុងទីជិតនៃមហាពោធិ៍ ។ កាលជនទាំងពួងកំពុងសំឡឹងមើលនោះឯង ដើមពោធិ៍ខ្ចីៗ ៨ ដើម ដែលមានប្រវែង ៤ហត្ថ បានដុះឡើង ។ ព្រះរាជាទ្រង់ទតឃើញហេតុអស្ចារ្យនោះហើយក៏ទ្រង់បូជាដើមពោធិ៍ខ្ចីៗទាំង ៨ ដើម ដោយស្វេតច្ឆត្រហើយបានព្រះរាជទានគ្រឿងរាជាភិសេក (ដល់ដើមពោធិ៍ខ្ចីទាំង ៨ ដើមនោះ)។ ទើបឱ្យដាំដើមពោធិ៍មួយដើម អំពីដើមពោធិ៍ទាំង៨ ដើមនោះត្រង់កំពង់ឈ្មោះជម្ពុកោលបដ្តនៈ ក្នុងឱកាសដែលដើមមហាពោធិ៍ប្រតិស្ឋានលើកដំបូង ក្នុងកាលដែលមកដល់។ ដាំមួយដើមត្រង់មុខទ្វារផ្ទះរបស់តវក្កព្រាហ្មណ៍ មួយដើមទៀតត្រង់ថូបារាម មួយដើមទៀតត្រង់ឥស្សរនិម្មានវិហារ មួយដើមទៀតត្រង់ទីបឋមចេតិយ មួយដើមទៀតត្រង់ចេតិយបព៌ត មួយដើមទៀតត្រង់កាជរគ្រាម ក្នុងរោហណជនបទ មួយដើមទៀតត្រង់ស្រុកចន្ទគ្រាម ក្នុងរោហណជនបទដូច

គ្នា ។ ពួកមនុស្សបានដាំដើមពោធិ៍ខ្ចីៗ ៣២ ដើម ដែលកើតអំពីពូជនៃផ្លែទាំង ៤ ក្រៅនេះក្នុងអារាមដែលតាំងនៅចម្ងាយ ១ យោជន៍ ។

## ព្រះនាងអនុឡាទេវី និងអរិដ្ឋអាមាត្យ បួសហើយសម្រេចព្រះអរហន្ត

កាលដើមមហាពោធិ៍ដែលជាទង់ជ័យនៃព្រះសទ្ធម្ម របស់ព្រះទស-ពល បានប្រតិស្ឋានដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនអ្នកនៅក្នុងកោះតម្ពបណ្ណិទ្វីបដោយជុំវិញ តាមលំដាប់តកូនចៅយ៉ាងនេះហើយ ព្រះនាងអនុឡាទេវីព្រមទាំងមាតុគ្រាម ១,០០០ គឺស្ត្រីក្រមុំ ៥០០ នាក់ និងស្ត្រីក្នុងបុរី ៥០០ នាក់ទៀត បានបួសក្នុងសម្នាក់ព្រះនាងសង្ឃមិត្តាថេរីមិនយូរប៉ុន្មានក៏បានតាំងនៅក្នុងអរហត្តផលព្រមទាំងបរិវារ។ ចំណែកក្មួយរបស់ព្រះរាជាឈ្មោះអរិដ្ឋ ព្រមទាំងបុរស៥០០ នាក់ បួសក្នុងសម្នាក់ព្រះថេរៈ មិនយូរប៉ុន្មាន ក៏បានតាំងនៅក្នុងព្រះអរហត្តផលព្រមទាំងបរិវារ ។

(ស្រង់ចាកសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ បឋមភាគ ពាហិរកថា)

* ក្នុងគម្ពីរមហាវង្សប្រាប់ថា ដើមពោធិ៍នៅប្រទេសស្រីលង្កាបានដាំក្នុងឆ្នាំទី ១៨ នៃការគ្រងរាជ្យរបស់ព្រះបាទធម្មាសោក ត្រូវនឹងព.ស.២៣៦ ឆ្នាំ ដូច្នេះ ដើមពោធិ៍នេះ រហូតមកដល់សព្វថ្ងៃ (គឺព.ស.២៥៦៣) មានអាយុ ២៣២៧ ឆ្នាំហើយ ។

**ចប់ប្រវត្តិដើមពោធិព្រឹក្ស**

**នៅប្រទេសស្រីលង្កា**

*****

**ឯវំ លង្កា លោកហិតំ សាសនវុឌ្ឍី;**
**សំសោធេន្តោ ឯស មហាពោធិ ទុមិន្ទោ;**
**លង្កាទីបេ រម្មេ មហាមេឃវនស្មឹ,**
**អដ្ឋា សីឃំ កាលមនេកព្ភុតយុត្តោតិ ។**

ដើមព្រះស្រីមហាពោធិព្រឹក្សជាម្ចាស់នៃដើមឈើនោះ ប្រកបដោយសេចក្តីគួរអស្ចារ្យ ធ្វើប្រយោជន៍ដល់ប្រជាជនក្នុងលង្កាទ្វីប និងសេចក្តីចម្រើននៃព្រះសាសនាឱ្យសម្រេចយ៉ាងនេះ ក៏បានប្រតិស្ឋាននៅក្នុងមហាមេឃវ័នដែលគួរមនោរម្យ ក្នុងលង្កាទ្វីបអស់កាលដ៏យូរ ដូច្នេះឯង ។

(ចាកគម្ពីរមហាវង្ស បរិច្ឆេទី ១៩)

# អ្នកទម្លាយព្រះចេតិយ មានទោសស្មើនឹងអនន្តរិយកម្ម

ក្នុងកាលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះជន្មនៅឡើយ បើបុគ្គលណាមួយមានចិត្តប្រទូស្ត គិតចង់សម្លាប់ ធ្វើព្រះលោហិតរបស់ព្រះអង្គ សូម្បីត្រឹមតែមួយចម្អែតសត្វរុយឱ្យពុរពងឡើង ដូចជាភិក្ខុទេវទត្ត អំពើរបស់បុគ្គលនោះ ឈ្មោះថាអនន្តរិយកម្ម ។

នៅក្នុងបបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ, មនោរថ-បូរណី អដ្ឋកថាអង្គុត្តរនិកាយ, សម្មោហវិនោទនី អដ្ឋកថាព្រះអភិធម្ម និងសារត្ថទីបនី ដីកាព្រះវិន័យ ភាគ ៤/១៨១ មានសម្ដែងអំពីទោសនៃបុគ្គលដែលប្រទូស្តព្រះសារីរិកធាតុ ព្រះចេតិយ និងដើមពោធិព្រឹក្ស ទុកដូច្នេះថា ៖

ស្ងួរថា "អថ យេ ច បរិនិព្វុតេ តថាគតេ ចេតិយំ ភិន្ទន្តិ, ពោធឹ ឆិន្ទន្តិ, ធាតុម្ហិ ឧបក្កមន្តិ, តេសំ កឹ ហោតីតិ ។ កាលព្រះតថាគត ទ្រង់បរិនិព្វានទៅហើយ បុគ្គលណាទម្លាយព្រះចេតិយ, កាត់ដើមពោធិព្រឹក្ស, ប្រទូសរ៉ាយនឹងព្រះបរម-

សារីរិកធាតុ, តើកម្មអ្វីនឹងមានដល់បុគ្គលនោះ?”។

ឆ្លើយថា “ភារិយំ កម្មំ ហោតិ អនន្តរិយសទិសំ ។ ជាកម្មធ្ងន់ ស្មើនឹងអនន្តរិយកម្ម” ។

សធាតុកំ បន ថូបំ វា បដិមំ វា ពាធមានំ ពោធិសាខំ ឆិន្ទិតុំ វដ្ដតិ ។ សចេបិ តត្ថ និលីនា សកុណា ចេតិយេ វច្ចំ បាតេន្តិ, ឆិន្ទិតុំ វដ្ដតិយេវ ។ បរិភោគចេតិយតោ ហិ សរីរចេតិយំ មហន្តរំ ។

តែបើកាត់នូវមែកដើមពោធិព្រឹក្ស ដែលបៀតបៀននូវព្រះស្តូប ដែលតម្កល់នូវព្រះសារីរិកធាតុក្តី ព្រះពុទ្ធបដិមាក្តី ក៏គួរ ។ ប្រសិនបើសត្វស្លាប (មានចាបជាដើម) ដែលនៅលើដើមពោធិព្រឹក្សនោះជុះអាចម៍ដាក់ព្រះចេតិយ នឹងកាត់មែកពោធិព្រឹក្សនោះចេញក៏គួរ។ ព្រោះសារីរិកចេតិយ គឺព្រះបរមសារីរិកធាតុសំខាន់ជាងបរិភោគចេតិយ (ដើមពោធិព្រឹក្ស )។

ចេតិយវត្ថុំ ភិន្ទិត្វា គច្ឆន្តំ ពោធិមូលម្បិ ឆិន្ទិត្វា ហរិតុំ វដ្ដតិ ។ យា បន ពោធិសាខា ពោធិយរំ ពាធតិ, តំ គេហរក្ខនត្ថំ ឆិន្ទិតុំ ន លព្ភតិ, ពោធិអត្ថំ ហិ គេហំ, ន គេហត្ថំ

ពោធិ ។

សូម្បីកាត់នូវឫសដើមពោធិព្រឹក្ស ដែលដុះចាក់ទម្លាយព្រះចេតិយ ក៏គួរ។ ចំណែកមែកដើមពោធិព្រឹក្សណាបៀតបៀននូវផ្ទះនៃដើមពោធិព្រឹក្ស នឹងកាត់នូវមែកដើមពោធិព្រឹក្សនោះចេញដើម្បីរក្សាផ្ទះមិនគួរ, ព្រោះថា ផ្ទះធ្វើដើម្បីប្រយោជន៍ដល់ដើមពោធិព្រឹក្ស មិនមែនដើមពោធិព្រឹក្សនោះដាំដើម្បីប្រយោជន៍ដល់ផ្ទះទេ។

អាសនឃរេបិ ឯសេវ នយោ ។ យស្មិំ បន អាសយនឃរេ ធាតុ និធហិត្វា ហោតិ, តស្ស រក្ខនត្ថាយ ពោធិសាខំ ឆិន្ទិតុំ វដ្ដតិ ។ ពោធិជគ្គនត្ថំ ឱគរណសាខំ វា បតិដ្ឋានំ វា ឆិន្ទិតុំ វដ្ដតិយេវ ។

សូម្បីក្នុងផ្ទះអាសនៈ ក៏មានន័យដូចគ្នា ។ ក៏ព្រះបរមសារីរិកធាតុ តម្កល់ក្នុងផ្ទះអាសនៈណា នឹងកាត់មែកដើមពោធិព្រឹក្សដើម្បីរក្សានូវផ្ទះអាសនៈនោះក៏គួរ ។ នឹងកាត់ចេញនូវមែកដែលឱនចុះក្ដី ដែលស្អុយក្ដី ដើម្បីទំនុកបំរុងនូវដើមពោធិព្រឹក្សក្ដីគួរមែនពិត។

ភគវតោ សរីរប្បដិជគ្គនេ វិយ បុញ្ញម្បិ ហោតិ ។ (ការរក្សាដើមពោធិព្រឹក្សនេះ) សូម្បីបុណ្យ ក៏បានដូចការបដិបត្តិព្រះសរីរនៃព្រះដ៏មានព្រះភាគដែរ។

ក្នុងគម្ពីរឧបរិបណ្ណាសកដីកា ឈ្មោះនីនត្ថប្បកាសិនី ភាគ ៣/ ៣៩១ ខែពន្យល់ថា ៖

សរីរប្បដិជគ្គនេ វិយាតិ សត្ថុរូបកាយប្បដិជគ្គនេ វិយ បទថា សរីរប្បដិជគ្គនេ វិយ សេចក្តីថា បុគ្គលកាលរក្សានូវដើមពោធិព្រឹក្ស រមែងបានបុណ្យដូចការបដិបត្តិរូបកាយនៃព្រះសាស្តាដែរ។



វេជ្ជបណ្ឌិតអ្នកជំនាញខាងផ្នែករុក្ខសាស្ត្រ ថែរក្សាព្រះពោធិព្រឹក្ស (ប្រទេសស្រីលង្កា)

# អានិសង្សនៃការបូជាដើមពោធិព្រឹក្ស

## ១. បុឡិនបូជកត្ថេរាបទាន

(រឿងព្រះថេរៈបូជាដីខ្សាច់ត្រង់ខឿនដើមពោធិព្រឹក្ស)

(ព្រះបុឡិនបូជកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា:)

ខ្ញុំកើបខ្សាច់ចាស់ចោល ហើយរោយរាយនូវខ្សាច់ថ្មីដ៏ស្អាតត្រង់ខឿននៃពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្សាច់ ក្នុង កាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយខ្សាច់ ។

ក្នុងកប្បទី ៥៣ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ជាធំជាងជន មានកម្លាំងច្រើន ព្រះនាមមហាបុឡិនៈ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ

ហើយ ។

បានឮថា ព្រះបុឡិនបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុឡិនបូជកត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧២ ទំព័រ ១៧៩)

## ២. គន្ធោទកទាយកត្ថេរាបទាន

(រឿងព្រះថេរៈស្រោចទឹកក្រអូបដើមពោធិព្រឹក្ស)

(ព្រះគន្ធោទកទាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

កាលគេធ្វើពិធីឆ្លងមហាពោធិព្រឹក្ស របស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ខ្ញុំបានយកទឹកក្រអូបមួយក្អមដ៏វិចិត្រ ហើយស្រោចទឹកក្រអូបនោះ លើដើមពោធិ៍នោះ ។ ក្នុងកាលដែលកំពុងតែស្រោចដើមពោធិ៍ មហាមេឃក៏បង្អុរភ្លៀងផ្គរលាន់គឹកកងយ៉ាងខ្លាំង ព្រមទាំងរន្ទះបាញ់ក៏កើតឡើង ។ ខ្ញុំក៏បានធ្វើមរណកាលត្រង់កន្លែងនោះ ដោយកម្លាំងនៃរន្ទះបាញ់ត្រូវ ខ្ញុំបានទៅឋិតនៅក្នុងទេវលោក ហើយសម្តែងនូវគាថានេះថាៈ

"អហោ ពុទ្ធោ អហោ ធម្មោ អហោ នោ សត្ថុសម្បទា
ករណ្ឌវេ មេ បតិតំ ទេវលោកេ រមាមហំ ។

ឱហ្ន៎ព្រះពុទ្ធ ឱហ្ន៎ព្រះធម៌ ឱហ្ន៎សម្បទានៃព្រះសាស្តា របស់ខ្ញុំ ឱសាកសពរបស់ខ្ញុំ ធ្លាក់ចុះហើយ ខ្ញុំបានមកត្រេកអរ ក្នុងទេវលោកនេះ" ។

ភពជាទីនៅរបស់ខ្ញុំ មានជាន់ ៧ ខ្ពស់ត្រដែតត្រដឹម ពួកនាងកញ្ញាមួយសែន តែងចោមរោមខ្ញុំសព្វៗ កាល។ ខ្ញុំមិនមានអាពាធ ខ្ញុំមិនមានសោក ខ្ញុំមិនជួបសេចក្តីក្រហល់ក្រហាយ នេះជាផលនៃបុញ្ញកម្ម ។

ក្នុងកប្បទី ២,៨០០ ខ្ញុំបានជាស្តេចចក្រពត្តិគ្រប់គ្រងផែនដីបរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធោទកទាយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គន្ធោទកទាយកត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទានា លេខ ៧២ ទំព័រ ២៣៩)

# ៣. បញ្ចទីបកត្ថេរាបទាន

(រឿងព្រះថេរៈបូជាប្រទីបជុំវិញដើមពោធិព្រឹក្ស)

(ព្រះបញ្ចទីបកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំជឿស៊ប់ ក្នុងព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់អនុគ្រោះដល់សព្វសត្វ ទ្រង់មានទិដ្ឋិត្រង់ ។ ខ្ញុំបានថ្វាយប្រទីបជាទាន ព័ទ្ធជុំវិញដើមពោធិព្រឹក្ស កាលខ្ញុំជឿហើយ បានថ្វាយប្រទីបទាំងឡាយ ក្នុងវេលានោះ លុះខ្ញុំទៅកើតក្នុងកំណើតណាៗ ទោះបីទេវតា ឬជាមនុស្ស ពួកទេវ-តាតែងទ្រោលបំភ្លឺគប់ភ្លើងព្វដ៏អាកាស នេះជាផលនៃការថ្វាយប្រទីប ។

ខ្ញុំបានទទួលនូវទស្សនកិច្ច (ឃើញរូបទាំងពួង) ចម្ងាយ ១00 យោជន៍ ដោយជុំវិញ ឃើញធ្លុះទៅខាងក្រៅជញ្ជាំងខាងក្រៅផែនថ្ម និងភ្នំបាន ។

ដោយសេសផលនៃកុសលកម្មនោះ ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈ ខ្ញុំទ្រទ្រង់នូវរាងកាយ ជាទីបំផុតក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ជាធំជាងសត្វជើងពីរ ។

ក្នុងកប្បទី ៣,៤០០ ខ្ញុំបានជាស្តេចចក្រពត្តិច្រើនជាតិ មាននាមថា សតចក្ខុដូចគ្នា មានតេជៈច្រើន ទាំងមានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចទីបកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ចទីបកត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទានា លេខ ៧២ ទំព័រ ២៤៤)

## ៤. ធជទាយកត្ថេរាបទាន

(រឿងព្រះថេរៈបូជាទង់ រើសស្លឹកពោធិ៍ និងថ្វាយបង្គំដើមពោធិព្រឹក្ស)

(ព្រះធជទាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំមានចិត្តរីករាយ បានលើកឡើងនូវទង់ជិតគល់ពោធិព្រឹក្សដ៏ឧត្តម របស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ។ ខ្ញុំរើសស្លឹកពោធិដែលជ្រុះមក យកទៅចោលខាងក្រៅខឿន ខ្ញុំបានថ្វាយបង្គំ

ពោធិព្រឹក្សដ៏ប្រសើរ ដូចថ្វាយបង្គំព្រះសម្ពុទ្ធចំពោះព្រះភក្ត្រ ទ្រង់ស្អាតខាងក្នុង ស្អាតខាងក្រៅ ទ្រង់មានព្រះហឫទ័យផុតស្រឡះ ទាំងមិនមានអាសវៈ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់ឋិតនៅក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថាៈ "កុលបុត្តនោះ នឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ដោយផលទាំង ២ យ៉ាង គឺការថ្វាយទង់ និងការបម្រើនេះ ។ កុលបុត្តនោះ នឹងទទួលនូវភាពជាទេវតា មានជោគល្អជាច្រើនជាតិរាប់មិនអស់ ក្នុងឋានទេវលោក ។ នឹងបានជាស្តេចក្នុងដែនអស់ច្រើនរយជាតិ នឹងបានជាស្តេចចក្រពត្តិព្រះនាមឧគ្គតៈ ។ កុលបុត្តនោះ លុះទទួលសម្បត្តិហើយ មានកុសលមូលដាស់តឿន នឹងបានត្រេកអរក្នុងសាសនា របស់ព្រះមានព្រះភាគព្រះនាមគោតម" ។

ខ្ញុំមានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់រំងាប់ មិនមាន ឧបក្កិលេស ទ្រទ្រង់នូវរាងកាយជាទីបំផុត ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងកប្បទី ៥១ ពាន់ ខ្ញុំបានជាក្សត្រច្រើនជាតិ ព្រះនាម ឧគ្គតៈដូចគ្នា ក្នុងកប្បទី ៥០ ពាន់ ខ្ញុំបានជាក្សត្រប្រមុខសេនា ច្រើនជាតិ ព្រះនាមខេមៈដូចគ្នា ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យ ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ហើយ ។

បានឮថា ព្រះធជទាយកត្ថេរមានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធជទាយកត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទានា លេខ ៧២ ទំព័រ ២៤៥)

## ៥. អសនពោធិយត្ថេរាបទាន

(រឿងព្រះថេរៈដាំដើមធ្នង់ជាពោធិព្រឹក្ស)

(ព្រះអសនពោធិយត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីត ជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត បានឃើញព្រះលោកនាយក

ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ហើយចូលទៅគាល់ព្រះសម្ពុទ្ធ ជាបុគ្គលប្រសើរជាងពួកនរៈ ។ ខ្ញុំជាអ្នកមានចិត្តរីករាយ បានដាំ (ដើមធ្នង់) ជាពោធិព្រឹក្សដ៏ឧត្តម ថ្វាយព្រះមានព្រះភាគ ព្រះនាមតិស្សៈ ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ លុះដើមធ្នង់នោះដុះឡើងផុតអំពីផែនដី ខ្ញុំក៏បានថែទាំដើមធ្នង់ជាពោធិ៍ដ៏ឧត្តមនោះអស់ ៥ ឆ្នាំ។ ខ្ញុំបានឃើញដើមធ្នង់ មានផ្កាល្អចំឡែក គួរព្រឺរោមហើយ ក៏ប្រកាសនូវកម្មរបស់ខ្លួន ទើបចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ គ្រានោះឯងព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជាសយម្ភូអគ្គបុគ្គលនោះ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយទ្រង់សម្ដែងនូវគាថា ទាំងនេះថា៖ "កុលបុត្តណា ដាំដើមឈើជាពោធិព្រឹក្សនេះផង ធ្វើពុទ្ធបូជាដោយគោរពផង តថាគតនឹងសម្ដែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្ដាប់តថាគតសម្ដែងចុះ ។ កុលបុត្តនោះ នឹងបាននូវទេវសម្បត្តិក្នុងទេវលោកអស់ ៣០ កប្ប នឹងបានជាស្ដេចចក្រពត្តិអស់ ៦៤ ដង។ លុះច្យុតចាកតុសិតទេវលោក មានកុសលមូលដាស់តឿននឹងបាននូវសម្បត្តិទាំងពីរ ហើយនឹង

ត្រេកអរក្នុងអត្តភាពជាមនុស្ស ។ កុលបុត្តនោះ មានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់រំងាប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិញ្វន” ។

ខ្ញុំប្រកបរឿយៗ ក្នុងទីស្ងាត់ មានចិត្តស្ងប់រំងាប់ មិនមានឧបធិ-ក្កិលេស ជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ផ្តាច់នូវទន្លីង ។

ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំដាំដើមពោធិ៍ (ថ្វាយព្រះសម្ពុទ្ធ ព្រះនាមតិស្សៈ) ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការដាំដើមពោធិ៍ ។

ក្នុងកប្បទី ៧៤ អំពីភទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ មានព្រះនាមប្រាកដថាទណ្ឌសេនៈ ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ ក្នុងកាលនោះ ។

ក្នុងកប្បទី ៧៣ អំពីភទ្ទកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ជាធំលើផែនដី ៧ ដង មានព្រះនាមថាសមន្តនេមិដូចគ្នា ។

ក្នុងកប្បទី ២០ គត់ អំពីភទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្រ-

ពត្តិមួយព្រះអង្គ ទ្រង់ព្រះនាមបុណ្ណកៈ បរិបូណ៌ដោយកែវ ៧ ប្រការ ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអសនពោធិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អសនពោធិយត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទានា លេខ ៧២ ទំព័រ ២៤៩)

## ៦. ពោធិសិញ្ចកត្ថេរាបទាន

(រឿងព្រះថេរៈស្រោចទឹកដើមពោធិព្រឹក្ស)

(ព្រះពោធិសិញ្ចកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

មានពិធីឆ្លងព្រះមហាពោធិព្រឹក្ស របស់ព្រះមានព្រះភាគព្រះនាមវិបស្សី ក្នុងកាលនោះ ខ្ញុំជាអ្នកបួសមានចិត្តស្ងប់រំងាប់ដើរចូលទៅ (ជិតដើមពោធិព្រឹក្សនោះ) ។

ខ្ញុំដងទឹកត្រពាំងស្រោចដើមពោធិព្រឹក្ស (ដោយគិតថា) ព្រះវិបស្សីសម្ពុទ្ធ ទ្រង់រួចចាកទុក្ខហើយ នឹងញុំាងយើងឱ្យរួចទុក្ខផង ទ្រង់រំលត់ទុក្ខហើយ នឹងញុំាងយើងឱ្យរលត់ផង ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្រោចស្រប់ដើមពោធិព្រឹក្សក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្រោចពោធិព្រឹក្ស ។

ក្នុងកប្បទី ៣៣ កំពុងប្រព្រឹត្តទៅ ខ្ញុំបានជាស្តេចចក្រពត្តិ ៨ ដង ជាធំលើពួកជន ទ្រង់ព្រះនាមឧទកាសេចនៈដូចគ្នា ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិសិញ្ចកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិសិច្ចកត្ថេរាបទាន

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧២ ទំព័រ ២៩៤)

# ៧. តិបុប្ផិយត្ថេរាបទាន

(រឿងព្រះថេរៈបូជាផ្កា ៣ ទងចំពោះពោធិព្រឹក្ស)

(ព្រះតិបុប្ផិយត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ក្នុងភពមុខ ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញដើម ច្រនៀង (ជាពោធិព្រឹក្ស) មានពណ៌ខៀវបំព្រង ហើយខ្ញុំរោយផ្កា ៣ ទង (ត្រង់គល់ច្រនៀងនោះ)។ កាលនោះ ខ្ញុំរើសស្លឹកស្ងួតៗ យកទៅចោលខាងក្រៅ ហើយថ្វាយបង្គំដើមច្រនៀងនោះ ដូចជាថ្វាយបង្គំព្រះសម្ពុទ្ធព្រះនាមវិបស្សី ជាលោកនាយកទ្រង់ស្អាតខាងក្នុង ស្អាតខាងក្រៅ មានព្រះទ័យផុតស្រឡះ (ចាកកិលេស) មិនមានអាសវៈ ក្នុងទីចំពោះមុខ ហើយធ្វើកាលកិរិយាក្នុងទីនោះ ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាដើមពោធិព្រឹក្ស ។

ក្នុងកប្បទី ៣០ អំពីកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិ ១៣

ផង ព្រះនាមសមន្តបាសាទិកៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

ចប់ តិបុប្ផិយត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧២ ទំព័រ ៣០៤)

## ៨. តម្ពបុប្ផិយត្ថេរាបទាន

(រឿងព្រះថេរៈរោយផ្កាឈើក្រហមទៀបគល់ពោធិព្រឹក្ស)

(ព្រះតម្ពបុប្ផិយត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំប្រកបក្នុងការងាររបស់ជនដទៃ បានធ្វើនូវកំហុស ជាអ្នកពេញប្រៀបដោយភ័យ និងពៀរ ហើយក៏ស្ទុះរត់ទៅពួនក្នុងព្រៃ ។

ខ្ញុំឃើញដើមឈើ ដែលមានផ្ការីកស្គុះស្គាយចងជាចង្កោម

ដែលធម្មតានិម្មិតល្អហើយ កាន់យកនូវផ្កាក្រហមរោយរាយចុះទៀបពោធិព្រឹក្ស ។

ខ្ញុំបោសដើមច្រនៀង ជាឈើដ៏ឧត្តម ជាពោធិព្រឹក្សនោះ ហើយចូលទៅជិតគល់ពោធិព្រឹក្សអង្គុយផ្គត់ភ្នែន ។

កាលពួកជនស្វែងរកផ្លូវដែលខ្ញុំទៅ ក៏មកកាន់សម្នាក់ខ្ញុំ លុះខ្ញុំឃើញនូវពួកជនទាំងនោះ ក៏នឹកដល់ពោធិព្រឹក្សដ៏ឧត្តមក្នុងទីនោះ។

ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំដើមពោធិព្រឹក្ស រួចហើយក៏ធ្លាក់ទៅក្នុងជ្រោះភ្នំដែលគួរខ្លាច មានជម្រៅច្រើនជួរដើមត្នោត ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាពោធិព្រឹក្ស ។

ក្នុងកប្បទី ៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមសម្មសិតៈ ទ្រង់មានកម្លាំងច្រើន បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិ

ហើយ ។

បានឮថា ព្រះតម្ពបុប្ផិយត្ថេរមានអាយុ បានសម្ដែងហើយ នូវគាថា ដោយប្រការដូច្នេះ ។

ចប់ តម្ពបុប្ផិយត្ថេរាបទាន

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៣ ទំព័រ ៧៨)

## ៩. សីហាសនទាយកត្ថេរាបទាន

(រឿងព្រះថេរៈថ្វាយសីហាសនៈ និងថ្វាយបង្គំដើមពោធិព្រឹក)

(ព្រះសីហាសនទាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈជានាយក ជាទីពឹងនៃលោក បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយសីហាសនៈ ។ សេចក្ដីពិត ជនមានប្រមាណច្រើននាក់ បាននូវសេចក្ដីសុខក្នុងបរលោក ហើយរំលត់ទុក្ខបាន ព្រោះធ្វើនូវការបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាច្រើនក្នុងទីបរិនិព្វាននោះ ។

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ថ្វាយបង្គំនូវពោធិព្រឹក្ស

ដ៏ឧត្តម ខ្ញុំមិនទៅកើតក្នុងទុគ្គតិអស់មួយសែនកប្ប ព្រោះកុសលនេះ ។

ក្នុងកប្បទី ១៥.០០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ ព្រះនាមសីលុច្ចយៈដូចគ្នា ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ។

បានឮថា ព្រះសីហាសនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សីហាសនទាយកត្ថេរាបទាន

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៣ ទំព័រ ១០៥)

## ១០. ឯកទីបិយត្ថេរាបទាន

(រឿងព្រះថេរៈបូជាប្រទីបដើមពោធិព្រឹក)

(ព្រះឯកទីបិយត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយប្រទីបមួយដល់ព្រះមុនី ព្រះនាមបទុមុត្តរៈទៀបដើមស្រល់ ជាពោធិព្រឹក្សដ៏

ប្រសើរ ។

កាលខ្ញុំកើតក្នុងភព កាលការសន្សំបុណ្យកើតហើយ ខ្ញុំក៏មិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយប្រទីប ។

ក្នុងកប្បទី ១៦ ពាន់អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមចន្ទាភៈដូចគ្នា ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទីបិយត្ថេរមានអាយុ បានសម្តែងនូវគាថានេះ ដោយប្រការដូច្នេះ ។

ចប់ ឯកទីបិយត្ថេរាបទាន

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៣ ទំព័រ ១០៧)

## ១១. ពោធិឧបដ្ឋាយកត្ថេរាបទាន

(រឿងព្រះថេរៈបម្រើដើមពោធិព្រឹក)

(ព្រះពោធិឧបដ្ឋាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំជាអ្នកវាយសំភោក្នុងនគររម្មវតី បានទៅប្រកបការបម្រើជានិច្ចនូវដើមពោធិព្រឹក្សដ៏ប្រសើរ ។

ខ្ញុំបម្រើល្ងាចព្រឹក ត្រូវកុសលមូលដាស់តឿនហើយ ក្នុងកប្បទី១,៨០០ ខ្ញុំមិនដែលទៅកើតក្នុងទុគ្គតិ ។

ក្នុងកប្បទី ១,៥០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រ-ពត្តិ ជាធំជាងជន មានព្រះនាមទមថ ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិឧបដ្ឋាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិឧបដ្ឋាយកត្ថេរាបទាន

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៣ ទំព័រ ១១៧)

## ១២. សកឹសម្មជ្ជកត្ថេរាបទាន

(រឿងព្រះថេរៈបោសសម្អាតទីលានដើមពោធិព្រឹក្ស)

(ព្រះពោធិសម្មជ្ជកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីត

ជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំ(បានឃើញ) ដើមជ្រនៀង ជាពោធិព្រឹកដ៏ឧត្តមរបស់ព្រះមានព្រះភាគព្រះនាមវិបស្សី លុះខ្ញុំបានឃើញឈើដ៏ប្រសើរនោះហើយ ក៏ញុំាងចិត្តឱ្យជ្រះថ្លាចំពោះឈើនោះ ។ ខ្ញុំចាប់យកអំបោស ហើយបោសដើមពោធិព្រឹក្សក្នុងពេលនោះភ្លាម លុះខ្ញុំបានបោសរួចហើយ ក៏ថ្វាយបង្គំដើមជ្រនៀងជាពោធិព្រឹក្សនោះ ។ ខ្ញុំធ្វើចិត្តឱ្យជ្រះថ្លាចំពោះពោធិព្រឹក្សនោះ រួចធ្វើអញ្ជលីលើក្បាល នមស្ការពោធិព្រឹក្សនោះ ហើយដើរថយក្រោយទៅ ។ កាលខ្ញុំកំពុងនឹកចំពោះពោធិព្រឹក្សដ៏ប្រសើរ ហើយដើរបណ្តើរតាមផ្លូវជាទីត្រាច់ទៅ ស្រាប់តែពស់ថ្លាន់មួយជាសត្វក្លាហានមានកម្លាំងច្រើនរួបរឹតខ្ញុំ។

អំពើដែលខ្ញុំបានធ្វើក្នុងពេលថ្មីៗ ក៏ញុំាងខ្ញុំឱ្យត្រេកអរចំពោះផល ចំណែកឯពស់ថ្លាន់ លេបរាងកាយខ្ញុំចូលបាត់ទៅ ខ្ញុំបានទៅរីករាយក្នុងទេវលោក ។

ចិត្តរបស់ខ្ញុំឥតមានកករល្អក់ឡើយ ជាចិត្តសស្អាតសព្វៗកាល ខ្ញុំមិនដែលស្គាល់នូវសរ គឺសេចក្តីសោក ដែលជាហេតុ

ញុំាងចិត្តរបស់ខ្ញុំឱ្យក្តៅក្រហាយឡើយ ។

រោគឃ្លង់ រោគបូស រោគស្រែង រោគឆ្កួតជ្រូក ឃ្លង់ដែក ដំនួចពិស រមាស់ ខ្ញុំពុំដែលមានឡើយ នេះជាផលនៃការបោសសម្អាត ។

សេចក្តីសោក និងសេចក្តីក្តួលក្តៅក្នុងហឫទ័យ ខ្ញុំមិនដែលមានទេ ចិត្តរបស់ខ្ញុំជាចិត្តត្រជាក់ មិនភាន់ភាំង នេះជាផលនៃការបោសសម្អាត ។

ខ្ញុំដល់នូវសមាធិម្តងទៀត ចិត្តនៃខ្ញុំជាធម្មជាតបរិសុទ្ធ ខ្ញុំប្រាថ្នាសមាធិណាៗ សមាធិនោះៗ រមែងសម្រេចដល់ខ្ញុំ ។

ខ្ញុំមិនដែលត្រេកត្រអាល ចំពោះរបស់ដែលគួរត្រេក-ត្រអាល ម្យ៉ាងទៀត ខ្ញុំមិនដែលប្រទូស្ត ចំពោះរបស់ដែលគួរប្រទូស្ត មិនបានវង្វេងចំពោះរបស់ដែលគួរវង្វេង នេះជាផលនៃការបោសសម្អាត ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអំពើល្អ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបោសសម្អាត ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង។

ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អុហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសកឹសម្មជ្ជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សកឹសម្មជ្ជកត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៥ ទំព័រ ៣៨)

## ១៣. ពោធិសម្មជ្ជកត្ថេរាបទាន

(រឿងព្រះថេរៈរើសស្លឹកពោធិព្រឹក្សក្នុងលានព្រះចេតិយយកទៅចោល)

(ព្រះពោធិសម្មជ្ជកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីត

ជាតិរបស់ខ្លួន ទើបពោលថា)

ក្នុងភពមុន ខ្ញុំបានរើសស្លឹកពោធិ៍ ដែលជ្រុះក្នុងលានព្រះចេតិយហើយយកទៅចោល ខ្ញុំបាននូវគុណ ២០។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ តែងអន្ទោលទៅក្នុងភពទាំងពីរ គឺទេវតា និងមនុស្ស ដោយតេជះនៃកម្មនោះ ។ លុះខ្ញុំច្យុតចាកទេវលោកមកកាន់ភពរបស់មនុស្ស តែងកើតក្នុងត្រកូលពីរ គឺក្សត្រនិងព្រាហ្មណ៍ ។

ខ្ញុំបរិបូណ៌ដោយអវយវៈតូចធំ មានកម្ពស់និងទំហំសមរម្យ មានរូបល្អ មានសម្បុរស្អាត មានរាងកាយពេញលេញមិនខ្វះខាត ។

ខ្ញុំកើតក្នុងទេវលោក ឬក្នុងមនុស្សលោក ឬក៏ក្នុងភពណាមួយ តែងមានសម្បុរល្អដូចមាស ឬប្រៀបដូចមាសឆ្អិន ។ សម្បុររបស់ខ្ញុំ ទន់ល្មន់ល្មោស ជិតស្និទ្ធ ល្អិត ផូរផង់សព្វៗកាល ព្រោះបានយកស្លឹកពោធិ៍ទៅចោល ។

ទឹកដែលច្រឡំដោយធូលី មិនដែលប្រឡាក់ក្នុងប្រជុំសរីរៈ(របស់ខ្ញុំ) ក្នុងកាលណាម្តងឡើយ នេះជាផលក្នុងការយកស្លឹក

ពោធិ៍ទៅចោល ។

ខ្លួនរបស់ខ្ញុំនោះ (ឋិតនៅ) ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ក្តៅក្តី ឬត្រូវកម្តៅភ្លើងក្តី ញើសទាំងឡាយក៏មិនដែលហូរចេញ នេះជាផលក្នុងការយកស្លឹកពោធិ៍ទៅចោល ។

រោគឃ្លង់ពក ស្រែង ប្រជ្រុយ បូស ដំនួចពិស មិនដែលមានក្នុងកាយ (របស់ខ្ញុំឡើយ) នេះជាផលក្នុងការយកស្លឹកពោធិ៍ទៅចោល ។

គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺរោគទាំងឡាយ មិនដែលកើតក្នុងកាយរបស់ខ្ញុំឡើយ នេះជាផលក្នុងការយក ស្លឹលពោធិទៅចោល ។

គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូច និងភពធំ គឺអន្តរាយជាគ្រឿងបៀតបៀន ដែលកើតអំពីចិត្ត មិនដែលមានឡើយ នេះជាផល ក្នុងការយកស្លឹកពោធិ៍ទៅចោល ។

គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺពួកសត្រូវ មិនដែលមានដល់ខ្ញុំនោះ នេះជាផលក្នុងការយកស្លឹកពោធិ៍ទៅចោល ។

គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺភោគៈមិនដែលខ្វះខាតឡើយ នេះជាផលក្នុងការយកស្លឹក-ពោធិ៍ទៅចោល ។

គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺភ័យ អំពីភ្លើងនិងស្តេច អំពីចោរនិងទឹក មិនដែលមានឡើយ ។

មានគុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូច និងភពធំ គឺពួកខ្ញុំស្រីខ្ញុំប្រុស ជាអ្នកប្រព្រឹត្តតាម ជាអ្នកលុះអំណាចចិត្តរបស់ខ្ញុំ ។

បុគ្គលកើតក្នុងភព ជារបស់មនុស្ស មានកំណត់អាយុត្រឹមណា អាយុរបស់ខ្ញុំមិនថយចុះអំពីកំណត់ត្រឹមនោះ តែងឋិតនៅដរាបដល់អស់អាយុ ។

ពួកជនទាំងអស់ អ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាសេចក្តីសុខ ទោះនៅខាងក្នុងក្តី ខាងក្រៅក្តី អ្នកនិគមក្តី អ្នកដែនក្តីសុទ្ធតែជាអ្នកប្រកបតាមខ្ញុំ ។

ខ្ញុំជាអ្នកមានភោគៈ មានយស មានសិរី មានពួកញាតិ ជា

អ្នកឥតមានវេរា ប្រាសចាកសេចក្តីតក់ស្លុត តែងមានក្នុងភពសព្វៗ កាល ។

ពួកទេវតា មនុស្ស អសុរ គន្ធព្វ យក្ខ អារក្សទឹក អ្នកទាំងអស់នោះ តែងរក្សាខ្ញុំ ដែលអន្ទោលទៅក្នុងភពសព្វៗ កាល ។

ខ្ញុំទទួលយសទាំងពីរក្នុងទេវលោកផង ក្នុងមនុស្សលោកផង រួចខ្ញុំបានដល់នូវព្រះនិព្វាន ជាសិវដ្ឋានដ៏ប្រសើរ ក្នុងកាលជាទីបំផុត ។

បុរសណា ឧទ្ទិសចំពោះព្រះសម្ពុទ្ធ ឬចំពោះដើមពោធិ៍របស់ព្រះសាស្តានោះ គប្បីទទួលនូវផលបុណ្យ (ផលទាំងអស់) ឈ្មោះថាបុរសនោះបានដោយក្រ ដូចម្តេចបាន ។

បុគ្គល (ដែលឋិតនៅ) ក្នុងមគ្គ ក្នុងផល ក្នុងបរិយត្តិ ក្នុងគុណ គឺឈាននិងអភិញ្ញា ជាបុគ្គលប្រសើរក្រៃលែងជាងពួកជនដទៃ ជាអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។

ក្នុងភពមុន ខ្ញុំមានចិត្តរីករាយ បានយកស្លឹកពោធិ៍ទៅចោលទើបជាអ្នកបរិបូណ៌ដោយអង្គ ២០ នេះ សព្វៗ កាល ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដក

ចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិសម្មជ្ជកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិសម្មជ្ជកត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន លេខ ៧៥ ទំព័រ ២៦៩)

# អានិសង្សកសាងខឿនដើមពោធិព្រឹក្ស

## ១. វេទិទាយកត្ថេរាបទាន

(រឿងព្រះថេរៈឱ្យគេធ្វើខឿនដើមពោធិព្រឹក្ស)

(ព្រះវេទិទាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឱ្យគេធ្វើខឿនត្រង់ដើមពោធិព្រឹក្សដ៏ប្រសើររបស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឱ្យគេកសាងខឿន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខឿន ។

ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសុរិយស្សមៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យ

ជាក់ច្បាស់ហើយ ទាំងសាសនាព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះវេទិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ។

ចប់ វេទិទាយកត្ថេរាបទាន

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៣ ទំព័រ ១៧៣)

## ២. អនុលោមទាយកត្ថេរាបទាន

(រឿងព្រះថេរៈធ្វើខឿនពោធិព្រឹក្ស ថ្វាយដុំបាយអ និងបូកបាយអ)

(ព្រះអនុលោមទាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំបានធ្វើខឿនពោធិព្រឹក្សនៃព្រះមុនីព្រះនាមអនោមទស្សី បានដាក់ដុំបាយអ ហើយធ្វើនូវបាណិកម្ម (បូក) ។

ព្រះសាស្តាព្រះនាមអនោមទស្សីប្រសើរជាងនរៈ គង់ក្នុងកណ្តាលភិក្ខុសង្ឃ ឃើញអំពើដែលខ្ញុំធ្វើល្អនោះហើយ ទើបសម្តែងគាថានេះថា កុលបុត្តនេះ បានសោយសម្បត្តិដោយការបូកបាយអនេះផង ដោយការតម្កល់ទុកនូវចេតនា ហើយនឹងធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខ ។

ខ្ញុំមានសម្បុរមុខថ្លាស្រស់ មានចិត្តនឹងនៅក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំល្អ ខ្ញុំទ្រទ្រង់នូវរាងកាយជាទីបំផុតក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងកប្បទី ១០០ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមសម្បស្សនៈ ទ្រង់បរិបូណ៌ មិនខ្វះខាត (ដោយសម្បត្តិ) មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុលោមទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការ ដូច្នេះ ។

ចប់ អនុលោមទាយត្ថេរាបទាន

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៣ ទំព័រ ៧០)

## ៣. តេលមក្ខិយត្ថេរាបទាន

(រឿងព្រះថេរៈលាបប្រេងត្រង់ខឿនដើមពោធិព្រឹក្ស)

(ព្រះតេលមក្ខិយត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

កាលព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈជានរាសភៈ បរិ-និព្វានហើយ ក្នុងកាលនោះ ខ្ញុំបានលាបប្រេងត្រង់ខឿនពោធិព្រឹក្ស ។

ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានលាបប្រេង ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការលាបប្រេង ។

ក្នុងកប្បទី ២៤ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមសុច្ឆវិ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតេលមក្ខិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ។

ចប់ តេលមក្ខិយត្ថេរាបទាន

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៣ ទំព័រ ១៩៩)

# ៤. អញ្ជលិយត្ថេរាបទាន

(រឿងព្រះថេរៈថ្វាយក្បាច់អញ្ជលិចំពោះពោធិព្រឹក្ស)

(ព្រះអញ្ជលិយត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំបានថ្វាយក្បាច់អញ្ជលិ ចំពោះពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមានព្រះភាគព្រះនាមតិស្សៈ ដែលជាឈើដុះលើធរណី ។

ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយអញ្ជលិ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាពោធិព្រឹក្ស ។

ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិព្រះនាមទេវលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអញ្ជលិយត្ថេរមានអាយុ បានសម្តែងនូវ

គាថាទាំងនេះ ដោយប្រការដូច្នេះ។

ចប់ អឌ្ឍចន្ទិយត្ថេរាបទាន ។

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៣ ទំព័រ ២០០)

## ៥. វេទិយការកត្ថេរាបទាន

(រឿងព្រះថេរៈកសាងកំពែងទៀបគល់ដើមពោធិព្រឹក្ស)

(ព្រះវេទិយការកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំកសាងកំពែងដ៏ល្អ ទៀបដើមពោធិព្រឹក្សដ៏ឧត្តម របស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈហើយញុំាងចិត្តរបស់ខ្លួនឱ្យជ្រះថ្លា ។

ភណ្ឌៈទាំងឡាយដ៏ប្រសើរលើសលុប ដែលគេធ្វើហើយក្តី គេមិនទាន់ធ្វើហើយក្តី រមែងធ្លាក់ចុះមកអំពីអាកាស នេះជាផលនៃកំពែង ។

ខ្ញុំស្ទុះចូលទៅក្នុងពួកសង្គ្រាម ជាទីគួរខ្លាចដោយចំណែកទាំងពីរក៏មិនឃើញនូវភ័យដែលគួរខ្លាច នេះជាផលនៃកំពែង ។

វិមានដ៏ល្អរមែងកើតឡើង ទីដេកទាំងឡាយជារបស់មានតម្លៃច្រើន ក៏កើតឡើង ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ នេះ

ជាផលនៃកំពែង ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកំពែងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកំពែង ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្ដាច់នូវទន្លីង ។

ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ។

បានឮថា ព្រះវេទិយការកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ។

ចប់ ព្រះវេទិយការកត្ថេរាបទាន

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៥ ទំព័រ ១០២)

# ៦. ពោធិឃរការកត្ថេរាបទាន

(រឿងព្រះថេរៈធ្វើខឿនដើមពោធិព្រឹក្ស)

(ព្រះពោធិឃរការកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើខឿននៃដើមពោធិព្រឹក្ស របស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ព្រះអង្គជាធំជាងសត្វជើងពីរ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ។

ខ្ញុំបានទៅកើតក្នុងឋានតុសិត នៅក្នុងផ្ទះកែវ សម្ផ័ស្ស ទាំងឡាយត្រជាក់ក្តី ក្តៅក្តី ខ្យល់ក្តី មិនដែលពាល់ត្រូវខ្លួនខ្ញុំឡើយ ។

ក្នុងកប្បទី ៦៥ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ នគររបស់ស្តេចនោះ ឈ្មោះកាសិកៈ ដែលវិស្សុកម្មទេវបុត្រសាងថ្វាយ ។

(នគរនោះ) មានបណ្តោយ ១០ យោជន៍ ទំហំ ៨ យោជន៍ ឈើក្តី វល្លិក្តី ដីស្អិតក្តី មិនមានក្នុងនគរនោះឡើយ ។

ប្រាសាទឈ្មោះមង្គលៈ ដែលវិស្សុកម្មទេវបុត្រសាងថ្វាយ

មានទទឹង ១ យោជន៍ ទំហំកន្លះយោជន៍ ។

សរសរ ៨៤,០០០ សឹងជាវិការៈនៃមាស ប្រាសាទកំពូលជាវិការៈនៃកែវមណី ដំបូលជាវិការៈនៃប្រាក់ ។

ផ្ទះជាវិការៈនៃមាសទាំងអស់ ដែលវិស្សុកម្មទេវបុត្រសាងថ្វាយហើយ ផ្ទះនុ៎ះខ្ញុំនៅអាស្រ័យហើយ នេះជាផលនៃការឱ្យនូវខឿន ។

ខ្ញុំបានសោយនូវភពជារបស់ទេវតា និងមនុស្សទាំងអស់នោះហើយ ដល់នូវព្រះនិព្វាន ជាបទដ៏ស្ងប់ប្រសើរក្នុងថ្ងៃនេះ។

ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានធ្វើខឿនពោធិ-ព្រឹក្សក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឱ្យនូវខឿន ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។

ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ

ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំក៏បានប្រតិបត្តិហើយ។

បានឮថា ព្រះពោធិយរការកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ពោធិយរការត្ថេរបទាន

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៥ ទំព័រ ១០៤)

## ៧. ជគតិទាយកត្ថេរបទាន

(រឿងព្រះថេរៈឱ្យគេពូនផែនដីជិតខឿនដើមពោធិព្រឹក្ស)

(ព្រះជគតិទាយកត្ថេរ កាលនឹងប្រកាសប្រវត្តិក្នុងអតីតជាតិរបស់ខ្លួន ទើបពោលថា)

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឱ្យគេពូនផែនដីជិតដើមពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះមហាមុនីព្រះនាមធម្មទស្សី ។

ខ្ញុំរបូតធ្លាក់ក្នុងជ្រោះក្តី អំពីភ្នំក្តី អំពីដើមឈើក្តី រមែងបាននូវទីពឹង នេះជាផលនៃការពូនផែនដី ។

ចោរទាំងឡាយ មិនហ៊ានបៀតបៀនខ្ញុំ ក្សត្រទាំងឡាយមិន

ហាក់មើលងាយខ្ញុំ ខ្ញុំកន្លងផុតនូវសត្រូវទាំងពួង នេះជាផលនៃការពូនផែនដី ។

ខ្ញុំកើតក្នុងកំណើតណាៗ ទោះជាទេវតា ឬជាមនុស្សអ្នកផងតែងបូជាក្នុងទីទាំងពួង នេះជាផលនៃការពូនផែនដី ។

ក្នុងកប្បទី ១,៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឱ្យគេពូន ផែនដីក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការពូនផែនដី ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង។

ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជគតិទាយកត្ថេរមានអាយុ បានសម្ដែងនូវ

គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជគតិទាយកត្ថេរាបទាន

(ខុទ្ទកនិកាយ អបទាន បិដកលេខ ៧៥ ទំព័រ ១០៧)

# បំភ្លឺពាក្យមួយចំនួន

ពាក្យថា "ដើមពោធិព្រឹក្ស" គឺដើមឈើ តាមតែឈើណាក៏ដោយដែលព្រះពោធិសត្វគង់អាស្រ័យក្រោមម្លប់ ទ្រង់ក៏បានត្រាស់ដឹងជាព្រះពុទ្ធ ដើមឈើនោះក៏បានឈ្មោះហៅថា "ដើមពោធិព្រឹក្ស" ទាំងអស់, ឬហៅថាមហាពោធិព្រឹក្ស ឬក៏ព្រះស្រីមហាពោធិព្រឹក្ស ក៏បាន។

ពាក្យថា "ចេតិយ" គឺវត្ថុដែលគួរគោរពបូជានៃមនុស្ស និងទេវតា ។

ពាក្យថា "អានិសង្ស" ប្រែថា ផលនៃកុសល, ផលបុណ្យ, គុណប្រយោជន៍ ឬសេចក្ដីសុខ-ចម្រើន ដែលបានអំពីការប្រព្រឹត្តល្អ។

ពាក្យថា "បូជា" ប្រែថា ការគំនាប់, រាប់អាន, គោរព, កោតក្រែង។

ពាក្យថា "បដិសម្ភិទា" ប្រែថា សេចក្ដីបែកធ្លាយ, ការដឹងបែកធ្លាយ, បញ្ញាបែកធ្លាយ **មាន ៤ យ៉ាង** គឺៈ

**១-អត្ថប្បដិសម្ភិទា** បញ្ញាបែកធ្លាយក្នុងអត្ថ (សេចក្ដី)

**២-ធម្មប្បដិសម្ភិទា** បញ្ញាបែកធ្លាយក្នុងធម៌

**៣-និរុត្តិបដិសម្ភិទា** បញ្ញាបែកធ្លាយក្នុងការពោលធម្មនិរុត្តិ គឺភាសា

**៤-បដិភាណប្បដិសម្ភិទា** បញ្ញាបែកធ្លាយដ៏ធំទូលាយក្នុងចំណេះដឹងទាំងឡាយ។

ពាក្យថា "អភិញ្ញា" ប្រែថា ការដឹងដ៏ក្រៃលែង **មាន ៦ យ៉ាង** គឺៈ

**១-ឥទ្ធិវិធ** សម្ដែងឫទ្ធិផ្សេងៗបាន

**២-ទិព្វសោត** ត្រចៀកទិព្វ

**៣-ចេតោបរិយញ្ញាណ** ញាណដែលអាចដឹងចិត្តរបស់បុគ្គលដទៃបាន

**៤-បុព្វេនិវាសានុស្សតិញ្ញាណ** ញាណអាចរឭកជាតិមុនៗរបស់ខ្លួនបាន

**៥-ចុតូបបាតញ្ញាណ** ញាណដែលអាចដឹងការចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ

**៦-អាសវក្ខយញ្ញាណ** គឺញាណដែលធ្វើកិលេសឱ្យអស់ទៅ។

ពាក្យថា "វិមោក្ខ" ប្រែថា ការរួចផុតចាកកិលេស **មាន ៨ យ៉ាង**គឺៈ រូបជ្ឈាន ៤ និងអរូបជ្ឈាន ៤។

-រូបជ្ឈាន ៤ នោះ គឺៈ

**១- បឋមជ្ឈាន** ឈានទី១ មានអង្គ ៥ គឺ វិតក្កៈ, វិចារៈ, បីតិ, សុខ, ឯកគ្គតា។

**២- ទុតិយជ្ឈាន** ឈានទី ២ មានអង្គ ៣ គឺ បីតិ, សុខ, ឯកគ្គតា។

**៣-តតិយជ្ឈាន** ឈានទី ៣ មានអង្គ ២ គឺ សុខ, ឯកគ្គតា។

**៤-ចតុត្ថជ្ឈាន** ឈានទី ៤ មានអង្គ ២ គឺ ឧបេក្ខា, ឯកគ្គតា។

-អរូបជ្ឈាន ៤ នោះ គឺៈ

**១-អាកាសានញ្ចាយតនជ្ឈាន** កំណត់យកអាកាសមិនមានទី

បំផុតជាអារម្មណ៍

**២-វិញ្ញាណញ្ចាយតនជ្ឈាន** កំណត់យកវិញ្ញាណមិនមានទីបំផុតជាអារម្មណ៍

**៣-អាកិញ្ចញ្ញាយតនជ្ឈាន** កំណត់យកសភាវៈមិនមានអ្វីតិចតួចជាអារម្មណ៍

**៤-នេវសញ្ញានាសញ្ញាយតនៈ** សភាវៈដែលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

## ចប់អានិសង្សនៃការបូជាដើមពោធិព្រឹក្ស
## ដោយសង្ខេប

**បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី**
**បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។**

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងពុទ្ធភូមិណា១ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

(និធិកណ្ឌសូត្រ ខុ.ខុ.បាឋ: បិ.៥២/១៥)

# ឯកសារ ស្រាវជ្រាវ ពិគ្រោះ ដកស្រង់

-ព្រះសុត្តន្តបិដក ខុទ្ទកនិកាយ អបទាន និងពុទ្ធវំសៈ (ច្បាប់របស់ពុទ្ធសាសនបណ្ឌិត្យ)

-វិនយបិដក មហាវគ្គ បព្វជ្ជាខន្ធកៈ (ពោធិកថា)

-សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ ពាហិរកថា និងបព្វជ្ជាខន្ធកៈ (ពោធិកថា)

-ជាតកដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ ជាតក (កាលិង្គពោធិជាតក)

-សុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ មហាវគ្គ (មហាបទានសូត្រ)

-សារត្ថទីបនី ដីកាព្រះវិន័យ (ពាហិរកថា និងពោធិកថា)

-គម្ពីរទីបវំង្ស, គម្ពីរមហាវំង្ស, គម្ពីរសាសនវំង្ស

-អភិធានវណ្ណនា និងអភិធានប្បទីបិកា (ភាសាថៃ)

-វចនានុក្រមពុទ្ធសាសន៏ (ភាសាថៃ)

-បទានុក្រមធម្មបទ (អាចារ្យ កឹម តូ)

-ប្រវត្តិស្រីមហាពោធិព្រឹក្ស របស់ភិក្ខុ ស្រី សុវណ្ណ ចារុវណ្ណោ

-វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ)

និងឯកសារមួយចំនួនផ្សេងទៀត ។

# សៀវភៅដែលខ្ញុំបានរៀបរៀង មានៈ

១-ឱវាទបាតិមោក្ខទីបនី ព.ស.២៥៥៨

២-វិធីអានភាសាបាលីសង្ខេប ព.ស.២៥៥៨

៣-ប្រជុំភាណវារៈ បាលី-ប្រែ ព្រមទាំងសេចក្ដីពន្យល់ ព.ស.២៥៥៩

៤-ធម៌នមស្ការព្រះរតនត្រ័យ និងធម៌កាព្យផ្សេងៗ ព.ស.២៥៦២

៥-សិក្សាធម៌នមស្ការ និងគោលធម៌សំខាន់ៗ មួយចំនួន ព.ស.២៥៦២

៦-ប្រវត្តិដើមពោធិព្រឹក្ស នៅពុទ្ធគយា វត្តជេតពន ប្រទេសស្រីលង្កា និងអានិសង្សនៃការបូជា ព.ស. ២៥៦៣

--------------

*-សារៈនៃទ្រព្យ គឺការឱ្យទាន*

*-សារៈនៃចំណេះដឹង គឺការសង្គ្រោះអ្នកដទៃ*

*-សារៈនៃការសង្គ្រោះនោះ គឺការប្រាប់ផ្លូវត្រូវ*

*-សារៈនៃរូបកាយ គឺប្រើរូបកាយសាងប្រយោជន៍*

*-សារៈនៃជីវិត គឺការប្រព្រឹត្តធម៌ ។*

កើតមួយជាតិ ធាតុមួយចាន បានធ្វើល្អ បុណ្យកំដរ តជីវិត ពិតប្រពៃ
ពេលស្លាប់ទៅ នៅល្អឈ្មោះ រស់មានន័យ ជនដទៃ លៃលកត្រាប់ ច្បាប់គំរូ។



ពុទ្ធេ គារវំ ករោតិ យោ ចេតិយំ វា ពោធឹ វា
សោ សព្វកាលេ វន្ទេយ្យ ឯតស្ស សុវត្ថិ ហោតុ ៗ

បុគ្គលណាធ្វើនូវសេចក្ដីគោរពក្នុងព្រះពុទ្ធ បុគ្គលនោះ គប្បីថ្វាយបង្គំនូវព្រះចេតិយ និងដើមពោធិព្រឹក្សឱ្យបានសព្វៗកាល សិរីសួស្ដី នឹងមានដល់បុគ្គលនោះជានិច្ចកាលដែរ ។